**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**



# សៀវភៅរបាយការណ៍
# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ
# ខេត្តកំពង់ធំ និងឧត្តរមានជ័យ

*ផលិតដោយ៖ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែមិថុនា ឆ្នាំ២០២៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សៀវភៅរបាយការណ៍
# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ
## ខេត្តកំពង់ធំ និងឧត្តរមានជ័យ

*ផលិតដោយ៖ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែមិថុនា ឆ្នាំ២០២៣**

# មាតិកា


**បុព្វកថា** ...... I

**អារម្ភកថា** ...... II

**ជំពូកទី១** ...... **១**

**សេចក្តីផ្តើម** ...... **១**

**១.១. សេចក្តីផ្តើម** ...... ២

*១.១.១. និមិត្តសញ្ញាខេត្ត* ...... *៤*

*១.១.២. ផែនទីខេត្ត* ...... *៧*

*១.១.៣. ផែនទីអនុវត្តគម្រោង* ...... *៨*

**១.២. គោលបំណង** ...... ៨

**១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ** ...... ៩

**១.៤. ការផលិតទិន្នន័យ** ...... ៩

**ជំពូកទី២** ...... **១០**

**វិភាគទិន្នន័យ** ...... **១០**

**២.១. ព័ត៌មានប្រជាសាស្ត្រ** ...... ១១

*២.១.១. ព័ត៌មានគ្រួសារ* ...... *១១*

*២.១.២. ព័ត៌មានប្រជាជន* ...... *១២*

*២.១.៣. ការផ្លាស់ប្តូរទីលំនៅ* ...... *១៤*

*២.១.៤. លំនៅឋាន* ...... *១៧*

*២.១.៥. បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់* ...... *២៣*

**២.២. អត្រាកំណើត និងមរណភាព** ...... ២៦

*២.២.១. អត្រាកំណើត* ...... *២៦*

*២.២.២. មរណភាព* ...... *២៧*

**២.៣. ពិការភាព និងបុគ្គលគ្មានអ្នកថែទាំ** ...... ៣១

**២.៤. ការលែងលះ** ...... ៣៥

**២.៥. ការប្រើប្រាស់ទឹក និងបង្គន់អនាម័យ** ...... ៣៧

**២.៦. បរិស្ថាន និងធនធានធម្មជាតិ** ...... ៤០

**២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច** ...... ៤៤

*២.៧.១. សន្តិសុខសង្គម* ...... *៤៤*

*២.៧.២. សេដ្ឋកិច្ចគ្រួសារ* ........ *៤៦*

**២.៨. វិស័យអប់រំ និងសេវាសង្គម** ........ ៤៩

*២.៨.១. វិស័យអប់រំ* ........ *៤៩*

*២.៨.២. សេវាសង្គម* ........ *៥១*

**២.៩. ផ្លូវគមនាគមន៍** ........ ៥២

**២.១០. សុខាភិបាល** ........ ៥៣

*២.១០.១. សេវាកម្មសុខភាព* ........ *៥៣*

*២.១០.២. ជំងឺសំខាន់ៗ* ........ *៥៤*

*២.១០.៣. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និងកុមារកំព្រា* ........ *៥៧*

**២.១១. កសិកម្ម** ........ ៥៨

*២.១១.១. ការកាន់កាប់ដីកសិកម្ម* ........ *៥៩*

*២.១១.២. ផ្ទៃដីកសិកម្ម និងផលិតកម្ម* ........ *៦០*

*២.១១.៣. ប្រព័ន្ធស្រោចស្រព* ........ *៦១*

*២.១១.៤. ការប្រើប្រាស់ជី និងថ្នាំពុលលើផ្ទៃដីផលិតកម្ម* ........ *៦២*

*២.១១.៥. ការចិញ្ចឹមបសុសត្វ និងបសុបក្សី* ........ *៦៣*

*២.១១.៦. ទិន្នផលដំណាំ និងគោលបំណងផលិត* ........ *៦៦*

**ជំពូកទី៣** ........ **៦៨**

**សន្និដ្ឋាន និងអនុសាសន៍** ........ **៦៨**

**៣.១. សន្និដ្ឋាន** ........ ៦៩

**៣.២. អនុសាសន៍** ........ ៦៩

**ឧបសម្ព័ន្ធ ១** ........ **៧០**

**ឧបសម្ព័ន្ធ ២** ........ **៩៤**

# បុព្វកថា

មានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូននូវរបាយការណ៍លទ្ធផលវិភាគ ស្តីពី "ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ជំហានទី៧ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលចំនួន ២ខេត្ត គឺខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។ នៅក្នុងរបាយការណ៍នេះមានទិន្នន័យសំខាន់ៗជារួមៈ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការរៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឱ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនេះឡើងតាមអនុក្រឹត្យ លេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក ។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំ និងសម្របសម្រួលការងារនេះតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ឯកឧត្តម **ចាន់ សំអាត** ប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ឯកឧត្តមប្រធានមន្ទីរផែនការ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ លោកជំទាវប្រធានមន្ទីរផែនការ និងសហការីនៃខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ នឹងប្រើប្រាស់របាយការណ៍លទ្ធផលវិភាគ ស្តីពី "ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ជំហានទី៧ ដ៏មានសារៈសំខាន់មួយនេះ។៚

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

ភ្នំពេញ កម្ពុជា
ខែមិថុនា ឆ្នាំ២០២៣

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ការបោះពុម្ពផ្សាយសៀវភៅលើកទី៧ នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដែលបានផលិតឡើងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការសហការពីមន្ទីរផែនការខេត្តខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។ សៀវភៅនេះផ្តល់នូវទិន្នន័យសំខាន់ៗមួយចំនួនរួមមាន៖ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម ដែលជាសូចនាករដ៏សំខាន់មិនអាចខ្វះបានសម្រាប់កសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ។

នៅក្នុងសៀវភៅនេះមានការវិភាគជាតារាងតួលេខ និងក្រាហ្វិក រួមជាមួយនឹងការអធិប្បាយខ្លីៗ ដែលអាចជាប្រភពទិន្នន័យព័ត៌មានសម្រាប់អ្នកប្រើប្រាស់គ្រប់រូបភាពដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។ ទិន្នន័យនៅក្នុងសៀវភៅនេះ ត្រូវបានផលិតឡើងដំបូងបំផុតដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយមន្ទីរផែនការខេត្ត ដោយជំហានទី១ បានចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន៥ខេត្ត (ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ) ជំហានទី២ បានចំនួន៤ខេត្ត ដែលស្ថិតនៅតំបន់ឆ្នេរសមុទ្រ (ខេត្តកែប កំពត កោះកុង និងខេត្តព្រះសីហនុ) ហើយជំហានទី៣ បានចំនួន៥ខេត្ត (ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ) ឯជំហានទី៤ បានចំនួន២ខេត្ត (ខេត្តកណ្ដាល និងខេត្តតាកែវ) ចំណែកឯជំហានទី៥ បានចំនួន១ខេត្ត (ខេត្តស្វាយរៀង) រីឯជំហានទី៦ បានចំនួន១ខេត្ត (ខេត្តព្រៃវែង) និងជំហានទី៧ ឆ្នាំ២០២២នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ក៏បានបន្តចុះស្រង់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានចំនួន២ខេត្តទៀតបន្តទៀត គឺខេត្តខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ និងមន្ទីរផែនការខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំចងក្រង បោះពុម្ពនូវរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ដ៏មានសារៈសំខាន់ជាលើកទី៧ នេះឡើង។៚

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

ភ្នំពេញ កម្ពុជា
ខែមិថុនា ឆ្នាំ២០២៣

**ហង់ លីណា**

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. សេចក្តីផ្តើម

ស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងថ្មីមួយដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យស្ថិតិនៅថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះស្របតាមការធ្វើវិមជ្ឈការ និងសហវិមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋានដើម្បីយកមកវិភាគ និងចងក្រង រួមមាន៖ ស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ ដែលស្របទៅតាមភារកិច្ចរបស់នាយកដ្ឋាន និងសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រទេសកម្ពុជាបានបែងចែកជា៤តំបន់សំខាន់ៗគឺ៖ តំបន់ភ្នំ និងខ្ពង់រាប តំបន់វាលទំនាប តំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ។ យ៉ាងណាមិញ នៅជំហានទី៧ ឆ្នាំ២០២២នេះដែរ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានជ្រើសយកខេត្តចំនួនពីរ (ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ) មកបន្តអនុវត្តគម្រោងរបស់ខ្លួន។

**កំពង់ធំ** គឺជាខេត្តមួយដែលស្ថិតនៅចំកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា។ ខេត្តនេះមានផ្ទៃដីសរុបចំនួន ១៥.០៦១គីឡូម៉ែត្រការ៉េ ដោយចែកជា ៩ក្រុង/ស្រុក ៨១ឃុំ/សង្កាត់ ៧៦៧ភូមិ និងចែកសណ្ឋានដីជាពីរគឺ៖

- ***ភាគខាងជើងផ្លូវជាតិលេខ៦*** (ខាងលើផ្លូវជាតិលេខ៦)៖ ជាតំបន់ខ្ពង់រាប ដែលសមប្រកបបំផុតសម្រាប់ដំណាំចម្ការ ដូចជា កៅស៊ូ ស្វាយចន្ទី និងដំឡូងមីជាដើម។
- ***ភាគខាងលិចផ្លូវជាតិលេខ៦*** (ខាងក្រោមផ្លូវជាតិលេខ៦)៖ ជាតំបន់វាលទំនាប ដែលលាតសន្ធឹងរហូតដល់បឹងទន្លេសាប។ នៅតំបន់នេះ អាកាសធាតុផ្តល់ផលល្អសម្រាប់ដាំដំណាំរយៈពេលខ្លី ចិញ្ចឹមសត្វ និងនេសាទត្រី ដើម្បីបំពេញតម្រូវការនៅតាមខេត្តក្រុងនានា និងការនាំចេញទៅក្រៅប្រទេសជិតខាងផងដែរ។

ខេត្តកំពង់ធំមានព្រំប្រទល់៖ ខាងជើងជាប់ខេត្តស្ទឹងត្រែង ខាងត្បូងជាប់ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ខាងកើតជាប់ខេត្តក្រចេះ ខាងលិចជាប់បឹងទន្លេសាប (ខេត្តពោធិ៍សាត់) នៅភាគឦសានជាប់ខេត្តព្រះវិហារ និងនៅភាគពាយព្យជាប់ខេត្តសៀមរាប។ បើគេធ្វើដំណើរតាមផ្លូវគោកពីរាជធានីភ្នំពេញ ទៅ

ទីរួមខេត្តនេះ (ក្រុងស្ទឹងសែន) គេអាចចេញពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៦ ដោយឆ្លងកាត់ខេត្តកណ្ដាល និងខេត្តកំពង់ចាម មានចម្ងាយ ១៦៨ គីឡូម៉ែត្រ។

**ខេត្តឧត្តរមានជ័យ** ត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៦៤ តាមព្រះរាជក្រមលេខ ១៩៤ ប.រ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៦៤ នៅសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ក្រោមព្រះរាជកិច្ចដឹកនាំរបស់**សម្តេចព្រះបាទ នរោត្តម សីហនុ** ប៉ុន្តែក្រោយឆ្នាំ១៩៧០ សង្គ្រាមបានឆាបឆេះឡើង រាល់រចនាសម្ព័ន្ធរដ្ឋបាលត្រូវបានលើកទីតាំងមកដាក់នៅខេត្តសៀមរាប។ ខេត្តនេះត្រូវរួមបញ្ចូលគ្នាជាមួយខេត្តសៀមរាបនៅសម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យខ្មែរក្រហម ដែលជាតំបន់ស្វយ័តដាច់ដោយឡែក (ភូមិភាគពិសេស)។ នៅទសវត្សរ៍ឆ្នាំ៨០-៩០ ខេត្តនេះ គឺជាទីតាំងភូមិសាស្ត្ររបស់ពួកខ្មែរក្រហម ជាពិសេសគឺស្រុកអន្លង់វែង។ យោងព្រះរាជក្រឹត្យលេខ នស/រកត/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ខេត្តនេះត្រូវបានបង្កើតឡើងសារជាថ្មី ដោយផ្តាច់ចេញពីខេត្តសៀមរាប។ នៅពេលនោះ រាល់រចនាសម្ព័ន្ធពុំទាន់ដំណើរការនៅឡើយ លុះដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្ថិតក្រោមអធិបតីភាព **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានប្រកាសដាក់ឲ្យដំណើរការការងាររដ្ឋបាលជាផ្លូវការ។ ខេត្តឧត្តរមានជ័យគឺជាខេត្តចុងក្រោយគេបង្អស់នៅទូទាំងប្រទេសដែលបានសម្រេចធ្វើសមាហរណកម្មបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៨ ក្រោមយុទ្ធសាស្ត្រនយោបាយ "ឈ្នះ-ឈ្នះ" របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបញ្ចប់សង្គ្រាមផ្ទៃក្នុងទាំងស្រុងចេញពីប្រទេសកម្ពុជា។ បច្ចុប្បន្នខេត្តនេះមានផ្ទៃដីសរុប ៦.៨៤០,៩១គីឡូម៉ែត្រការ៉េ ដោយចែកជា ៥ក្រុង/ស្រុក ២៤ឃុំ/សង្កាត់ និង ៣០៤ភូមិ។ ទីតាំងភូមិសាស្ត្រស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់៖ ខាងជើងជាប់នឹងប្រទេសថៃ (ខ្មែរលើ) គឺខេត្តបុរីរ៉ាំ សុរិន្ទ និងខេត្តស៊ីសាកេត មានប្រវែង ២២៤គីឡូម៉ែត្រ ខណ្ឌចែកដោយភ្នំដងរែក (គ្មានដីវាលរាបទេជាមួយប្រទេសថៃ គឺសុទ្ធតែភ្នំ ហើយមានច្រក៣សម្រាប់ចេញចូលគឺ៖ ច្រកជុបគគី ច្រកអូស្មាច់ និងច្រកជាំសាង៉ាម) ខាងត្បូងជាប់ខេត្តសៀមរាប ខាងកើតជាប់ខេត្តព្រះវិហារ និងខាងលិចជាប់ខេត្តបន្ទាយមានជ័យ។

បើគេធ្វើដំណើរតាមផ្លូវគោកពីរាជធានីភ្នំពេញ ទៅទីរួមខេត្តនេះ (ក្រុងសំរោង) គេអាចធ្វើដំណើរតាមផ្លូវដូចខាងក្រោម៖

- **ផ្លូវជាតិលេខ៥៖** ចេញពីរាជធានីភ្នំពេញ ដោយឆ្លងកាត់ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានចម្ងាយប្រមាណជា ៤៦៩គីឡូម៉ែត្រ។
- **ផ្លូវជាតិលេខ៦៖** ចេញពីរាជធានីភ្នំពេញ ដោយឆ្លងកាត់ខេត្តកណ្តាល កំពង់ចាម កំពង់ធំ និងខេត្តសៀមរាប ដែលមានចម្ងាយប្រមាណជា ៤៤៧គីឡូម៉ែត្រ។

### ១.១.១. និមិត្តសញ្ញាខេត្ត

#### ក. ខេត្តកំពង់ធំ




ការប្រើប្រាស់នូវនិមិត្តសញ្ញាសម្គាល់នេះ គឺយោងទៅតាមប្រកាសលេខ ២១០៧ ប្រក. ចុះថ្ងៃចន្ទ ១២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ស្តីពី ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកំពង់ធំ។

#### អត្ថន័យនិមិត្តសញ្ញា៖

- **ប្រាសាទយាយព័ន្ធ៖** តំណាងឱ្យភាពរុងរឿងនៃស្ថាបត្យកម្មខ្មែរនាសតវត្សរ៍ទី៧ដែលមាននៅក្នុងតំបន់ប្រាសាទសំបូរព្រៃគុក នាទឹកដីខេត្តកំពង់ធំ និងតំណាងឱ្យជំនឿរបស់ខ្មែរបុរាណក្នុងការគោរពព្រហ្មញ្ញសាសនា។

- **រូបបដិមាគោះ** តំណាងឱ្យភាពអស្ចារ្យនៃសិល្បៈខ្មែរនាចុងសម័យចេនឡាក្នុងតំបន់ប្រាសាទសំបូរព្រៃគុក និងតំណាងឱ្យអំណាច អានុភាពខ្លាំងក្លា។
- **រូបដំរីជាន់ខ្លា៖** តំណាងឱ្យរូបសំណាកដែលមាននៅខេត្តកំពង់ធំ តាំងពីអំឡុងសតវត្សរ៍ទី៦០ ហើយឆ្លុះបញ្ចាំងពីគចភាពធនធានធម្មជាតិនៃខេត្តកំពង់ធំ។
- **កួរស្រូវ៖** តំណាងឱ្យភាពសម្បូរសប្បាយ និងភាពរុងរឿងនៃវិស័យកសិកម្ម ពិសេសគឺភោគផលនៃដំណាំស្រូវ។
- **ដើមឈើ៖** តំណាងឱ្យភាពរីកចម្រើនលើវិស័យកសិឧស្សាហកម្ម ដែលខេត្តកំពង់ធំសម្បូរដោយដីមានជីជាតិអំណោយផលដល់ដំណាំកសិកម្ម និងកសិឧស្សាហកម្ម។

### ខ. ខេត្តឧត្តរមានជ័យ




ការប្រើប្រាស់នូវនិមិត្តសញ្ញាសម្គាល់នេះ គឺយោងទៅតាមប្រកាសលេខ ២០៣៨ ប្រក. ចុះថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្ដីពី ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តឧត្តរមានជ័យ។

## អត្ថន័យនិមិត្តសញ្ញា៖

- **ព្រះលោកេស្វរៈ៖** ជាអវតារព្រះវិស្ណុ តំណាងឱ្យសេចក្តីសុខ ការបង្រួបបង្រួមសាសនា គ្មានជំលោះសាសនា ឬជំលោះផ្សេងៗកើតឡើង មានព្រះវិស្ណុនៅទីណា ទីនោះនឹងមានសេចក្តីសុខយ៉ាងបរិបូរណ៍។
- **កងចក្រ៖** តំណាងឱ្យរដ្ឋបាលគ្រប់គ្រងដែនដី អំណាចគ្រប់គ្រងដ៏មានបារមី កំចាត់អំពើអាក្រក់។
- **គម្ពីរវេទ៖** តំណាងឱ្យការប្រកាន់គោលច្បាប់ជាធំ ពិសេសច្បាប់រដ្ឋធម្មនុញ្ញដែលជាច្បាប់គោល។
- **ដំបងមោងកសៈ៖** តំណាងឱ្យវិស័យការពារជាតិ មានកងកម្លាំងប្រដាប់អាវុធដ៏រឹងមាំរបស់ជាតិ។
- **ព្រះពុទ្ធ៖** តំណាងឱ្យការគោរពព្រះពុទ្ធសាសនា ដែលជាសាសនាតែមួយរបស់ជាតិ។
- **តុមកំបោរ ឬ ថូទឹក៖** តំណាងឱ្យវិស័យសុខាភិបាល មានការព្យាបាលដ៏ស័ក្តិសិទ្ធិនាំឱ្យចាកផុតពីទុក្ខទាំងពួង។
- **ផែនដី៖** តំណាងឱ្យវិស័យបរិស្ថាន ដែលផ្តល់នូវភាពអនុគ្រោះគ្រប់យ៉ាងដល់ជីវិតរស់នៅ។
- **ផ្កាឈូក៖** តំណាងឱ្យវិស័យអប់រំ សិក្សាធិការ ការបណ្តុះបណ្តាលធនធានមនុស្សល្អសម្រាប់សង្គម។
- **ខ្យងស័ង្ខ៖** តំណាងឱ្យប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់ ឥតខ្ចោះរបស់ជនជាតិខ្មែរ។

## ១.១.២. ផែនទីខេត្ត

### ក. ខេត្តកំពង់ធំ




### ខ. ខេត្តឧត្តរមានជ័យ



### ១.១.៣. ផែនទីអនុវត្តគម្រោង




## ១.២. គោលបំណង

គោលបំណងសំខាន់ៗនៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺដើម្បីផ្តល់នូវទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការ៖

១. សម្រាប់ធ្វើគោលនយោបាយអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ

២. សម្រាប់ប្រើប្រាស់ក្នុងវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ

៣. សម្រាប់តម្រូវការអ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត បណ្តាអង្គការជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋ និងវិស័យឯកជនជាច្រើនទៀត។

នៅក្នុងជំពូកបន្ទាប់ មានបង្ហាញយ៉ាងលម្អិតនូវទិន្នន័យជាច្រើនដែលទាក់ទងទៅនឹងព័ត៌មានប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងផ្នែកកសិកម្ម។ ក្រៅពីការបោះពុម្ពផ្សាយចេញនូវសៀវភៅ "របាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តឆ្នាំ២០២២" នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិក៏មានការផ្សព្វផ្សាយដោយបើកចំហនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដែលមានអាសយដ្ឋាន *https://www.nis.gov.kh* ផងដែរ។

## ១.៣. វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺត្រូវបានធ្វើឡើងដោយការសម្ភាសទល់មុខ (Face to Face) និងប្រើប្រាស់ម៉ាស៊ីនថេប្លេត តាមរយៈកម្មវិធីឌីជីថល (Kobo Toolbox)។ កម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិនេះ ត្រូវបានចុះសម្ភាសន៍គ្រប់ភូមិដែលមាននៅក្នុងខេត្តជាមួយមេភូមិទាំងអស់រយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី៧ ដល់ទី២១ ខែមីនា ឆ្នាំ២០២២ ដោយមន្ត្រីនៃមន្ទីរផែនការខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ ក្រោយពីទទួលបានការបណ្តុះបណ្តាលយ៉ាងលម្អិត និងច្បាស់លាស់រួចមក។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកសម្របសម្រួលផ្នែកបច្ចេកទេស តាំងពីចាប់ផ្តើមដំណើរការ រហូតដល់ការប្រមូលទិន្នន័យត្រូវបានបញ្ចប់ដោយជោគជ័យ១០០ភាគរយ។ ចំណែកកាលបរិច្ឆេទយោងនៃការប្រមូលទិន្នន័យនេះ គឺយករយៈពេល១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២។

## ១.៤. ការផលិតទិន្នន័យ

ការផលិតទិន្នន័យ គឺត្រូវបានធ្វើឡើងដោយការទាញយកទិន្នន័យពីកម្មវិធី Kobo Toolbox បំប្លែងទៅជា Microsoft Excel ដើម្បីបង្កើតជាតារាង សង់ជាក្រាហ្វិក និងវិភាគទិន្នន័យ មុននឹងឈានដល់ការបកស្រាយទិន្នន័យក្នុងកម្មវិធី Microsoft Word។ ដំណើរការផលិត និងវិភាគទិន្នន័យមានរយៈពេល៣ខែ គឺចាប់ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

# ជំពូកទី២

# វិភាគទិន្នន័យ

## ២.១. ព័ត៌មានប្រជាសាស្ត្រ

### ២.១.១. ព័ត៌មានគ្រួសារ

**គ្រួសារ** គឺជាមនុស្សមួយក្រុមដែលរស់នៅរួមគ្នា និងបរិភោគអាហារចេញពីចង្ក្រានតែមួយ វៀរលែងតែអ្នកដែលមានការងារពិសេសមិនអាចទៅហូបចុកជាមួយបាន។

**មេគ្រួសារ** គឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងគ្រួសារ។ មេគ្រួសារអាចជាបុរស ឬស្ត្រី ដែលជាទូទៅគាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាមឱ្យគ្រួសារ។ មេគ្រសារ មិនចាំបាច់ត្រូវតែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាស្ត្រី ក្មេងស្រី ឬក្មេងប្រុស នៃសមាជិកគ្រួសារ។

*តារាងទី១៖ ចំនួន និងប្រភេទមេគ្រួសារ*

| ប្រភេទមេគ្រួសារ | ខេត្ត | |
|---|---|---|
| | កំពង់ធំ | ឧត្តរមានជ័យ |
| បុរស | ១៥៨.២៤៨ | ៥៥.០២៨ |
| ស្ត្រី | ២៥.១១៦ | ៥.៦០០ |
| **សរុប** | **១៨៣.៣៦៤** | **៦០.៦២៨** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

តារាងទី១ គឺជាចំនួន និងប្រភេទមេគ្រួសារនៅក្នុងខេត្តគោលដៅ។ យើងឃើញថា ខេត្តកំពង់ធំមានចំនួន ១៨៣.៣៦៤គ្រួសារ ក្នុងនោះមានស្ត្រីជាមេគ្រួសារ ២៥.១១៦គ្រួសារ ស្មើនឹង ១៤%) ឯខេត្តឧត្តរមានជ័យមាន ៦០.៦២៨គ្រួសារ (ស្ត្រីជាមេគ្រួសារ ៥.៦០០គ្រួសារ ស្មើនឹង ៩%)។

*រូបភាពទី១៖ ភាគរយស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំនៅជាមួយ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

រូបភាពទី១ បានបង្ហាញពីភាគរយស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំរស់នៅជាមួយ។ ក្នុងចំណោមស្ត្រីជាមេគ្រួសារនៅក្នុងខេត្តទាំងពីរ យើងឃើញថា ខេត្តកំពង់ធំ មាន ១៣% (៣.៣៥៤ គ្រួសារ) និងខេត្តឧត្តរមានជ័យមាន ១០% (៥៨៦គ្រួសារ) មានកុមារអាយុក្រោម៥ឆ្នាំស្នាក់នៅ និងកំពុងរស់នៅជាមួយ។

## ២.១.២. ព័ត៌មានប្រជាជន

**ប្រជាជន** គឺសំដៅដល់មនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ ដែលរស់នៅ ឬធ្វើការក្នុងប្រទេសណាមួយជាក់លាក់។

### ក. ចំនួនប្រជាជន

*តារាងទី២៖ ចំនួនប្រជាជននៅតាមជនជាតិ*

| ជនជាតិ | កំពង់ធំ | | | ឧត្តរមានជ័យ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ខ្មែរ | ៨០៧.៤៣៨ | ៣៩៦.៧៩៨ | ៤១០.៦៤០ | ២៧៨.៥០៩ | ១៣៨.៩៨៧ | ១៣៩.៥២២ |
| ចិន | ៦ | ៦ | ០ | ០ | ០ | ០ |
| ថៃ | ៤ | ៤ | ០ | ៦ | ៦ | ០ |
| ឡាវ | ២ | ០ | ២ | ៤ | ០ | ៤ |
| វៀតណាម | ១.៤៨៨ | ៧៤៨ | ៧៤០ | ២៤ | ១៦ | ៨ |
| ខ្មែរឥស្លាម | ៨.៦៤៨ | ៤.៣១៤ | ៤.៣៣៤ | ២៣៨ | ១១៨ | ១២០ |
| កូរ៉េ | ៤ | ២ | ២ | ០ | ០ | ០ |
| ជនជាតិដើមភាគតិច | ៦.៧៤២ | ៣.២៨៤ | ៣.៤៥៨ | ១០៦ | ៤៨ | ៥៨ |
| ជនជាតិបរទេសផ្សេងៗទៀត | ២ | ២ | ០ | ២ | ២ | ០ |
| **សរុបរួម** | **៨២៤.៣៣៤** | **៤០៥.១៥៨** | **៤១៩.១៧៦** | **២៧៨.៨៨៩** | **១៣៩.១៧៧** | **១៣៩.៧១២** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

តារាងទី២ បានបង្ហាញថា ខេត្តកំពង់ធំ មានប្រជាជនសរុប ៨២៤.៣៣៤នាក់ (ស្រី ៤១៩.១៧៦ នាក់ ស្មើនឹង ៥០,៨៥%) ក្នុងនោះភាគច្រើនជាជនជាតិខ្មែរ (៩៧,៩៥%) បន្ទាប់មកគឺជនជាតិខ្មែរឥស្លាម (១,០៥%) ជនជាតិដើមភាគតិច (០,៨២%) ខណៈដែលជនជាតិវៀតណាមមាន ០,១៨%។ ខេត្តឧត្តរមានជ័យ មានប្រជាជនសរុប ២៧៨.៨៨៩នាក់ (ស្រី ១៣៩.៧១២នាក់ ស្មើនឹង ៥០,១០%) ក្នុងនោះភាគច្រើនជាជនជាតិខ្មែរ (៩៨,៨៦%) បន្ទាប់មកគឺជនជាតិខ្មែរឥស្លាម (០,០៩%) ជនជាតិដើមភាគតិច (០,០៤%) ខណៈដែលជនជាតិវៀតណាមមាន ០,០១%។

## ខ. ស្ថានភាពអាពាហ៍ពិពាហ៍

*តារាងទី៣៖ ភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍តាមគ្រួសារ*

| ស្ថានភាពអាពាហ៍ពិពាហ៍ | ខេត្ត | |
|---|---|---|
| | កំពង់ធំ | ឧត្តរមានជ័យ |
| គ្រួសារដែលបានរៀបការ និងកំពុងរស់នៅជាមួយគ្នា | ៨០,៧៤ | ៨៩,៣១ |
| គ្រួសារមេម៉ាយ/ពោះម៉ាយ | ១៣,៨១ | ៨,៦៩ |
| គ្រួសារដែលរស់នៅផ្សេងគ្នា | ២,៨២ | ០,៦៩ |
| គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការ | ១,៦២ | ០,៩៨ |
| គ្រួសារមិនដែលរៀបការ | ១,០១ | ០,៣៣ |
| **សរុប** | **១០០** | **១០០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

តារាងទី៣ បានបង្ហាញពីភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍តាមគ្រួសារ។ យើងឃើញថា ក្នុងគ្រួសារសរុបទាំង ១៨៣.៣៦៤គ្រួសារ នៃខេត្តកំពង់ធំ គ្រួសារដែលបានរៀបការ និងកំពុងរស់នៅជាមួយគ្នាមានភាគរយខ្ពស់ជាងគេ គឺ ៨០,៧៤% បន្ទាប់មក គឺគ្រួសារមេម៉ាយ/ពោះម៉ាយ មាន ១៣,៨១% បន្ទាប់មកទៀត គឺគ្រួសារដែលរស់នៅផ្សេងគ្នា ២,៨២% គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការ ១,៦២% និងគ្រួសារមិនដែលរៀបការមាន ១,០១%។ ខេត្តឧត្តរមានជ័យ មានគ្រួសារសរុបចំនួន ៦០.៦២៨គ្រួសារ ក្នុងនោះគ្រួសារដែលបានរៀបការ និងកំពុងរស់នៅជាមួយគ្នាមានចំនួន ៨៩,៣១% បន្ទាប់មកគឺគ្រួសារមេម៉ាយ/ពោះម៉ាយមាន ៨,៦៩% គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការ ០,៩៨% គ្រួសារដែលរស់នៅផ្សេងគ្នាមាន ០,៦៩% និងចុងក្រោយគឺគ្រួសារគ្រួសារមិនដែលរៀបការមាន ០,៣៣%។

### ២.១.៣. ការផ្លាស់ប្តូរទីលំនៅ

**ការផ្លាស់ប្តូរទីលំនៅ** គឺជាចលនាផ្លាស់ប្តូរទីកន្លែងរស់នៅរបស់មនុស្សពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ ជាទូទៅ គេចាត់ទុកចលនាបំលាស់លំនៅជាបាតុភូតសកល ពីព្រោះចលនានេះតែងតែកើតមានឡើងនៅគ្រប់ប្រទេសទាំងអស់ មិនថាប្រទេសអ្នកមាន ឬប្រទេសអ្នកក្រនោះទេ។ កត្តាចម្បងដែលនាំឱ្យមានការបញ្ហានេះ គឺដោយសារវិបត្តិសេដ្ឋកិច្ច តម្លៃទំនិញឡើងថ្លៃ ការប្តូរកន្លែងធ្វើការ ការស្វែងរកការងារធ្វើ អសន្តិសុខ ការវិលជួបជុំគ្រួសារ កូនកំព្រា និងការបាត់បង់ដីធ្លី ឬលំនៅឋាន។ នៅកម្ពុជាបច្ចុប្បន្ន គេចែកបំលាស់លំនៅជាបួនរូបភាព គឺបំលាស់លំនៅពីជនបទទៅទីក្រុង បំលាស់លំនៅពីជនបទទៅជនបទ បំលាស់លំនៅពីទីក្រុងទៅទីក្រុង និងបំលាស់លំនៅពីទីក្រុងទៅជនបទ។ មួយរយៈចុងក្រោយនេះ គេសង្កេតឃើញមានការផ្លាស់លំនៅពីជនបទទៅជនបទច្រើន ដោយសារកំណើននៃសេដ្ឋកិច្ច ជាពិសេសគឺតម្លៃដីធ្លីឡើងថ្លៃ ដែលធ្វើឲ្យប្រជាជនធ្វើការលក់ដូរដីពីកន្លែងដែលដីមានតម្លៃថ្លៃ ទៅរស់នៅកន្លែងមួយទៀត។ រូបភាពបំលាស់លំនៅ ពីជនបទទៅទីក្រុង ជារូបភាពដែលបណ្តាលឲ្យមានបញ្ហានគរូនីយកម្ម និងបង្កឲ្យមានចំណោទលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ថែមទៀតផង។

#### ក. ចំនួនអ្នកចំណាកស្រុក និងចំណូលស្រុក

**ចំណាកស្រុក និងចំណូលស្រុក** គឺជាការផ្លាស់ទីចេញ ឬចូលមករស់នៅក្នុងភូមិជាក់លាក់ណាមួយចាប់ពីរយៈពេល៦ខែឡើងទៅ។

*រូបភាពទី២៖ ភាគរយប្រជាជនចំណាកស្រុក និងចំណូលស្រុក*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

រូបភាពទី២ បានបង្ហាញពីចំនួនភាគរយនៃប្រជាជនធ្វើចំណាកស្រុក និងចំណូលស្រុក ដែលមានទំនាក់ទំនងទៅនឹងកត្តាសេដ្ឋកិច្ច និងសង្គម។ ខេត្តកំពង់ធំ មានប្រជាជនធ្វើចំណាកស្រុក ៩,៤% និងចំណូលស្រុក ០,៥% នៃប្រជាជនសរុប ៨២៤.៣៣៤នាក់។ ដោយឡែកខេត្តឧត្តរមានជ័យវិញ ប្រជាជនចំណាកស្រុកមាន ៧,០% និងប្រជាជនចំណូលស្រុកមាន ០,៨% នៃប្រជាជនសរុប ២៧៨.៨៨៩នាក់។

## ខ. ភេទនៃអ្នកចំណាកស្រុក និងចំណូលស្រុក

*រូបភាពទី៣៖ ភាគរយប្រជាជនចំណាកស្រុក និងចំណូលស្រុកបែងចែកតាមភេទ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តាមរូបភាពទី៣ បានបង្ហាញថា៖ ខេត្តកំពង់ធំ មានប្រជាជនចំណាកស្រុក ៧៧.៧៩០នាក់ (៤៩% ជាមនុស្សស្រី) ប្រជាជនចំណូលស្រុកមាន ៤.៣៣០នាក់ (៤៦% ជាមនុស្សស្រី) រីឯខេត្តឧត្តរមានជ័យមានប្រជាជនចំណាកស្រុក ៧៧.៧៩០នាក់ (៤៤% ជាមនុស្សស្រី) ប្រជាជនចំណូលស្រុកមាន ២.១៦៨នាក់ (៥២% ជាមនុស្សស្រី)។

## គ. មូលហេតុចំណាកស្រុក




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

រូបភាពទី៤ បង្ហាញពីមូលហេតុចម្បងនៃការធ្វើចំណាកស្រុករបស់ប្រជានជនក្នុងតំបន់ ឬពីខេត្តមួយទៅខេត្តមួយនៃប្រទេសកម្ពុជា ដោយផ្អែកលើកត្តាចំបាច់មួយចំនួនដែលជាតម្រូវការរបស់ពួកគាត់។ ខេត្តកំពង់ធំ កត់សម្គាល់ឃើញថា អត្រាប្រជាជនធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើមានរហូតដល់ទៅ ៨៩% ខណៈដែលការបន្តការសិក្សា និងមូលហេតុផ្សេងទៀតមានតែ ១១% ប៉ុណ្ណោះ។ ចំណែកខេត្តឧត្តរមានជ័យវិញ អត្រាអ្នកចំណាក ស្រុកដើម្បីស្វែងរកការងារធ្វើខ្ពស់ជាងខេត្តកំពង់ធំ ១% ខណៈដែលបន្តការសិក្សាមាន ៩% និងអ្នកចំណាកស្រុកដោយមូលហេតុផ្សេងទៀតមាន ១%។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

រូបភាពទី៥ យើងកត់សម្គាល់ឃើញថាៈ ខេត្តកំពង់ធំ ការធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើនៅក្រៅប្រទេសមានរហូតដល់ ៩៧% ខណៈដែលអ្នកចំណាកស្រុកទៅបន្តការសិក្សាមាន ៣% រីឯខេត្តឧត្តរមានជ័យ អ្នកចំណាកស្រុកដើម្បីស្វែងរកការងារធ្វើក្រៅប្រទេសគឺមិនខុសគ្នាពីខេត្តកំពង់ធំឡើយ ប្លែកតែមូលហេតុផ្សេងៗទៀត (ក្រៅពីស្វែងរកការងារធ្វើ និងបន្តការសិក្សា) មានរហូតដល់ ៣% នៃប្រជាជនចំណាកស្រុកក្រៅប្រទេសទាំងអស់។

## ២.១.៤. លំនៅឋាន

គោលបំណងសំខាន់នៅក្នុងផ្នែកនេះ គឺដើម្បីបង្ហាញនូវទិន្នន័យស្ថិតិអំពីលំនៅឋានរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទាំងពីរ។ នៅឆ្នាំ២០២២ ខេត្តកំពង់ធំមានគ្រួសារសរុបចំនួន ១៨៣.៣៦៤ គ្រួសារ និងខេត្តឧត្តរមានជ័យមាន ៦០.៦២៨គ្រួសារ នោះចំនួនខ្នងផ្ទះអាចស្មើ ឬតិចជាងនេះ ដោយសារតែមានគ្រួសារមួយចំនួនរៀបការរួច ពុំទាន់មានលទ្ធភាពសាងសង់ផ្ទះសម្រាប់ស្នាក់នៅផ្ទាល់ខ្លួន ទើបទៅស្នាក់អាស្រ័យជាមួយផ្ទះឪពុកម្ដាយ ឬបងប្អូនជាដើម។ សម្ភារៈប្រើប្រាស់សម្រាប់ធ្វើជាដំបូលផ្ទះ វាមានសារៈសំខាន់ណាស់ចំពោះការកំណត់នូវចរិតលក្ខណៈនៃគុណភាពរបស់លំនៅឋានដែលរួមមានដូចជា បេតុង ក្បឿង ហ្វីប្រូស៊ីម៉ង់ត៍ ស័ង្កសី ស្លឹក និងវត្ថុផ្សេងៗទៀត។

### ក. ប្រភេទដំបូលផ្ទះ

*តារាងទី៤៖ ចំនួនខ្នងផ្ទះតាមប្រភេទដំបូល*

| ប្រភេទដំបូល | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បេតុង | ៣.៩៨០ | ២,៤ | ១៦២ | ០,៣ |
| ក្បឿង | ៩៨.០២៦ | ៥៨,៨ | ១៣.៦៤៦ | ២៥,៤ |
| ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ | ៥៩.៩៧០ | ៣៦,០ | ៣៨.១២៦ | ៧១,១ |
| ស្លឹក | ៣.៨៤៦ | ២,៣ | ១.៥១០ | ២,៨ |
| ផ្សេងៗ | ៩៧៤ | ០,៥ | ១៨៨ | ០,៤ |
| **សរុប** | **១៦៦.៧៩៦** | **១០០** | **៥៣.៦៣២** | **១០០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២២*

តារាងទី៤ បានបង្ហាញពីចំនួនខ្នងផ្ទះរបស់ប្រជាពលរដ្ឋទៅតាមប្រភេទដំបូល។ យើងឃើញថា នៅក្នុងខេត្តកំពង់ធំមានចំនួនខ្នងផ្ទះសរុប ១៦៦.៧៩៦ខ្នង ក្នុងនោះខ្នងផ្ទះភាគច្រើនរហូតដល់ ៩៨.០២៦ខ្នង (៥៨,៨%) គឺមានដំបូលប្រក់ក្បឿង បន្ទាប់មក គឺផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍មានចំនួន ៥៩.៩៧០ខ្នង (៣៦,០%) ខណៈដែលផ្ទះដំបូលបេតុងនិងស្លឹកមាន ៧.៨២៦ខ្នង (៤,៧%) ក្រៅពីនេះ ក៏នៅមានខ្នងផ្ទះមួយចំនួនទៀតដែលមានដំបូលប្រក់ពីសម្ភារៈផ្សេងៗចំនួន ៩៧៤ខ្នង (០,៥%) ផងដែរ។ ខេត្តឧត្តរមានជ័យមានចំនួនខ្នងផ្ទះសរុប ៥៣.៦៣២ខ្នង ក្នុងនោះខ្នងផ្ទះភាគច្រើនគឺមានដំបូលប្រក់ពីស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍រហូតដល់ ៣៨.១២៦ខ្នង (៧១,១%) បន្ទាប់មក គឺខ្នងផ្ទះដំបូលប្រក់ក្បឿងមានចំនួន ១៣.៦៤៦ខ្នង (២៥,៤%) ខណៈដែលផ្ទះដំបូលបេតុងនិងស្លឹកមាន ១.៦៧២ខ្នង (៣,១%) ក្រៅពីនេះ ក៏នៅមានខ្នងផ្ទះមួយចំនួនទៀតដែលមានដំបូលប្រក់ពីសម្ភារៈផ្សេងៗចំនួន ១៨៨ ខ្នង (០,៤%) ផងដែរ។

## ខ. ការប្រើប្រាស់បណ្តាញអគ្គិសនី

អគ្គិសនី គឺសំដៅលើប្រភពថាមពលដែលនាំឱ្យមានភ្លើងសម្រាប់ប្រើប្រាស់។ បណ្តាញ គឺជាការភ្ជាប់ពីទីតាំងមេ ដោយតជាសេរី ឬជាខ្សែ ដើម្បីចែកចាយបន្តទៅអ្នកប្រើប្រាស់ជាច្រើន។ បណ្តាញអគ្គិសនី វាអាចជាកម្មសិទ្ធិរបស់រដ្ឋ ឬជារបស់ឯកជន។

*រូបភាពទី៦៖ ភាគរយនៃខ្នងផ្ទះដែលមានអគ្គិសនីប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៦ គឺជាភាគរយនៃខ្នងផ្ទះដែលមានបណ្តាញអគ្គិសនីប្រើប្រាស់។ តាមរូបភាពនេះបានបញ្ជាក់ថា ខេត្តកំពង់ធំ មានបណ្តាញភ្លើងអគ្គិសនីបានលាតសណ្តឹង និងគ្របដណ្តប់ (៨៧,៤%) ស្ទើរតែពាសពេញផ្ទៃខេត្តទាំងមូល។ ក្នុងនោះដែរយើងសង្កេតឃើញថា ក្នុងចំណោមខ្នងផ្ទះទាំងអស់ ភាគច្រើនខ្នងផ្ទះដែលមានដំបូលបេតុងគឺមានលទ្ធភាព និងកំពុងប្រើប្រាស់ភ្លើងអគ្គិសនីរហូតដល់ ៩៧,៩% ខុសពីខ្នងផ្ទះដំបូលប្រក់ស្លឹក ឬសម្ភារៈផ្សេងៗដែលមានតែ ៥១,៦% នៃចំនួនខ្នងផ្ទះសរុប។ ចំពោះខេត្តឧត្តរមានជ័យវិញ បណ្តាញភ្លើងអគ្គិសនីបានលាតសណ្តឹង និងគ្របដណ្តប់លើផ្ទះប្រជាពលរដ្ឋ ៦៦,២% ដែលភាគច្រើនទៅលើខ្នងផ្ទះដែលមានដំបូលបេតុង (៩៨,៨%) ខណៈដែលខ្នងផ្ទះដំបូលប្រក់ស្លឹក ឬសម្ភារៈផ្សេងៗមានតែ ២៩,០% ប៉ុណ្ណោះ។

## គ. ការប្រើប្រាស់ទូរទស្សន៍

ទូរទស្សន៍ គឺជាឧបករណ៍កម្សាន្តអារម្មណ៍ ផ្តល់ចំណេះដឹង និងជាប្រព័ន្ធផ្សព្វផ្សាយដ៏សំខាន់មួយក្នុងការបញ្ជូនព័ត៌មានគ្រប់បែបយ៉ាងទៅកាន់អ្នកទស្សនា។ អាគុយ ម៉ាស៊ីនភ្លើង សូឡា និងថាមពលមួយចំនួនទៀតក៏ត្រូវបានប្រើប្រាស់ផងដែរ ក្រៅពីបណ្តាញអគ្គិសនី។ នៅពេលប្រជាពលរដ្ឋមានប្រភពថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ ពួកគាត់ភាគច្រើនអាចមានលទ្ធភាពក្នុងការប្រើប្រាស់ទូរទស្សន៍ដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួន ក្រុមគ្រួសារ និងញាតិមិត្តជិតខាង។

*រូបភាពទី៧៖ ភាគរយនៃខ្នងផ្ទះដែលមានទូរទស្សន៍ប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៧ សបញ្ជាក់ឱ្យឃើញថា នៅពេលបច្ចេកទេសកាន់តែទំនើប និងរីកចម្រើន អត្រានៃអ្នកប្រើប្រាស់ទូរទស្សន៍ (មើល) គឺកាន់តែថយចុះ ដោយភាគច្រើនពួកគេទាំងនោះ បានបង្វែរពីការមើលទូរទស្សន៍ទៅប្រើប្រាស់ទូរសព្ទ ថេប្លេត ឬកុំព្យូទ័រមកជំនួសជាដើម។ ជាក់ស្តែង ខេត្តកំពង់ធំ ខ្នងផ្ទះដែលប្រើប្រាស់ទូរទស្សន៍ (មើល) មាន ៥២,៧% ខណៈដែលខេត្តឧត្តរមានជ័យមាន ៣៥,៨% បើធៀបទៅនឹងចំនួនខ្នងផ្ទះសរុបដែលមាននៅទូទាំងខេត្តទាំងនេះ។

## ឃ. ការប្រើប្រាស់កុំព្យូទ័រ

កុំព្យូទ័រ គឺជាឧបករណ៍មួយសម្រាប់ជំនួយ និងពន្លឿនការងារក្នុងសម័យទំនើប។




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៨ បានបង្ហាញឱ្យឃើញថា នៅក្នុងខេត្តទាំងពីរ គឺមានអ្នកចេះ និងមានកុំព្យូទ័រប្រើប្រាស់ប្រហាក់ប្រហែលគ្នា។ ជាក់ស្តែង ខេត្តកំពង់ធំ មាន ២,៤% ស្មើនឹង ៤.០០២ខ្នងផ្ទះ រីឯខេត្តឧត្តរមានជ័យមាន ២,១% ស្មើនឹង ១.១២០ខ្នងផ្ទះ ដែលមាន និងកំពុងប្រើប្រាស់កុំព្យូទ័រ ហើយភាគច្រើននៃខ្នងផ្ទះទាំងនោះ គឺជាប្រភេទផ្ទះដំបូលបេតុង។

## ង. ការប្រើប្រាស់អ៊ីនធឺណែត

អ៊ីនធឺណែត គឺជាប្រព័ន្ធទូរគមនាគមន៍សម្រាប់ប្រើប្រាស់ជាមួយកុំព្យូទ័រ ថេប្លេត ទូរសព្ទដៃ និងរបស់របរប្រើប្រាស់មួយចំនួនទៀត។ នៅក្នុងផ្នែកការប្រើប្រាស់អ៊ីនធឺណែតនៃរបាយការណ៍នេះ គឺគ្រាន់តែចង់សំដៅដល់លទ្ធភាព និងទីតាំងភូមិសាស្ត្រ ដែលខ្នងផ្ទះនីមួយៗអាចភ្ជាប់ ឬប្រើប្រាស់អ៊ីនធឺណែតបានតែប៉ុណ្ណោះ។

*រូបភាពទី៩៖ ភាគរយនៃខ្នងផ្ទះដែលមានអ៊ីនធឺណែតប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៩ បានបង្ហាញពីភាគរយនៃខ្នងផ្ទះដែលមានអ៊ីនធឺណែតប្រើប្រាស់។ យើងឃើញថា បណ្តាគ្រប់ទីតាំងខ្នងផ្ទះទាំងអស់នៃខេត្តកំពង់ធំ ខ្នងផ្ទះដំបូលបេតុង ៨៦,៧% ផ្ទះដំបូលក្បឿង ៨៣,៧% ផ្ទះដំបូលស័ង្កសី/ហ្វីប្រូស៊ីម៉ងត៍ ៨១,២% និងខ្នងផ្ទះដំបូលប្រក់ស្លឹក/សម្ភារៈផ្សេងៗទៀតមានចំនួន ៥៣,៩% ខណៈដែល ៨២,០% នៃចំនួនខ្នងផ្ទះសរុបក្នុងខេត្តនេះអាចមានលទ្ធភាពភ្ជាប់ និងកំពុងប្រើប្រាស់អ៊ីនធឺណែត។ ខេត្តឧត្តរមានជ័យ ខ្នងផ្ទះដំបូលបេតុង ៩៨,៨% ផ្ទះដំបូលក្បឿង ៩២,៣% ផ្ទះដំបូលស័ង្កសី/ហ្វីប្រូស៊ីម៉ងត៍ ៨៩,៤% និងខ្នងផ្ទះដំបូលប្រក់ស្លឹក/សម្ភារៈផ្សេងៗទៀតមានចំនួន ៨៣,៩% ខណៈដែល ៩០,០% នៃចំនួនខ្នងផ្ទះសរុបក្នុងខេត្តនេះអាចមានលទ្ធភាពភ្ជាប់ និងកំពុងប្រើប្រាស់អ៊ីនធឺណែត។

## ច. ការប្រើប្រាស់ទូរសព្ទដៃ

បច្ចុប្បន្ននេះ ការប្រើប្រាស់សំបុត្រដើម្បីធ្វើការទំនាក់ទំនងគ្នាលែងសូវមានវត្តមានទៀតហើយ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រព័ន្ធបច្ចេកវិទ្យាកាន់តែទំនើបទៅៗ ទូរសព្ទដៃក៏បានក្លាយជាឧបករណ៍ដ៏ពិសេសមួយសម្រាប់ភ្ជាប់ការទំនាក់ទំនងគ្នា។ ទោះជានៅទីណា ឬកន្លែងណាក៏ដោយ ក៏ទូរសព្ទនៅតែមានលទ្ធភាពអាចភ្ជាប់ដើម្បីជជែកគ្នា ឃើញទាំងរូបភាព និងឮជាសំឡេងផងដែរ។

*រូបភាពទី១០៖ ភាគរយនៃខ្នងផ្ទះដែលមានទូរសព្ទដៃប្រើប្រាស់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ជាក់ស្តែង ដូចជានៅក្នុងរូបភាពទី១០នេះអ៊ីចឹង យើងឃើញថា ខេត្តកំពង់ធំ មានខ្នងផ្ទះតែ ១១,៨% និងខេត្តឧត្តរមានជ័យមានតែ ៤,៨% ប៉ុណ្ណោះ ដែលគ្មានលទ្ធភាពក្នុងការប្រើប្រាស់ទូរសព្ទដៃ។ ការរារាំងនេះ គឺដោយសារកត្តាសេដ្ឋកិច្ច ចំណេះដឹង ភូមិសាស្ត្រ និងបរិបទជុំវិញ។

### ២.១.៥. បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់

#### ក. បរិក្ខារកសិកម្ម និងនេសាទ

*តារាងទី៥៖ ចំនួនគ្រួសារដែលមានបរិក្ខារកសិកម្ម និងនេសាទ*

| ប្រភេទ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| គ្រឿងម៉ាស៊ីនភ្ជួររាស់/កសិកម្ម | ៣១.១៤៦ | ៣១.៤៥៦ | ២៨.៣៨២ | ៣០.៩១៤ |
| ម៉ាស៊ីនប្រមូលផល | ៦០២ | ៦៥០ | ៣១០ | ៣២០ |
| ឧបករណ៍កសិកម្មក្រៅពីគ្រឿងម៉ាស៊ីន | ១១.២៤៨ | ១៩.២១៦ | ៤.១០០ | ៤.២១០ |
| រទេះគោ/រទេះសេះ | ១.០៤៤ | ១.១០៦ | ៦ | ៦ |
| ទូកនេសាទ | ១២.១៥៤ | ១២.៥២៦ | ៣០០ | ៣៣៨ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី៥ បានបង្ហាញពីចំនួនបរិក្ខារកសិកម្ម និងនេសាទដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះយើងឃើញថា ខេត្តកំពង់ធំ គ្រឿងម៉ាស៊ីនភ្ជួររាស់/កសិកម្មមានចំនួន៣១.៤៥៦គ្រឿង ស្មើនឹង១៧,0% (កាន់កាប់ដោយ ៣១.១៤៦គ្រួសារ) ម៉ាស៊ីនប្រមូលផលមាន៦៥០គ្រឿង ស្មើ ០,៣% (កាន់កាប់ដោយ ៦០២គ្រួសារ) ឧបករណ៍កសិកម្មក្រៅពីគ្រឿងម៉ាស៊ីនមាន១៩.២១៦គ្រឿង ស្មើ ៦,១% (កាន់កាប់ដោយ ១១.២៤៨គ្រួសារ) រទេះគោ/រទេះសេះមាន១.១០៦គ្រឿង ស្មើ ០,៦% (កាន់កាប់ដោយ ១.០៤៤គ្រួសារ) និងទូកនេសាទមាន១២.៥២៦គ្រឿង ស្មើ ៦,៦% (កាន់កាប់ដោយ ១២.១៥៤គ្រួសារ)។ ខេត្តឧត្តរមានជ័យ គ្រឿងម៉ាស៊ីនភ្ជួររាស់/កសិកម្មមានចំនួន៣០.៩១៤គ្រឿង ស្មើនឹង៤៦,៨% (កាន់កាប់ដោយ ២៨.៣៨២គ្រួសារ) ម៉ាស៊ីនប្រមូលផលមាន៣២០គ្រឿង ស្មើ ០,៥% (កាន់កាប់ដោយ ៣១០គ្រួសារ) ឧបករណ៍កសិកម្មក្រៅពីគ្រឿងម៉ាស៊ីនមាន៤.២១០គ្រឿង ស្មើ ៦,៨% (កាន់កាប់ដោយ ៤.១០០គ្រួសារ) ទូកនេសាទមាន៣៣៨គ្រឿង ស្មើ ០,៥% (កាន់កាប់ដោយ ៣០០គ្រួសារ) ចំណែករទេះគោ/រទេះសេះមិនសូវមានអ្នកប្រើប្រាស់ទេ (៦គ្រឿង ដែលកាន់កាប់ដោយ ៦គ្រួសារ)។ ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារកសិកម្ម និងនេសាទនីមួយៗ ទៅនឹងចំនួនគ្រួសារសរុបដែលមាននៅទូទាំងខេត្តទាំងពីរ។

## ខ. បរិក្ខារដឹកជញ្ជូន

*តារាងទី៦៖ ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ដឹកជញ្ជូន*

| ប្រភេទ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| រថយន្តដឹកទំនិញ | ១.៧២៦ | ១.៧៧៤ | ២៦៦ | ៣០៦ |
| រថយន្តដឹកអ្នកដំណើរ | ៨២៨ | ១.០៤៦ | ១៥០ | ១៥៨ |
| រថយន្តក្រុង | ២៧៦ | ២៨០ | ១៧៨ | ១៩៨ |
| ម៉ូតូកង់បី | ៩៩០ | ១.០០៤ | ៦៦ | ៦៨ |
| រទេះអូសដោយដៃ | ៧៣៤ | ៧៣៤ | ៨៩០ | ៩០៨ |
| ទូកដឹកអ្នកដំណើរ | ៤៨ | ៤៨ | ៨ | ៨ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី៦ បានបង្ហាញពីចំនួនបរិក្ខារសម្រាប់ដឹកជញ្ជូនដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះយើងឃើញថា ខេត្តកំពង់ធំ រថយន្តដឹកទំនិញមានចំនួន១.៧៧៤គ្រឿង ស្មើនឹង ០,៩% ដែលជាតួលេខច្រើនជាងគេ (កាន់កាប់ដោយ ១.៧២៦គ្រួសារ) បន្ទាប់គឺរថយន្តដឹកអ្នកដំណើរមាន១.០៤៦គ្រឿង ស្មើ ០,៥% (កាន់កាប់ដោយ ៨២៨គ្រួសារ) បន្ទាប់ទៀតគឺម៉ូតូកង់បី មានចំនួន១.០០៤គ្រឿង ស្មើ ០,៥% (កាន់កាប់ដោយ ៩៩០គ្រួសារ) ហើយរទេះអូសដោយដៃមាន៧៣៤គ្រឿង ស្មើ ០,៤% (កាន់កាប់ដោយ ៧៣៤គ្រួសារ) រថយន្តក្រុងមាន ២៨០គ្រឿង ស្មើ ០,២% (កាន់កាប់ដោយ ២៧៦គ្រួសារ) និងចុងក្រោយ គឺទូកដឹកអ្នកដំណើរមាន៤៨គ្រឿង (កាន់កាប់ដោយ ៤៨គ្រួសារ) ដែលជាចំនួនតិចជាងគេ បើធៀបទៅនឹងចំនួនគ្រួសារសរុបដែលមាននៅក្នុងខេត្តនេះ។ ខេត្តឧត្តរមានជ័យ រទេះអូសដោយដៃមានចំនួនច្រើនជាងគេ គឺ៩០៨គ្រឿង ស្មើ ១,៥% (កាន់កាប់ដោយ ៨៩០គ្រួសារ) បន្ទាប់មកគឺរថយន្តដឹកទំនិញមាន ០,៤% រថយន្តក្រុងមាន ០,៣% រថយន្តដឹកអ្នកដំណើរមាន ០,២% ម៉ូតូកង់បីមាន ០,១% ចំណែកឯទូកដឹកអ្នកដំណើរមានតែ ៨គ្រឿង (កាន់កាប់ដោយ ៨គ្រួសារ) ប៉ុណ្ណោះ។ ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារសម្រាប់ដឹកជញ្ជូននីមួយៗ ទៅនឹងចំនួនគ្រួសារសរុបដែលមាននៅទូទាំងខេត្តទាំងពីរ។

### គ. បរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួន

*តារាងទី៧៖ ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន*

| ប្រភេទ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| រថយន្តលក្ខណៈគ្រួសារ | ៩.២៦៦ | ៩.៧២០ | ៣.៩៥២ | ៤.៨៣៤ |
| ម៉ូតូ | ១៤០.២៩២ | ១៥៧.000 | ៤៤.២១៨ | ១៩២.១០២ |
| ទូក | ៤.៨២៨ | ៤.៩៧៦ | ៤០ | ៤០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ផ្អែកតាមតារាងទី៧ យើងឃើញថា ម៉ូតូមានចំនួនច្រើនលើលលប់ បើធៀបទៅនឹងបរិក្ខារប្រើប្រាស់ផ្ទាស់ខ្លួនផ្សេងទៀត ខេត្តកំពង់ធំមានរហូតដល់ ៧៦,៥% (១៥៧.000គ្រឿង ដែលកាន់កាប់ដោយ១៤០.២៩២គ្រួសារ) និងខេត្តឧត្តរមានជ័យមាន ៧២,៩% (១៩២.១០២គ្រឿង ដែលកាន់កាប់ដោយ៤៤.២១៨គ្រួសារ)។ ចំណែករថយន្តលក្ខណៈគ្រួសារមាន ៥,១% (៩.៧២០គ្រឿង ដែលកាន់កាប់ដោយ ៩.២៦៦គ្រួសារ) ទូកមាន ២,៦% (៤.៩៧៦គ្រឿង ដែលកាន់កាប់ដោយ ៤.៨២៨គ្រួសារ) សម្រាប់ខេត្តកំពង់ធំ រីឯខេត្តឧត្តរមានជ័យវិញ រថយន្តលក្ខណៈគ្រួសារមាន ៦,៥% (៤.៨៣៤គ្រឿង ដែលកាន់កាប់ដោយ ៣.៩៥២គ្រួសារ) ទូកមាន ០,១% (៤០គ្រឿង ដែលកាន់កាប់ដោយ ៤០គ្រួសារ។ ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននីមួយៗ ទៅនឹងចំនួនគ្រួសារសរុបដែលមាននៅទូទាំងខេត្តទាំងពីរ។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១. អត្រាកំណើត

*តារាងទី៨៖ ចំនួន និងកន្លែងកើតរបស់ទារក*

| ប្រភេទ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី |
| មន្ទីរពេទ្យ/មណ្ឌលសុខភាពរដ្ឋ | ៤.១៩០ | ៥.០៤៤ | ១.៤៨៦ | ១.៦២៤ |
| មន្ទីរពេទ្យ/គ្លីនិកឯកជន | ២០២ | ២៦៤ | ៨ | ២៤ |
| ផ្សេងៗ | ២ | ១០ | ០ | ២ |
| **សរុបរួម** | **៤.៣៩៤** | **៥.៣១៨** | **១.៤៩៤** | **១.៦៥០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី៨ បានបង្ហាញនូវអត្រាកំណើតរបស់ទារក ដោយបែងចែកចំនួនទារកទៅតាមទីកន្លែងដែលបានសម្រាល។ តារាងនេះបានកំណត់បង្ហាញឱ្យឃើញថា ខេត្តកំពង់ធំ ទារកភាគច្រើនគឺកើតនៅមន្ទីរពេទ្យរដ្ឋ (មន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព ... ) ដែលមានចំនួន ៩.២៣៤នាក់ (ស្រី ៥.០៤៤នាក់) ដែលស្មើនឹង ៩៥,១% ចំណែកមន្ទីរពេទ្យឯកជន (មន្ទីរពេទ្យ មន្ទីរសម្រាកព្យាបាល គ្លីនិកសម្ភព ... ) មានចំនួន ៤៦៦នាក់ (ស្រី ២៦៤នាក់) ស្មើនឹង ៤,៨% និងនៅទីកន្លែងផ្សេងទៀតៗមាន ១២នាក់ (ស្រី ១០នាក់) ស្មើនឹង ០,១%។ ខេត្តឧត្តរមានជ័យ ក៏មិនខុសពីខេត្តកំពង់ធំដែរ ដោយទារកភាគច្រើនគឺកើតនៅមន្ទីរពេទ្យរដ្ឋ ដែលមានរហូតដល់ ៣១១០នាក់ (ស្រី ១.៦២៤នាក់) ស្មើនឹង ៩៨,៩% ខណៈដែលមន្ទីរពេទ្យឯកជន និងកន្លែងផ្សេងទៀតមានតែ ៣៤នាក់ (ស្រី ២៦នាក់) ស្មើនឹង ១,១% ប៉ុណ្ណោះ។

*រូបភាពទី១១ ភាគរយនៃកំណើតទារកដោយបែងចែកតាមភេទ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

បើនិយាយពីកំណើតរបស់ទារកដោយបែងចែកតាមភេទវិញឃើញថា (រូបភាពទី១១) ភាគរយនៃភេទទាំងពីរមិនសូវជាខុសគ្នាប៉ុន្មានឡើយដោយ៖ ខេត្តកំពង់ធំ ទារកភេទប្រុសមាន ៤៥,២% និងទារកភេទស្រីមាន ៥៤,៨% ចំណែកឯខេត្តឧត្ដរមានជ័យ ទារកភេទប្រុសមាន ៤៧,៥% និងទារកភេទស្រីមាន ៥២,៥%។

## ២.២.២. មរណភាព

ផ្នែកនេះ នឹងមានបង្ហាញនូវទិន្នន័យមួយចំនួនទាក់ទងទៅនឹងមូលហេតុចម្បងនៃការស្លាប់ដូចជា ស្លាប់ដោយជំងឺ គ្រោះថ្នាក់ចរាចរណ៍ លង់ទឹក ពស់ចឹក ឃាតកម្ម និងស្លាប់ដោយកត្តាផ្សេងៗទៀត។ ទន្ទឹមនោះ ទិន្នន័យនៃការស្លាប់តាមក្រុមអាយុ និងភេទ ក៏ត្រូវបានបង្ហាញផងដែរ។

## ក. មូលហេតុនៃការស្លាប់

*តារាងទី៩៖ ចំនួន និងមូលហេតុនៃការស្លាប់ក្នុង១២ខែចុងក្រោយ*

| មូលហេតុស្លាប់ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ជំងឺ | ៣.១៨២ | ៨៨,០០ | ៦៦៤ | ៨៩,៤៩ |
| គ្រោះថ្នាក់ចរាចរណ៍ | ២៣២ | ៦,៤២ | ២៤ | ៣,២៣ |
| លង់ទឹក | ១០២ | ២,៨២ | ១៨ | ២,៤៣ |
| អត្តឃាត | ៣៤ | ០,៩៤ | ១២ | ១,៦២ |
| ឃាតកម្ម | ២០ | ០,៥៥ | ៤ | ០,៥៤ |
| ពស់ចឹក | ៦ | ០,១៧ | ៤ | ០,៥៤ |
| គ្រាប់មិនទាន់ផ្ទុះ | ០ | ០,០០ | ០ | ០,០០ |
| ផ្សេងៗ | ៤០ | ១,១១ | ១៦ | ២,១៦ |
| **សរុប** | **៣.៦១៦** | **១០០** | **៧៤២** | **១០០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី៩ បានបង្ហាញនូវចំនួន និងមូលហេតុនៃការស្លាប់ក្នុងរយៈពេល១២ខែចុងក្រោយ។ នៅឆ្នាំ២០២២នេះ ខេត្តកំពង់ធំ មានអ្នកស្លាប់សរុបចំនួន ៣.៦១៦នាក់ ក្នុងនោះអ្នកស្លាប់ដោយសារជំងឺ មានចំនួនច្រើនជាងគេដែលមានរហូតដល់ទៅ ៣.១៨២នាក់ (៨៨%) បន្ទាប់មកគឺអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ក៏មានចំនួនគួរឱ្យកត់សម្គាល់ផងដែរ ដែលមានចំនួន ២៣២នាក់ (៦,៤២%) ឯអ្នកស្លាប់ដោយលង់ទឹកមានចំនួន ១០២នាក់ (២,៨២%) អ្នកស្លាប់ដោយសារធ្វើអត្តឃាត/ឃាតកម្មមាន ៥៤នាក់ (១,៤៩%) អ្នកស្លាប់ដោយសារមូលហេតុផ្សេងៗមានចំនួន ៤០នាក់ (១,១១%) ចំណែកឯអ្នកស្លាប់ដោយសារពស់ចឹកមានចំនួនតិចជាងគេ គឺ៦នាក់ (០,១៧%)។ ខេត្តឧត្តរមានជ័យ មានអ្នកស្លាប់សរុប ៧៤២នាក់ ក្នុងនោះអ្នកស្លាប់ដោយសារជំងឺមានចំនួនច្រើនជាងគេ គឺ ៦៦៤នាក់ (៨៩,៤៩%) បន្ទាប់មកគឺអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍មានចំនួន ២៤នាក់ (៣,២៣%) អ្នកស្លាប់ដោយលង់ទឹកមានចំនួន ១៨នាក់ (២,៤៣%) អ្នកស្លាប់ដោយសារធ្វើអត្តឃាត/ឃាតកម្មមាន ១៦នាក់ (២,១៦%) អ្នកស្លាប់ដោយសារមូលហេតុផ្សេងៗមានចំនួន ១៦នាក់ (២,១៦%) និងអ្នកស្លាប់ដោយសារពស់ចឹកមានចំនួន ៤ នាក់ (០,៥៤%)។

## ខ. អាយុនៃអ្នកស្លាប់




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី១២ គឺជាចំនួនអ្នកស្លាប់ដោយបែងចែកទៅតាមក្រុមអាយុ។ រូបភាពខាងលើបានបញ្ជាក់យ៉ាងច្បាស់ផងដែរថា នៅពេលមនុស្សមានវ័យកាន់តែច្រើន (៦៥ឆ្នាំឡើង) អត្រានៃការស្លាប់ក៏កាន់តែខ្ពស់តាមនោះដែរ។ ជាក់ស្តែងយើងឃើញថា ខេត្តកំពង់ធំ អ្នកស្លាប់ភាគច្រើនគឺជាមនុស្សស្រីដែលស្ថិតក្នុងក្រុមអាយុចាប់ពី៦៥ឆ្នាំឡើងទៅ (១.៩២២នាក់ ស្រី ១.០១៦នាក់) ខណៈដែលមនុស្ស វ័យកុមារ និងវ័យកណ្តាលដែលមានមនុស្សប្រុសស្លាប់ច្រើនជាងមនុស្សស្រី (១.៦៩៤នាក់ ស្រី៦៥០នាក់)។ ចំណែកឯខេត្តឧត្តរមានជ័យ អ្នកស្លាប់រវាងភេទប្រុសនិងភេទស្រីមិនសូវជាខុសគ្នាប៉ុន្មានទេ។ ក្នុងចំណោមអ្នកស្លាប់ទាំង ៧៤២នាក់ (ស្រី ៣៤៤នាក់) យើងឃើញថា អ្នកស្លាប់ភាគច្រើនគឺជាមនុស្សប្រុសដែលស្ថិតក្នុងវ័យពី១៨-៦៤ឆ្នាំ (១៩៤នាក់) ខណៈដែលអ្នកវ័យចំណាស់ (៦៥ឆ្នាំឡើង) មានអ្នកស្លាប់ចំនួន ១៦៤នាក់ និងវ័យក្មេងមាន ៣០នាក់ ផ្ទុយពីអ្នកស្លាប់ភេទស្រី ដែលមនុស្សវ័យចំណាស់(៦៥ឆ្នាំឡើង) មានច្រើនជាងអ្នកស្លាប់ដែលមានវ័យពី ០-៦៤ឆ្នាំ ចំនួន ៧៨នាក់។

*រូបភាពទី១៣៖ ភាគរយអ្នកស្លាប់តាមក្រុមអាយុ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី១៣ គឺជាភាគរយនៃអ្នកស្លាប់ដោយបែងចែកតាមក្រុមអាយុ។ តាមរូបនេះបង្ហាញថា ខេត្តកំពង់ធំ មនុស្សដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី ៦៥ឆ្នាំឡើង មានអត្រាស្លាប់ច្រើនជាងគេ (៥៣%) ខណៈដែលក្រុមអាយុ ១៨-៦៤ឆ្នាំ មាន ៤០% ក្រុមអាយុ ៥-១៧ឆ្នាំ មាន ៤% ចំណែកឯក្រុមអាយុក្រោម៥ឆ្នាំមាន ៣%។ ខេត្តឧត្តរមានជ័យ មនុស្សដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី ៦៥ឆ្នាំឡើង មានអត្រាស្លាប់ច្រើនជាងគេដែលមាន ៥៧% បន្ទាប់មកគឺក្រុមអាយុ ១៨-៦៤ឆ្នាំ មាន ៣៧% ក្រុមអាយុ ៥-១៧ឆ្នាំ មាន ៤% និងក្រុមអាយុក្រោម៥ឆ្នាំ មាន ២% ដែលជាចំនួនតិចជាងគេបើធៀបទៅនឹងភាគរយនៃអ្នកស្លាប់ក្នុងក្រុមអាយុទាំងបួន។

## ២.៣. ពិការភាព និងបុគ្គលគ្មានអ្នកថែទាំ

ជនមានពិការភាព ត្រូវបានឲ្យនិយមន័យថា គឺជាឧបសគ្គ ឬជាកង្វះខាតផ្នែកសមត្ថភាពណាមួយ ក្នុងការអនុវត្តសកម្មភាព ឬនៅក្នុងកម្រិតមួយដែលមនុស្សធម្មតាអាចធ្វើបាន។

*តារាងទី១០៖ ចំនួនបុគ្គលមានពិការភាព និងមនុស្សគ្មានអ្នកថែទាំ*

| បរិយាយ | កំពង់ធំ | | | ឧត្តរមានជ័យ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ពិការភាព (ក្រោម១៨ឆ្នាំ) | ៨៨០ | ៤៧៦ | ៤០៤ | ៨៨០ | ៤៧៦ | ៤០៤ |
| ពិការភាព (អាចរកប្រាក់ចំណូលបាន) | ៥៨២ | ៤៤២ | ១៤០ | ១.៧៨៦ | ១.៤៣៦ | ៣៥០ |
| ពិការភាព (មិនអាចរកប្រាក់ចំណូលបាន) | ១.៥០២ | ៨០២ | ៧០០ | ៧១២ | ៤៣០ | ២៨២ |
| ពិការភាព (ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ) | ៣៦៤ | ៣២៤ | ៤០ | ៨៤ | ៧២ | ១២ |
| មនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ | ៣៨២ | ១២៤ | ២៥៨ | ១៤៤ | ៤៦ | ៩៨ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១០ បានបង្ហាញពីចំនួនបុគ្គលមានពិការភាព និងមនុស្សគ្មានអ្នកថែទាំ។ នៅក្នុងខេត្តកំពង់ធំ មានបុគ្គលពិការភាព (អាយុក្រោម១៨ឆ្នាំ) ចំនួន ៨៨០នាក់ (ស្រី ៤០៤នាក់) ពិការភាពអាចរកប្រាក់ចំណូលបាន មានចំនួន ៥៨២នាក់ (ស្រី ១៤០នាក់) ពិការភាពមិនអាចរកប្រាក់ចំណូលបានមានចំនួន ១.៥០២នាក់ (ស្រី ៧០០នាក់) និងមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ចំនួន ៣៨២នាក់ (ស្រី ២៥៨នាក់)។ ខេត្តឧត្តរមានជ័យ មានបុគ្គលពិការភាព (អាយុក្រោម១៨ឆ្នាំ) ចំនួន ៨៨០នាក់ (ស្រី ៤០៤នាក់) ពិការភាពអាចរកប្រាក់ចំណូលបានមានចំនួន ១.៧៨៦នាក់ (ស្រី ៣៥០នាក់) ពិការភាពមិនអាចរកប្រាក់ចំណូលបានមានចំនួន ៧១២នាក់ (ស្រី ២៨២នាក់) និងមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ចំនួន ១៤៤នាក់ (ស្រី ៩៨នាក់)។

## ក. អនីតិជនមានពិការភាព




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តាមរូបភាពនេះ (រូបភាពទី១៤) បានបង្ហាញថា ភាគរយនៃអនីតិជនមានពិការភាពនៅក្នុងខេត្តទាំងពីរគឺស្មើគ្នា ដែលមនុស្សប្រុសមាន ៥៤% ខណៈដែលមនុស្សស្រីមាន ៤៦%។

## ខ. ពិការភាពអាចរកប្រាក់ចំណូលបាន




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី១៥ បានបង្ហាញពីភាគរយនៃជនមានពិការភាពដែលមានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាន (ឧទាហរណ៍ដូចជា៖ ជាងម៉ូតូ ជាងកង់ ជាងកាត់សក់ ឬអ៊ុតសក់ជាដើម)។ យើងឃើញថា ខេត្តកំពង់ធំ ជនមានពិការភាពដែលមានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបានជាបុរសមាន ៧៦% និងស្ត្រីមាន ២៤% ខណៈដែលខេត្តឧត្តរមានជ័យមាន ៨០% ជាបុរស និង ២០% ជាស្ត្រី។

## គ. ពិការភាពមិនអាចរកប្រាក់ចំណូលបាន

*រូបភាពទី១៦៖ ភាគរយជនមានពិការភាពដែលមិនអាចរកប្រាក់ចំណូលបាន*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី១៦ បានបង្ហាញពីភាគរយនៃជនមានពិការភាពដែលគ្មានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបាន។ យើងឃើញថា ខេត្តកំពង់ធំ ជនមានពិការភាពដែលគ្មានសមត្ថភាពអាចរកចំណូលដោយខ្លួនឯងបានជាបុរសមាន ៥៣% និងស្ត្រីមាន ៤៧% ខណៈដែលខេត្តឧត្តរមានជ័យមាន ៦០% ជាបុរស និង ៤០% ជាស្ត្រី។

## ឃ. ពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ

*រូបភាពទី១៧៖ ភាគរយជនមានពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី១៧ បានបង្ហាញពីភាគរយនៃជនមានពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ។ យើងឃើញថា ខេត្តកំពង់ធំ ជនមានពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះជាបុរសមាន ៨៩% និងស្ត្រីមាន ១១% ខណៈដែលខេត្តឧត្តរមានជ័យមាន ៨៦% ជាបុរស និង ១៤% ជាស្ត្រី។

## ង. មនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់

ការរស់នៅដោយមានគ្នាសំណាក់អាស្រ័យជាមួយ គឺជារឿងសំខាន់ ពិសេសនៅពេលមានជំងឺឈឺថ្កាត់ ឬពេលស្ថិតនៅក្នុងវ័យជរា។ ទោះជាមិនចង់រស់នៅឯកាយ៉ាងណាក្តី តែព្រហ្មលិខិតបានកម្រិតចារមកហើយ យើងត្រូវតែហ៊ានទទួលយក និងតស៊ូ ព្យាយាម ជំនះគ្រប់ឧបសគ្គ ដរាបដល់ដង្ហើមចុងក្រោយ។

*រូបភាពទី១៨៖ ភាគរយមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ជាក់ស្តែង នៅក្នុងតារាងទី១៨ខាងលើ បានបង្ហាញថា៖ ខេត្តកំពង់ធំ មានមនុស្សចាស់ចំនួន ៣៨២នាក់ (ស្រី ២៥៨នាក់ ស្មើនឹង ៣២%) ខណៈដែលខេត្តឧត្តរមានជ័យមាន ១៤៤នាក់ (ស្រី ៩៨នាក់ ស្មើនឹង ៣២%) បាននិងកំពុងរស់រងវេទនាដោយគ្មានអ្នកផ្គត់ផ្គង់ និងមើលថែទាំត្រឹមត្រូវ។

## ២.៤. ការលែងលះ

អាពាហ៍ពិពាហ៍ ត្រូវបានកំណត់និយមន័យខុសៗគ្នាទៅតាមអង្គភាព ឬដោយផ្អែកទៅលើវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី សាសនា មជ្ឈដ្ឋានជុំវិញ ឬបុគ្គលផ្ទាល់ខ្លួនជាដើម។ នៅក្នុងរបាយការណ៍នេះ និយមន័យនៃអាពាហ៍ពិពាហ៍ត្រូវបានកំណត់ថា៖ ជាកិច្ចសន្យាសង្គម និងច្បាប់រវាងបុគ្គលពីរនាក់ដែលបង្រួបបង្រួមជីវិតរបស់ពួកគេតាមផ្លូវច្បាប់ផ្នែកសេដ្ឋកិច្ច និងខាងអារម្មណ៍។ កិច្ចសន្យាអាពាហ៍ពិពាហ៍ ជាធម្មតាបញ្ជាក់ថា ប្តីប្រពន្ធនោះមានកាតព្វកិច្ចផ្លូវច្បាប់ចំពោះគ្នាទៅវិញទៅមកពេញមួយជីវិត ឬរហូតដល់ពួកគេសម្រេចចិត្តលែងលះគ្នា។

*តារាងទី១១៖ ចំនួនអ្នកលែងលះ បែងចែកតាមមុខរបរនៃមេគ្រួសារ*

| មុខរបរមេគ្រួសារ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ពលករ/កម្មករ | ១.៥០៤ | ៤២,១១ | ៨៤ | ៣៧,៨៤ |
| មន្ត្រីរាជការ | ៥៨៤ | ១៦,៣៥ | ២៨ | ១២,៦១ |
| អ្នកមានវិជ្ជាជីវៈ | ៤៨០ | ១៣,៤៤ | ៤២ | ១៨,៩២ |
| អ្នកជំនួញ | ៤៦៦ | ១៣,០៥ | ១៨ | ៨,១១ |
| អ្នកនយោបាយ | ៧៤ | ២,០៧ | ២៤ | ១០,៨១ |
| ផ្សេងៗ | ៤៦៤ | ១២,៩៩ | ២៦ | ១១,៧១ |
| **សរុប** | **៣.៥៧២** | **១០០** | **២២២** | **១០០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១១ បានបង្ហាញនូវចំនួនអ្នកលែងលះគ្នាដោយបែងចែកតាមប្រភេទនៃមេគ្រួសារ។ យើងឃើញថា ខេត្តកំពង់ធំ ចំនួនអ្នកលែងលះគ្នាមាន ៣.៥៧២គ្រួសារ ក្នុងនោះមេគ្រួសារដែលមានមុខរបរជាពលករ/កម្មករមានចំនួនខ្ពស់ជាងគេ គឺ១.៥០៤គ្រួសារ (៤២,១១%) បន្ទាប់មកគឺមន្ត្រីរាជការ ៥៨៤គ្រួសារ (១៦,៣៥%) អ្នកមានវិជ្ជាជីវៈ ៤៨០គ្រួសារ (១៣,៤៤%) អ្នកជំនួញ ៤៦៦គ្រួសារ (១៣,០៥%) អ្នកមានមុខផ្សេងៗ ៤៦៤គ្រួសារ (១២,៩៩%) និងអ្នកនយោបាយមាន ៧៤គ្រួសារ (២,០៧%) ដែលជាចំនួនតិចជាងគេ។ ខេត្តឧត្តរមានជ័យ ចំនួនអ្នកលែងលះគ្នាមាន ២២២គ្រួសារ ក្នុងនោះមេគ្រួសារដែលមានមុខរបរជាពលករ/កម្មករមានចំនួន ៨៤គ្រួសារ (៣៧,៨៤%) ដែលជាចំនួនខ្ពស់ជាងគេ បន្ទាប់មក គឺអ្នកមានវិជ្ជាជីវៈមាន ៤២គ្រួសារ (១៨,៩២%) បន្ទាប់មកទៀតគឺ មន្ត្រីរាជការ ២៨គ្រួសារ (១២,៦១%) អ្នកដែលមានមុខផ្សេងៗមាន ២៦គ្រួសារ (១១,៧១%) អ្នកនយោបាយមាន ២៤គ្រួសារ (១០,៨១%) និងអ្នកជំនួញមាន ១៨គ្រួសារ (៨,១១%) ដែលជាចំនួនតិចជាងគេ បើធៀបទៅនឹងចំនួនអ្នកលែងលះគ្នានៃមុខរបររបស់មេគ្រួសារទាំងអស់។

## ២.៥. ការប្រើប្រាស់ទឹក និងបង្គន់អនាម័យ

ទឹក គឺជាវត្ថុរាវធម្មតាមួយប្រភេទនៅលើផែនដី។ វាមាន ៧១,៤% នៃផ្ទៃផែនដី គ្របដណ្តប់ទៅដោយទឹក។ ទឹកស្អាតដែលសព្វថ្ងៃគេនិយមហៅថា ទឹកបរិសុទ្ធ ពុំមានក្លិន រសជាតិ និងពណ៌ទេ។ ឈ្មោះនៃទឹក ត្រូវបានគេហៅតាមទីកន្លែងរបស់វាដូចជា ទឹកបឹង ទឹកទន្លេ ទឹកសមុទ្រ ឬទឹកភ្លៀងជាដើម។

### ក. ប្រភពទឹកប្រើប្រាស់

*តារាងទី១២៖ ប្រភពទឹកចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ*

| ប្រភពទឹក | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ទឹកភ្លៀង | ១.៦៦៧ | ០,៩១ | ១.៨៧០ | ៣,០៨ |
| ទឹកបរិសុទ្ធ | ៨.១០៩ | ៤,៤២ | ៧០៧ | ១,១៧ |
| ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ | ១៥.១១៦ | ៨,២៤ | ២៦.២៤២ | ៤៣,២៨ |
| ទឹកស្អាត (ទុយោ) | ៤០.៣៦៣ | ២២,០១ | ៩.៩២៥ | ១៦,៣៧ |
| ទឹកអណ្តូង | ១១៨.១០៩ | ៦៤,៤១ | ២១.៨៨៤ | ៣៦,១០ |
| **សរុប** | **១៨៣.៣៦៤** | **១០០** | **៦០.៦២៨** | **១០០** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១២ បង្ហាញពីប្រភពទឹកចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ខេត្តកំពង់ធំ ប្រមាណជា ៦៤,៤១% នៃគ្រួសារសរុបបានប្រើប្រាស់ទឹកអណ្តូង (១១៨.១០៩គ្រួសារ) បន្ទាប់មកគឺ ទឹកស្អាត (ទុយោ) មាន ២២,០១% (៤០.៣៦៣គ្រួសារ) ខណៈដែល ១៣,៥៨% (២៤.៨៩២គ្រួសារ) ទៀត បានប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ទឹកភ្លៀង និងទឹកបរិសុទ្ធ។ ខេត្តឧត្តរមានជ័យ គ្រួសារភាគច្រើន (២៦.២៤២ គ្រួសារ ស្មើនឹង ៤៣,២៨%) បានយកទឹកស្រះ/បឹង/ស្ទឹង/ទន្លេ យកមកប្រើប្រាស់ (៤៣,២៨%) ហើយក៏មានគ្រួសារមួយចំនួនតូច (៧០៧គ្រួសារ ស្មើនឹង ១,១៧%) បានយកទឹកបរិសុទ្ធមកប្រើប្រាស់ជាប្រចាំថ្ងៃផងដែរ។

## ខ. ប្រភពទឹកទទួលទាន

*តារាងទី១៣៖ ប្រភពទឹកចម្បងសម្រាប់ទទួលទានក្នុងគ្រួសារ*

| ប្រភពទឹក | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ទឹកភ្លៀង | ៥៩៨ | ០,៣៣ | ៧៣៦ | ១,២១ |
| ទឹកបរិសុទ្ធ | ៧៨.៧០៩ | ៤២,៩៣ | ៣០.៨៥២ | ៥០,៨៩ |
| ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ | ២.០១៧ | ១,១០ | ១២.៧៤០ | ២១,០១ |
| ទឹកស្អាត (ទុយោ) | ១៧.៩៣៩ | ៩,៧៨ | ៥.៣៥៩ | ៨,៨៤ |
| ទឹកអណ្តូង | ៨៤.១០១ | ៤៥,៨៦ | ១០.៩៤១ | ១៨,០៥ |
| សរុប | ១៨៣.៣៦៤ | ១០០ | ៦០.៦២៨ | ១០០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១៣ បង្ហាញពីប្រភពទឹកចម្បងសម្រាប់ទទួលទានក្នុងគ្រួសារ។ ខេត្តកំពង់ធំ ប្រមាណជា ៤៥,៨៦% នៃគ្រួសារសរុបបានទទួលទានទឹកអណ្តូង (៨៤.១០១គ្រួសារ) បន្ទាប់មកគឺ ទឹកបរិសុទ្ធ មាន ៤២,៩៣% (៧៨.៧០៩គ្រួសារ) ខណៈដែល ១១,២១% (២០.៥៥៤គ្រួសារ) ទៀត បានទទួលទានទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ទឹកភ្លៀង និងទឹកស្អាត (ទុយោ)។ ខេត្តឧត្តរមានជ័យ គ្រួសារភាគច្រើន (៣០.៨៥២ គ្រួសារ) បានយកទឹកបរិសុទ្ធមកទទួលទាន (៥០,៨៩%) ខណៈដែលគ្រួសារ ៤៩,១១% ទៀតបានយកទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ទឹកភ្លៀង ទឹកស្អាត (ទុយោ) និងទឹកអណ្តូងមកទទួលទានជាប្រចាំថ្ងៃ។

## គ. បង្គន់អនាម័យ

អនាម័យ គឺជាកត្តាសំខាន់សម្រាប់សុខភាព។ ការប្រើប្រាស់នូវបង្គន់អនាម័យបានត្រឹមត្រូវ វាគឺជាផ្នែកមួយក្នុងការជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមជាតិ តាមរយៈការកាត់បន្ថយជំងឺនានា ជាពិសេសគឺជំងឺរាករូស។ តាមលទ្ធផលជំរឿនឆ្នាំ២០១៩ ការប្រើប្រាស់បង្គន់អនាម័យនៅកម្ពុជាមាន ៨២,៨% គឺមានការរីកចម្រើនជាខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។

*តារាងទី១៤៖ ការប្រើប្រាស់បង្គន់អនាម័យសម្រាប់បន្ទោបង់តាមគ្រួសារ*

| ប្រភពទឹក | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បង្គន់អនាម័យផ្ទាល់ខ្លួន | ១៥៦.២០០ | ៨៥,១៩ | ៤៩.៩៧២ | ៨២,៤២ |
| បង្គន់អនាម័យអ្នកជិតខាង | ១៩.៦៣០ | ១០,៧១ | ៣.៩១០ | ៦,៤៥ |
| បន្ទោបង់ពាសវាល | ៧.៥៣៤ | ៤,១១ | ៦.៧៤៦ | ១១,១៣ |
| សរុប | ១៨៣.៣៦៤ | ១០០ | ៦០.៦២៨ | ១០០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១៤ គឺជាចំនួននៃការប្រើប្រាស់បង្គន់អនាម័យសម្រាប់បន្ទោបង់តាមគ្រួសារ។ យើងឃើញថា ខេត្តកំពង់ធំ គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួនមានចំនួន ១៥៦.២០០គ្រួសារ (៨៥,១៩%) គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាង (បង្គន់ឪពុកម្តាយ បងប្អូន អ្នកជិតខាង វត្តអារាម សាលារៀន ... ) មានចំនួន ១៩.៦៣០គ្រួសារ (១០,៧១%) ខណៈដែលប្រជាពលរដ្ឋ ៧.៥៣៤ គ្រួសារ (៤,១១%) ទៀត នៅមិនទាន់មានបង្គន់អនាម័យសម្រាប់បន្ទោបង់នៅឡើយ (បន្ទោបង់ពាសវាលពាសកាល)។ រីឯខេត្តឧត្តមានជ័យ គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួនមានចំនួន ៤៩.៩៧២ គ្រួសារ (៨២,៤២%) គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាងមានចំនួន ៣.៩១០គ្រួសារ (៦,៤៥%) ខណៈដែលប្រជាពលរដ្ឋ ៦.៧៤៦គ្រួសារ (១១,១៣%) ទៀត គឺនៅបន្ទោបង់ពាសវាលពាសកាល។ ដូច្នោះអជ្ញាធរដែលពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានគួរតែខិតខំជំរុញបន្ថែមទៀត ពិសេសគឺប្រជាពលរដ្ឋខ្លួនឯងផ្ទាល់គួរតែចេះភ្ញាក់រឭកដោះស្រាយនូវបញ្ហានេះ។

### ឃ. គ្រួសារគ្មានផ្ទះសំបែង

*រូបភាពទី១៩៖ ចំនួនគ្រួសារគ្មានផ្ទះសំបែង និងរស់នៅលើដីសាធារណៈ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ប្រជាជនគ្មានផ្ទះសំបែង និងគ្មានដីធ្លី ក៏ជាបញ្ហាប្រឈមមួយក្នុងការអភិវឌ្ឍប្រទេសជាតិផងដែរ។ រូបភាពទី១៩ បានបង្ហាញថា នៅក្នុងខេត្តកំពង់ធំមានប្រជាជនរស់នៅលើដីសាធារណៈចំនួន ២.២៨៤ គ្រួសារ (១,២៥%) ខណៈដែល ៤៨៦ គ្រួសារ (០,០៦%) ទៀត កំពុងគ្មានផ្ទះសំបែងសម្រាប់ស្នាក់នៅ (ស្នាក់នៅផ្ទះគេ វត្តអារាម ឬទីសាធារណៈនានា)។ ខេត្តឧត្តរមានជ័យ មានប្រជាជនរស់នៅលើដី សាធារណៈចំនួន ៧០គ្រួសារ (០,១២%) ខណៈដែល ១៦៤គ្រួសារ (០,០៦%) ទៀត ស្នាក់នៅផ្ទះគេ វត្តអារាម ឬទីសាធារណៈនានា។

## ២.៦. បរិស្ថាន និងធនធានធម្មជាតិ

### ក. គ្រោះធម្មជាតិ

នៅប្រទេសកម្ពុជា ខ្យល់ព្យុះ ទឹកជំនន់ និងរន្ទះបាញ់ គឺជាគ្រោះមហន្តរាយធម្មជាតិចម្បងដែលធ្វើឱ្យបាត់បង់ជីវិតមនុស្សសត្វ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ខណៈដែលគ្រោះរាំងស្ងួត ការបាក់ដី/ស្រុតដីចូលទន្លេ ព្រៃក ឬស្ទឹង បានបង្កឱ្យមានទុក្ខវេទនាយ៉ាងខ្លាំងដល់ប្រជាជន ជាពិសេសចំពោះប្រជាកសិករ។ ការផ្លាស់ប្ដូរអាកាសធាតុនឹងធ្វើឱ្យស្ថានភាពនេះកាន់តែលំបាក ដោយរដូវប្រាំងមានអាកាសធាតុកាន់តែក្ដៅហួតហែង និងរដូវវស្សាមានភ្លៀងធ្លាក់ជោគជាំ និងខ្យល់ព្យុះកាន់តែខ្លាំង។

*តារាងទី១៥៖ ផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ*

| គ្រោះធម្មជាតិ | កំពង់ធំ | | ឧត្ដរមានជ័យ | |
|---|---|---|---|---|
| | គ្រួសាររងផលប៉ះពាល់ | ផ្ទៃដីរងផលប៉ះពាល់ (ហិកតា) | គ្រួសាររងផលប៉ះពាល់ | ផ្ទៃដីរងផលប៉ះពាល់ (ហិកតា) |
| ទឹកជំនន់ | ២៥.៦៩២ | ៣២.១១០ | ៥.៩៨២ | ៩.៦៦០ |
| បាក់/ស្រុតដី | ៧០ | ៤១៤ | ០ | ០ |
| គ្រោះរាំងស្ងួត | ២៧៦ | ២៧៤ | ១២០ | ១០៦ |
| ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ | ១២៦ | ២២៩ | ២ | ២០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១៥៖ ផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ។ តារាងនេះបានបង្ហាញថា ខេត្តកំពង់ធំ គ្រោះទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន ២៥.៦៩២ហិកតា (៣២.១១០គ្រួសារ) គ្រោះរាំងស្ងួតប៉ះពាល់ដល់ផ្ទៃដីដាំដុះចំនួន ២៧៦ហិកតា (២៧៤គ្រួសារ) ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ប៉ះពាល់ដល់ផ្ទៃដីចំនួន ១២៦ហិកតា (២២៩គ្រួសារ) ចំណែកការបាក់ដី/ស្រុតដីក៏បានរងផលប៉ះពាល់ផ្ទៃដីចំនួន៧០ហិកតា (៤១៤គ្រួសារ) ផងដែរ។ ខេត្តឧត្ដមានជ័យ គ្រោះទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន ៥.៩៨២ហិកតា (៩.៦៦០គ្រួសារ) គ្រោះរាំងស្ងួតប៉ះពាល់ដល់ផ្ទៃដីដាំដុះចំនួន ១២០ហិកតា (១០៦គ្រួសារ) និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន ២ ហិកតា (២០គ្រួសារ) ផងដែរ។

## ខ. ការគ្រប់គ្រងកាកសំណល់

នៅប្រទេសកម្ពុជា កំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កំពុងបង្កឱ្យមានការបំពុលបរិស្ថាន។ សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច បាននិងកំពុងបង្កផលវិបាកដល់បរិស្ថាន មនុស្ស និងសត្វផងដែរ។

*តារាងទី១៦៖ ចំនួនទីតាំងចោលកាកសំណល់*

| ទីតាំង | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ចំនួន | ផ្ទៃដី (ហិកតា) | ចំនួន | ផ្ទៃដី (ហិកតា) |
| កាកសំណល់ទូទៅ | ២៤ | ៣២៣.៨២៦ | ២ | ២ |
| កាកសំណល់ឧស្សាហកម្ម | 0 | 0 | 0 | 0 |
| កាកសំណល់សិប្បកម្ម | 0 | 0 | 0 | 0 |
| កាកសំណល់វេជ្ជសាស្ត្រ | ៣៤ | ២៨.២០៦ | ២០ | ២.២ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តាមតារាងទី១៦ យើងឃើញថា ទីតាំងចោលកាកសំណល់នៅក្នុងខេត្តកំពង់ធំមាន ៥៨កន្លែង គ្របដណ្តប់លើផ្ទៃដី ៣៥២.០៣២ហិកតា ចំណែកឯខេត្តឧត្តរមានជ័យវិញមាន ២២កន្លែង ដែលគ្របដណ្តប់លើផ្ទៃដី ៤,២ហិកតា។

## គ. ថាមពលចម្អិនអាហារ

*រូបភាពទី២០៖ ភាគរយការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារតាមគ្រួសារ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ការចម្អិនអាហារ គឺជាតម្រូវការចាំបាច់ និងមិនអាចខ្វះបានសម្រាប់ជីវិតរស់នៅរបស់មនុស្ស។ ការប្រើប្រាស់អុស ធ្យូង ក៏ត្រូវបានប្រើជាប្រភពថាមពលចម្បងមួយក្នុងការចម្អិនអាហារ។ តាមរូបភាពទី២០ បានបង្ហាញថា នៅក្នុងខេត្តកំពង់ធំ ប្រជាជនប្រមាណជា ៧៩,៤៨% បានប្រើប្រាស់អុស/ធ្យូង ខណៈដែលការប្រើហ្គាសមាន ២០,១៧% ឡជីវឧស្ម័នមាន ០,០៧% និងការប្រើប្រាស់ប្រភពថាមពលផ្សេងទៀតសម្រាប់ចម្អិនអាហារមានចំនួន ០,២៨%។ ខេត្តឧត្តរមានជ័យ ប្រជាជនប្រើប្រាស់អុស/ធ្យូងមាន ៨៧,៦៦% ហ្គាសមាន ១១,២១% ឡជីវឧស្ម័នមាន ០,៣៥% និងការប្រើប្រាស់ប្រភពថាមពលផ្សេងទៀតសម្រាប់ចម្អិនអាហារមានចំនួនមាន ០,៧៨%។

## ឃ. ព្រៃឈើ




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២១ បានបង្ហាញថា នៅក្នុងខេត្តកំពង់ធំ មានផ្ទៃដីព្រៃឈើគ្របដណ្ដប់ចំនួន ៦៥.៦៤៨ ហិកតា និងផ្ទៃដីដាំកូនព្រៃឈើមានចំនួន ១.៤៩៣ហិកតា។ ខេត្តឧត្តរមានជ័យ ផ្ទៃដីព្រៃឈើគ្របដណ្ដប់មានចំនួន ៣.៨៦៦ហិកតា និងផ្ទៃដីដាំកូនព្រៃឈើចំនួន ១០២ហិកតា។ ទន្ទឹមនោះ ក៏មាននូវការកាប់រានទន្ទ្រានព្រៃឈើចំនួន ១៣.១៩១ហិកតា ដើម្បីយកដីធ្វើកសិកម្ម និងជាកម្មសិទ្ធិផ្ទាល់ខ្លួនផងដែរ (ខេត្តកំពង់ធំ ១២.៦៩១ហិកតា និងខេត្តឧត្តរមានជ័យ ៥០០ហិកតា)។

## ២.៧. សន្តិសុខសង្គម និងសេដ្ឋកិច្ច

### ២.៧.១. សន្តិសុខសង្គម

អសន្តិសុខសង្គម សំដៅលើការលួច ឆក់ ប្លន់ ចាប់ជម្រិត ឧក្រិដ្ឋកម្ម ការប្រើប្រាស់គ្រឿងញៀន និងជម្លោះដីធ្លីនៅក្នុងមូលដ្ឋានជាដើម។ ចំពោះករណីទាំងអស់នេះ ទោះបីជាមានចំនួនកើតឡើងច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាល និងអាជ្ញាធរខេត្តព្រៃវែងបានខិតខំដោះស្រាយបានមួយចំនួនធំផងដែរ ដូចមានតួលេខបញ្ជាក់ខាងក្រោមនេះ៖

#### ក. អសន្តិសុខសង្គម

*រូបភាពទី២២៖ អសន្តិសុខ និងការដោះស្រាយ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២២ បានបង្ហាញពីបញ្ហាអសន្តិសុខ និងដំណោះស្រាយ។ រូបភាពនេះបានបង្ហាញថាក្នុងចំណោមករណីអសន្តិសុខដែលកើតមាននៅក្នុងខេត្តកំពង់ធំទាំងអស់ បញ្ហាប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នាមាន ១០៤០ករណី ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏អាជ្ញាធរព្យាយាមដោះស្រាយអស់ ៩៤៤ករណីដែរ។ ចំពោះបញ្ហាជម្លោះដីធ្លីបានកើតឡើង ៨៦៨ករណី ក្នុងនោះដោះស្រាយបានចំនួន ៦៨៤ករណី ករណីលួចមាន ២៦២ករណី ដោះស្រាយបាន ១០៨ករណី បញ្ហាប្លន់/ចាប់ជម្រិតមានចំនួន ៣៦ករណី ដោះស្រាយបាន ២ករណី និងករណីឃាតកម្ម/ឧក្រិដ្ឋកម្មមាន ១៦ករណី ដោះស្រាយបានទាំងអស់។ រីឯខេត្តឧត្តរមានជ័យវិញ បញ្ហាប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នា៣៤៨ករណី ដោះស្រាយអស់៣៣៤ករណី

ជម្លោះដីធ្លីមាន២០២ករណី ដោះស្រាយបាន១៥០ករណី លួចមាន៦៦ករណី ដោះស្រាយបាន ២៦ករណី បញ្ហាប្លន់/ចាប់ជម្រិតមាន២ករណី ដោះស្រាយបានទាំង២ករណី ខណៈដែលឃាតកម្ម/ឧក្រិដ្ឋកម្មមានចំនួន ១៨ករណី ដោះស្រាយបានតែ ២ករណី ប៉ុណ្ណោះ។

## ខ. អំពើហិង្សាក្នុងគ្រួសារ និងគ្រឿងញៀន




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៣បានបង្ហាញថា៖ ក្នុងចំណោមគ្រួសារសរុប (១៨៣.៣៦៤គ្រួសារ) ដែលរស់នៅខេត្តកំពង់ធំ គឺមាន៨៧០គ្រួសារ (០,៥%) បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ និង ៤៣០គ្រួសារ (០,២%) មានសមាជិកកំពុងប្រើប្រាស់គ្រឿងញៀន។ ខេត្តឧត្តរមានជ័យ ក្នុងចំណោមគ្រួសារសរុប (៦០.៦២៨គ្រួសារ) គឺមាន៣៣៤គ្រួសារ (០,៥%) បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ និង ៤៣០គ្រួសារ (០,២%) មានសមាជិកកំពុងប្រើប្រាស់គ្រឿងញៀន។

## គ. ស្ត្រីរងគ្រោះដោយការចាប់រំលោភ និងការជួញដូរ

*រូបភាពទី២៤៖ ចំនួនស្ត្រីរងគ្រោះដោយការចាប់រំលោភ និងការជួញដូរ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៤បានបង្ហាញថា៖ ខេត្តកំពង់ធំ មានស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទចំនួន ២២នាក់ ក្នុងនោះភាគច្រើនគឺជាស្ត្រីដែលមានអាយុចាប់ពី១៨ឆ្នាំឡើង រីឯការជួញដូរស្ត្រីវិញមាន ៨នាក់ (ក្រោមអាយុ១៨ឆ្នាំមាន២នាក់ និងចាប់ពី១៨ឆ្នាំឡើងមាន៦នាក់) ខណៈដែលខេត្តឧត្តរមានជ័យមានស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទចំនួន ៨នាក់ ដែលភាគច្រើនគឺជាក្មេងស្រីដែលមានអាយុក្រោម១៨ឆ្នាំ និងការជួញដូរស្ត្រីមាន ៤នាក់ (អាយុចាប់ពី១៨ឆ្នាំឡើងទៅ)។

## ២.៧.២. សេដ្ឋកិច្ចគ្រួសារ

នៅក្នុងប្រទេសកម្ពុជាយើងមានសកម្មភាពអាជីវកម្មជាច្រើន ដែលប្រជាជនធ្វើសកម្មភាពដើម្បីរកស៊ីចិញ្ចឹមជីវិត (ដោយមិនរាប់ចូលសកម្មភាពកសិកម្ម និងមុខរបរអាជីពដូចជា គ្រូពេទ្យ គ្រូបង្រៀន ប៉ូលីស ទាហ៊ាន ... ជាដើម)។ ក្នុងចំណោមសកម្មភាពអាជីវកម្មទាំងអស់នោះ យើងបានជ្រើសរើសសកម្មភាពអាជីវកម្មសំខាន់ៗមួយចំនួនដើម្បីយកមកបង្ហាញសម្រាប់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។

## ក. សកម្មភាពអាជីវកម្ម

*តារាងទី១៧៖ សកម្មភាពអាជីវកម្មចម្បងតាមគ្រួសារ*

| សកម្មភាពអាជីវកម្ម | ចំនួនគ្រួសារ | |
|---|---|---|
| | កំពង់ធំ | ឧត្តរមានជ័យ |
| ម៉ាស៊ីនកិនស្រូវ | ៣.៧៩៦ | ៣៦៨ |
| លក់ និងជួសជុលម៉ូតូ/កង់ | ១.៣៧២ | ៥០៦ |
| លក់ និងជួសជុលរថយន្ត | ២៨៨ | ៨០ |
| លក់ និងជួសជុលឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្ម | ១៥៨ | ១៤០ |
| លក់ និងជួសជុលគ្រឿងអេឡិចត្រូនិច | ២៦២ | ១០៤ |
| លក់ និងផលិតគ្រឿងសង្ហារិមពីឈើ | ២៦០ | ២២៦ |
| លក់ និងផលិតគ្រឿងសង្ហារិមពីស៊ីម៉ងត៍ | ៩៦ | ២៦ |
| លក់ និងផលិតគ្រឿងសង្ហារិមពីដែក/អ៊ីណុក | ៩០ | ២៦ |
| បិតស្រា | ៨០៨ | ២៨៨ |
| ហាងកាត់សក់/អ៊ុតសក់/កែសម្ផស្ស | ៨៩៨ | ២៦៨ |
| ហាងលក់គ្រឿងទេស និងភេសជ្ជៈ | ៦.៩៦៦ | ២.៩៤៤ |
| ហាងលក់ថ្នាំពេទ្យ និងគ្លីនិក | ៥៨០ | ១៣៨ |
| សណ្ឋាគារ/ផ្ទះសំណាក់ | ១០៨ | ៥២ |
| ភោជនីយដ្ឋាន | ៦៨ | ០៨ |
| ស្ថានីយ៍ប្រេងឥន្ធនៈ | ២៦០ | ១៨៨ |
| តូបលក់សាំង | ៣.៩២៦ | ២២០ |
| លក់គ្រឿងសំណង់ | ២៨០ | ៧៤ |
| កាត់កញ្ចក់/ជាងដែក | ១៤៤ | ៤០ |
| អាជីវកម្មផ្សេងៗទៀត | ១.២២៨ | ២០ |
| ***សរុប*** | ***២១.៥៨៨*** | ***៥.៧១៦*** |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ក្រៅពីការប្រកបរបរកសិកម្ម និងមុខរបរអាជីព ការធ្វើអាជីវកម្មបានដើរតួបន្ថែមយ៉ាងសំខាន់ក្នុងការលើកស្ទួយជីវភាពគ្រួសារ។ តាមតារាងទី១៧ ឃើញថា នៅក្នុងខេត្តកំពង់ធំមានរបរអាជីវកម្មចំនួន ២១.៥៨៨គ្រួសារ (ស្មើនឹង១១,៨%) ដែលភាគច្រើនគ្រួសារទាំងនោះធ្វើទៅលើការលក់ចាប់ហួយ/គ្រឿងទេស/ភេសជ្ជៈ (៦.៩៦៦គ្រួសារ) បន្ទាប់មក គឺលក់សាំងដប (៣.៩២៦គ្រួសារ) ខណៈដែលភោជនីយដ្ឋានមានតិចតួចបំផុត (៦៨គ្រួសារ)។ ខេត្តឧត្តរមានជ័យ មានរបរអាជីវកម្មចំនួន ៥.៧១៦គ្រួសារ (ស្មើនឹង ៩,៤%) ដែលភាគច្រើនគ្រួសារទាំងនោះធ្វើទៅលើការលក់ចាប់ហួយ/គ្រឿងទេស/ភេសជ្ជៈ (២.៩៤៤ គ្រួសារ) បន្ទាប់មក គឺលក់និងជួសជុលម៉ូតូ/កង់ (៥០៦គ្រួសារ) ខណៈដែលភោជនីយដ្ឋានមានតិចតួចបំផុត (៨គ្រួសារ)។

## ខ. អ្នកធ្វើការក្នុងអាជីវកម្ម




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៥៖ និយាយពីចំនួនអ្នកធ្វើការក្នុងអាជីវកម្ម។ យើងឃើញថា ខេត្តកំពង់ធំ មានចំនួនអ្នកធ្វើការក្នុងអាជីវកម្មសរុប ៣៤.៥៤០នាក់ ក្នុងនោះមានស្រី ១៧.៩៧០នាក់ ស្មើនឹង ៥២% ខណៈដែលខេត្តឧត្តរមានជ័យមានចំនួនអ្នកធ្វើការក្នុងអាជីវកម្មសរុប ១១.២៥៦នាក់ (ក្នុងនោះស្រី ៥.៤១៨ នាក់ ស្មើនឹង ៤៨%)។ ជាមធ្យមខេត្តទាំងពីរមានមនុស្សប្រមាណជា ២នាក់ ធ្វើការក្នុងមួយអាជីវកម្ម ឬមួយកន្លែង។

## ២.៨. វិស័យអប់រំ និងសេវាសង្គម

### ២.៨.១. វិស័យអប់រំ

វិស័យអប់រំនៅក្នុងសៀវភៅនេះ គឺគ្រាន់តែសំដៅលើចំនួនគ្រឹះស្ថានសិក្សា និងចម្ងាយពីទីតាំងភូមិទៅកន្លែងផ្តល់សេវាអប់រំទាំងនោះតែប៉ុណ្ណោះ។ គ្រឹះស្ថានសិក្សាមានតាមកម្រិតដូចជា៖ មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យ (ទាំងរដ្ឋ និងឯកជន)។

#### ក. គ្រឹះស្ថានសិក្សា

*តារាងទី១៨៖ ចំនួនគ្រឹះស្ថានសិក្សាបែងចែកតាមវិស័យ*

| កម្រិតអប់រំ | កំពង់ធំ | | | ឧត្តរមានជ័យ | | |
|---|---|---|---|---|---|---|
| | រដ្ឋ | ឯកជន | សហគមន៍ | រដ្ឋ | ឯកជន | សហគមន៍ |
| មត្តេយ្យសិក្សា | ២៨០ | ១៦ | ៩៤ | ១៣០ | ៦ | ៤២ |
| បឋមសិក្សា | ៤៣៦ | ១០ | ០ | ១៩៤ | ១០ | ០ |
| អនុវិទ្យាល័យ | ៧៦ | ២ | ០ | ២៤ | ០ | ០ |
| វិទ្យាល័យ | ១៦ | ២ | ០ | ៦ | ០ | ០ |
| សាកលវិទ្យាល័យ | ២ | ០ | ០ | ០ | ០ | ០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី១៨ បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមកម្រិត និងបានបែងចែកទៅតាមវិស័យនីមួយៗ។ ចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា នៅខេត្តកំពង់ធំ មានគ្រឹះស្ថានសិក្សាចំនួន ៩៣៤កន្លែង ក្នុងនោះ មត្តេយ្យសិក្សាមានចំនួន ៣៩០កន្លែង (សាលារដ្ឋមាន២៨០កន្លែង ឯកជនមាន១៦កន្លែង និងសាលាសហគមន៍មាន៩៤កន្លែង) បឋមសិក្សាមានចំនួន ៤៤៦កន្លែង (សាលារដ្ឋមាន៤៣៦កន្លែង និងឯកជនមាន១០កន្លែង) អនុវិទ្យាល័យមានចំនួន ៧៨កន្លែង (សាលារដ្ឋមាន៧៦កន្លែង និងឯកជនមាន២កន្លែង) វិទ្យាល័យមានចំនួន ១៨កន្លែង (សាលារដ្ឋមាន១៦កន្លែង និងឯកជនមាន២កន្លែង) និងសាកលវិទ្យាល័យរដ្ឋចំនួន ២កន្លែង។ ខេត្តឧត្តរមានជ័យ មានគ្រឹះស្ថានសិក្សាចំនួន ៤១២កន្លែង ក្នុងនោះមានមត្តេយ្យសិក្សាចំនួន ១៧៨កន្លែង (សាលារដ្ឋមាន១៣០កន្លែង ឯកជនមាន៦កន្លែង និងសាលាសហគមន៍មាន៤២កន្លែង) បឋមសិក្សាមានចំនួន ២០៤កន្លែង (សាលារដ្ឋមាន១៩៤កន្លែង និងឯកជនមាន១០កន្លែង) អនុវិទ្យាល័យរដ្ឋមានចំនួន ២៤កន្លែង និងវិទ្យាល័យរដ្ឋមានចំនួន ៦កន្លែងផងដែរ។

## ខ. ចម្ងាយពីភូមិទៅសាលារៀន

ចម្ងាយជាមធ្យមពីភូមិទៅគ្រឹះស្ថានសិក្សា គឺជាចម្ងាយដែលគិតពីចំណុចកណ្ដាលភូមិមួយ ទៅភូមិណាមួយផ្សេងទៀតដែលមានទីតាំងសាលារៀន ដោយមិនបានរាប់បញ្ចូលទីតាំងសាលារៀនណាដែលមានជាក់ស្ដែងនៅក្នុងភូមិនោះឡើយ។

*តារាងទី១៩៖ ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងគ្រឹះស្ថានសិក្សាដែលជិតបំផុត (គិតជាគីឡូម៉ែត្រ)*

| កម្រិតអប់រំ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មត្តេយ្យសិក្សា | ១ | ១ | ១ | ១ |
| បឋមសិក្សា | ១ | ១ | ១ | ១ |
| អនុវិទ្យាល័យ | ៤ | ៤ | ៦ | ៦ |
| វិទ្យាល័យ | ៩ | ៩ | ១៦ | ១៦ |
| សាកលវិទ្យាល័យ | ៥១ | ៥១ | ១១៥ | ១១៥ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តាមតារាងទី១៩បានបង្ហាញថា៖ កាលពី៥ឆ្នាំមុន រហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងគ្រឹះស្ថានសិក្សាដែលនៅជិតបំផុតគឺគ្មានការប្រែប្រួលទេ។ ខេត្តកំពង់ធំ បើគិតពីចំណុចកណ្ដាលភូមិទៅមត្តេយ្យសិក្សា និងបឋមសិក្សាមានចម្ងាយ១គ.ម. ទៅអនុវិទ្យាល័យមានចម្ងាយ៤គ.ម. ទៅវិទ្យាល័យមានចម្ងាយ៩គ.ម. និងពីភូមិទៅសាកលវិទ្យាល័យមានចម្ងាយ៥១គ.ម.។ ខេត្តឧត្តរមានជ័យ ពីចំណុចកណ្ដាលភូមិទៅមត្តេយ្យសិក្សា និងបឋមសិក្សាមានចម្ងាយ១គ.ម. ទៅអនុ វិទ្យាល័យមានចម្ងាយ៦គ.ម. ទៅវិទ្យាល័យមានចម្ងាយ១៦គ.ម. និងពីភូមិទៅសាកលវិទ្យាល័យមានចម្ងាយ១១៥គ.ម. (មករៀននៅខេត្តសៀមរាប)។

### ២.៨.២. សេវាសង្គម

ចម្ងាយមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គម ក៏មានន័យមិនខុសគ្នាពីចម្ងាយមធ្យមពីភូមិទៅកាន់គ្រឹះស្ថានសិក្សាដែរ ពោលគឺគិតពីចំណុចកណ្តាលនៃភូមិមួយ ទៅភូមិណាមួយផ្សេងទៀតដែលមានទីតាំងផ្តល់សេវាទាំងនោះ ដោយមិនបានរាប់បញ្ចូលទីតាំងផ្តល់សេវាណាដែលមានជាក់ស្តែងនៅក្នុងភូមិនោះឡើយ។

*តារាងទី២០៖ ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គមដែលជិតបំផុត (គិតជាគីឡូម៉ែត្រ)*

| សេវាសង្គម | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មន្ទីរពេទ្យ | ២៨ | ២៨ | ២៩ | ២៩ |
| មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព | ៦ | ៦ | ៧ | ៧ |
| គ្លីនិកឯកជន | ១២ | ១២ | ១៦ | ១៦ |
| មណ្ឌលពាណិជ្ជកម្ម/ផ្សារ | ១០ | ១០ | ១២ | ១២ |
| ប៉ុស្តិ៍នគរបាល | ៤ | ៤ | ៩ | ៩ |
| សាលាឃុំ | ៤ | ៤ | ៩ | ៩ |
| ប្រៃសណីយ៍/អ៊ីនធឺណែតកាហ្វេ | ១១ | ១១ | ១៥ | ១៥ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២០បានបង្ហាញថា៖ កាលពី៥ឆ្នាំមុន រហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមពីចំណុចកណ្តាលភូមិទៅកាន់កន្លែងផ្តល់សេវាសង្គមគឺមានការផ្លាស់ប្តូរឡើយ។ ខេត្តកំពង់ធំ បើគិតពីចំណុចកណ្តាលភូមិទៅដល់ទីតាំងជិតបំផុតដែលមានមន្ទីរពេទ្យគឺមានចម្ងាយ២៨គ.ម. ទៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមានចម្ងាយ៦គ.ម. ទៅគ្លីនិកឯកជនមានចម្ងាយ១២គ.ម. ទៅមណ្ឌលពាណិជ្ជកម្ម/ផ្សារមានចម្ងាយ១០គ.ម. ទៅប៉ុស្តិ៍នគរបាល/សាលាឃុំមានចម្ងាយ៤គ.ម. និងពីចំណុចកណ្តាលភូមិទៅដល់ប្រៃសណីយ៍/អ៊ីនធឺណែតកាហ្វេមានចម្ងាយ១២គ.ម.។ ខេត្តឧត្តរមានជ័យ ពីចំណុចកណ្តាលភូមិទៅដល់មន្ទីរពេទ្យមានចម្ងាយ២៩គ.ម. ទៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមានចម្ងាយ៧គ.ម. ទៅ គ្លីនិកឯកជនមានចម្ងាយ១៦គ.ម. ទៅមណ្ឌលពាណិជ្ជកម្ម/ផ្សារមានចម្ងាយ១២គ.ម. ទៅប៉ុស្តិ៍នគរបាល/សាលាឃុំមានចម្ងាយ៩គ.ម. និងពីចំណុចកណ្តាលភូមិទៅដល់ប្រៃសណីយ៍/អ៊ីនធឺណែតកាហ្វេមានចម្ងាយ១៥គ.ម.។

## ២.៩. ផ្លូវគមនាគមន៍

ផ្លូវគមនាគមន៍ គឺសំដៅលើផ្លូវថ្នល់សម្រាប់ធ្វើដំណើរទៅមក។ រូបភាពខាងក្រោមនឹងបង្ហាញពីប្រវែងផ្លូវថ្នល់ដូចជា ផ្លូវដី ផ្លូវគ្រួស និងផ្លូវបេតុង ឬផ្លូវកៅស៊ូ ដែលបានស្ថាបនាក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

*រូបភាពទី២៦៖ ការស្ថាបនាផ្លូវថ្នល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (គិតជាគីឡូម៉ែត្រ)*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៦ បានបង្ហាញពីការស្ថាបនាផ្លូវថ្នល់នៅទូទាំងខេត្តទាំងពីរ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ (២០១៨-២០២២) រដ្ឋបាលខេត្តកំពង់ធំស្ថាបនាផ្លូវថ្នល់ (ធ្វើថ្មី និងជួសជុល) សរុបបានប្រវែង ១៨.៩៩៧គ.ម. ដែលភាគច្រើនជាផ្លូវគ្រួស (ប្រវែង ១២.៦៧៤គ.ម.) ខណៈដែលផ្លូវកៅស៊ូបានប្រវែង ៣.៩៨៥គ.ម. ផ្លូវដីប្រវែង២.២១០គ.ម. និងផ្លូវបេតុងបានប្រវែង១២៧គ.ម.។ រដ្ឋបាលខេត្តឧត្តរមានជ័យស្ថាបនាផ្លូវថ្នល់ (ធ្វើថ្មី និងជួសជុល) សរុបបានប្រវែង ៤១.៦៧៧គ.ម. ដែលភាគច្រើនជាផ្លូវគ្រួស (ប្រវែង ២៤.៨៦១គ.ម.) បន្ទាប់មកគឺផ្លូវដី (ប្រវែង១៦.៧៥៩គ.ម.) ខណៈដែលផ្លូវកៅស៊ូ និងផ្លូវបេតុងស្ថាបនាបានប្រវែង៥៧គ.ម.។

## ២.១០. សុខាភិបាល

### ២.១០.១. សេវាកម្មសុខភាព

សេវាកម្មសុខភាព គឺសំដៅលើទីតាំង ភ្នាក់ងារ និងភាពទទួលបានសេវាកម្មសុខភាពរបស់ប្រជាពលរដ្ឋ។

#### ក. ទីតាំងផ្តល់សេវាកម្មសុខភាព

*រូបភាពទី២៧៖ ចំនួនទីតាំងផ្តល់សេវាកម្មសុខភាព*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៧ បានបង្ហាញពីចំនួនទីតាំងផ្តល់សេវាកម្មសុខភាពនៅទូទាំងខេត្ត។ យើងឃើញថាខេត្តកំពង់ធំ មានមន្ទីរពេទ្យរដ្ឋចំនួន ១.៤០២កន្លែង មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមាន ១.២៩៤កន្លែង ខណៈដែលគ្លីនិកឯកជន/ឱសថស្ថានមានត្រឹមតែ ៥៨០កន្លែងប៉ុណ្ណោះ។ តួលេខវិស័យសុខាភិបាលសាធារៈរបស់រដ្ឋ និងវិស័យឯកជនក្នុងខេត្តនេះ វាផ្ទុយពីខេត្តឧត្តរមានជ័យ ដែលវិស័យឯកជនមានចំនួន ១៣៨កន្លែង ឯវិស័យសាធារណៈរបស់រដ្ឋមានតែ ៤០កន្លែងប៉ុណ្ណោះ។

### ខ. ភ្នាក់ងារផ្តល់សេវាកម្មសុខភាព




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៧ គឺជាចំនួនភ្នាក់ងារផ្តល់សេវាកម្មសុខភាពនៅទូទាំងខេត្ត។ តាមរូបភាពនេះ ខេត្តកំពង់ធំ មានវេជ្ជបណ្ឌិតចំនួន ១៥៦នាក់ ពេទ្យមធ្យមចំនួន ៣៤៤នាក់ គិលានុបដ្ឋាយិកា/ឆ្មបមានចំនួន ១២២នាក់ និងឆ្មបបុរាណមានចំនួន ៨៨នាក់។ ខេត្តឧត្តរមានជ័យ មានវេជ្ជបណ្ឌិតចំនួន ៨៤នាក់ ពេទ្យមធ្យមចំនួន ១១៦នាក់ គិលានុបដ្ឋាយិកា/ឆ្មបមានចំនួន ៤៨នាក់ និងឆ្មបបុរាណមានចំនួន ២៦នាក់។

## ២.១០.២. ជំងឺសំខាន់ៗ

### ក. ជំងឺគ្រុនចាញ់




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៨ បានបង្ហាញពីចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺគ្រុនចាញ់។ យើងឃើញថា ខេត្តកំពង់ធំ មានជនរងគ្រោះសរុបចំនួន ១៥០នាក់ (ស្រី ៥០នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន ៦នាក់ (ស្រី ០នាក់) ស្មើនឹង ៤%។ ខេត្តឧត្តរមានជ័យ មានជនរងគ្រោះសរុបចំនួន ២៦នាក់ (ស្រី ១០នាក់) ក្នុងនោះមិនមានអ្នករងគ្រោះរហូតដល់ស្លាប់ទេ។

## ខ. ជំងឺរបេង




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី២៩ បានបង្ហាញពីចំនួនអ្នកកើត និងស្លាប់ដោយសារជំងឺរបេង។ យើងឃើញថា ខេត្តកំពង់ធំ មានជនរងគ្រោះសរុបចំនួន ៥៨០នាក់ (ស្រី ២៩០នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន ៣០នាក់ (ស្រី ៤នាក់) ស្មើនឹង ៥%។ ខេត្តឧត្តរមានជ័យ មានជនរងគ្រោះសរុបចំនួន ២៧៤នាក់ (ស្រី ១២៤នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន ២៤នាក់ (ស្រី ១៤នាក់) ស្មើនឹង ៩%។

## គ. ជំងឺអេដស៍

*រូបភាពទី៣០៖ ចំនួនភេទអ្នកកើត និងស្លាប់ដោយសារជំងឺអេដស៍តាមក្រុមអាយុ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣០ បានបង្ហាញពីការបែងចែកទៅតាមភេទ និងក្រុមអាយុនៃអ្នកកើត និងស្លាប់ដោយសារជំងឺអេដស៍។ យើងឃើញថា គ្រប់ក្រុមអាយុទាំងអស់មនុស្សភេទស្រីមានអត្រាកើត និងស្លាប់ដោយសារជំងឺអេដស៍ខ្ពស់ជាងមនុស្សភេទប្រុស (លើកលែងតែក្រុមអាយុពី ០-១៧ឆ្នាំ សម្រាប់ខេត្តកំពង់ធំ)។ ខេត្តកំពង់ធំ មានអ្នកកើតជំងឺនេះសរុប ៤៣០នាក់ (ស្លាប់ចំនួន ៣៨នាក់ ក្នុងនោះមានអ្នកស្រី ២៤នាក់) ដែលភាគច្រើនគឺជាមនុស្សស្រីមានវ័យពី ២៦-៥៩ឆ្នាំ។ ខេត្តឧត្តរមានជ័យ មានអ្នកកើតជំងឺនេះចំនួន ១៨២នាក់ (ស្លាប់ចំនួន ២៨នាក់ ក្នុងនោះស្រី ២០នាក់) ដែលភាគច្រើនគឺជាមនុស្សស្រីមានវ័យពី ២៦-៥៩ឆ្នាំ។

## ២.១០.៣. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និងកុមារកំព្រា

### ក. ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ

*រូបភាពទី៣១៖ ចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារ និងកុមារកំព្រាមានឪពុកម្តាយស្លាប់ដោយសារជំងឺអេដស៍*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣១ បានបង្ហាញពីចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារ និងកុមារកំព្រាដោយមានឪពុកម្តាយស្លាប់ដោយសារជំងឺអេដស៍។ យើងឃើញថា ខេត្តទាំងពីរមានអ្នកកំពុងផ្ទុក/កើតជំងឺអេដស៍ ៥៤៦នាក់ (កំពង់ធំ ៣៩២នាក់ និងឧត្តរមានជ័យ ១៥៤នាក់) ដែលអ្នកខ្លះរស់នៅម្នាក់ឯង និងអ្នកខ្លះទៀតរស់នៅជាមួយក្រុមគ្រួសារ។ យ៉ាងណាមិញ តាមរូបភាពខាងលើបានបញ្ជាក់ថា ខេត្តកំពង់ធំ មានមនុស្សចំនួន ៣៦៤នាក់ ដែលជាសមាជិកគ្រួសាររបស់អ្នកជំងឺអេដស៍ និង ៦០នាក់ ជាកុមារកំព្រាដោយឪពុកម្តាយរបស់ខ្លួនស្លាប់ដោយសារជំងឺអេដស៍ ដែលបានរងផលប៉ះពាល់ និងកំពុងរស់នៅជាមួយគ្នា។ រូបភាពនេះក៏បានបង្ហាញផងដែរថា ខេត្តឧត្តរមានជ័យ មានមនុស្សចំនួន ២៤០នាក់ ដែលជាសមាជិកគ្រួសាររបស់អ្នកជំងឺអេដស៍ និង ២៦នាក់ ជាកុមារកំព្រាដោយឪពុកម្តាយរបស់ខ្លួនស្លាប់ដោយសារជំងឺអេដស៍ ដែលបានរងផលប៉ះពាល់ និងកំពុងរស់នៅជាមួយគ្នា។

### ខ. កុមារកំព្រា

*រូបភាពទី៣២៖ ចំនួនកុមារកំព្រាក្រោមអាយុ១៨ឆ្នាំ*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣២ គឺជាចំនួនកុមារកំព្រាក្រោមអាយុ១៨ឆ្នាំ។ តាមរូបភាពនេះបានបង្ហាញថា នៅក្នុងខេត្តកំពង់ធំ មានកុមារកំព្រាសរុបចំនួន ៦៣៤នាក់ ដែលក្នុងនោះ ៥៥៨នាក់ ជាកុមារកំព្រាដែលមានអ្នកមើលថែត្រឹមត្រូវ និង ៧៦នាក់ ជាកុមារកំព្រាគ្មានអ្នកមើលថែត្រឹមត្រូវ។ ខេត្តឧត្តរមានជ័យ មានកុមារកំព្រាសរុបចំនួន ៣០៦នាក់ ដែលក្នុងនោះ ២៦០នាក់ ជាកុមារកំព្រាដែលមានអ្នកមើលថែត្រឹមត្រូវ និង ៤៦នាក់ ជាកុមារកំព្រាគ្មានអ្នកមើលថែត្រឹមត្រូវ។

## ២.១១. កសិកម្ម

កសិកម្ម គឺមិនសំដៅទៅលើការដាំដុះតែម៉្យាងនោះទេ វាសំដៅលើការចិញ្ចឹមសត្វ វារីវប្បកម្ម និងការនេសាទផងដែរ។ តាមរបាយការណ៍ជំរឿនប្រជាជនឆ្នាំ២០១៩ បានបញ្ជាក់ថា សេដ្ឋកិច្ចប្រទេស កម្ពុជាបច្ចុប្បន្នបានពឹងលើវិស័យសំខាន់បីគឺ៖ វិស័យកសិកម្ម ៥៣,៤% វិស័យផលិតកម្ម ឬឧស្សាហកម្ម ១៦,៦% និងវិស័យសេវាកម្ម ១២,៦%។ នៅឆ្នាំ២០២២ ខេត្តកំពង់ធំមានផ្ទៃដីសម្រាប់ធ្វើកសិកម្មប្រមាណ ៤៣៩.១៥៣ហិកតា រីឯខេត្តឧត្តរមានជ័យមានប្រមាណជា ២៦៧.០៨៤ហិកតា។

### ២.១១.១. ការកាន់កាប់ដីកសិកម្ម

ដីកសិកម្ម គឺសំដៅទៅលើដីដែលគ្រួសារបានកាន់កាប់ធ្វើជាម្ចាស់កម្មសិទ្ធិផ្ទាល់ខ្លួន ឬបានប្រើប្រាស់ដូចជា ដីជួលពីគេ ដីជួលឱ្យគេ ដីប្រើប្រាស់មិនគិតថ្លៃ...ជាដើម ដើម្បីប្រើប្រាស់សម្រាប់ដាំដំណាំ ឬក៏ប្រើប្រាស់សម្រាប់ការងារកសិកម្មផ្សេងៗទៀត។

*តារាងទី២១៖ ការកាន់កាប់ផ្ទៃដីកសិកម្មតាមគ្រួសារ*

| ផ្ទៃដីកសិកម្ម | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | ភាគរយ | គ្រួសារ | ភាគរយ |
| គ្មានដី | ២៧.៩៤៨ | ១៥ | ១០.៨២៤ | ១៨ |
| ក្រោម១ហិកតា | ៧៥.៧៩៤ | ៤១ | ៦.៥០៦ | ១១ |
| ១-១.៩៩ហិកតា | ៣៤.១៨៦ | ១៩ | ៩.៣៩២ | ១៥ |
| ២-២.៩៩ហិកតា | ១៨.៤៥៨ | ១០ | ៩.៥៣៨ | ១៦ |
| ៣-៣.៩៩ហិកតា | ១២.០៦២ | ៧ | ៨.២១២ | ១៤ |
| ៤-៤.៩៩ហិកតា | ៨.២៤២ | ៤ | ៦.៨៧៤ | ១១ |
| ៥ហិកតាឡើង | ៦.៦៧៤ | ៤ | ៩.២៨២ | ១៥ |
| សរុប | ១៨៣.៣៦៤ | ១០០ | ៦០.៦២៨ | ១០០ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២១បានបង្ហាញថា៖ ខេត្តកំពង់ធំ គ្រួសារភាគច្រើនមានក្បាលដីកាន់កាប់សម្រាប់ធ្វើកសិកម្ម (៨៥%) ហើយក៏មានគ្រួសារមួយចំនួនតូច (១៥%) គ្មានដីប្រើប្រាស់សម្រាប់ធ្វើកសិកម្មផងដែរ ដែលពួកគាត់អាចជាគ្រួសាររស់នៅទីប្រជុំជនមានមុខរបរលក់ដូរតាមផ្ទះ លក់ដូរនៅផ្សារ ឬធ្វើការងារផ្សេងៗ។ ភាគច្រើននៃគ្រួសារទាំងនោះ (៧៥.៧៩៤គ្រួសារ ស្មើនឹង៤១%) មានដីកាន់កាប់សម្រាប់ធ្វើកសិកម្មទំហំតិចជាង១ហិកតា ខណៈដែលគ្រួសារមានដីកសិកម្មចាប់ពី៥ហិកតាឡើងទៅមានចំនួនតិចជាងគេ គឺត្រឹមតែ ៤% (៦.៦៧៤គ្រួសារ) ប៉ុណ្ណោះ។ ខេត្តឧត្តរមានជ័យ គ្រួសារមានក្បាលដីកាន់កាប់សម្រាប់ធ្វើកសិកម្ម ៨២% និង ១៨% ទៀត គ្មានដីសម្រាប់ធ្វើកសិកម្ម។ ភាគច្រើននៃគ្រួសារទាំងនោះ (៩.៥៣៨គ្រួសារ ស្មើនឹង ១៦%) មានដីកាន់កាប់សម្រាប់ធ្វើកសិកម្មទំហំពី ២ ទៅ ២.៩៩ហិកតា ខណៈដែលគ្រួសារមានដីសម្រាប់ធ្វើកសិកម្មក្រោម១ហិកតាមានចំនួនតិចជាងគេ គឺមានត្រឹម ១១% (៦.៥០៦ គ្រួសារ) តែប៉ុណ្ណោះ។

### ២.១១.២. ផ្ទៃដីកសិកម្ម និងផលិតកម្ម

ផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជាត្រូវបានចែកដីជាពីរប្រភេទគឺ ប្រភេទដីស្ងួត និងប្រភេទដីសើម។ ចំណែកឯរដូវវិញក៏មានពីរដែរគឺ រដូវប្រាំង និងរដូវវស្សា។ តារាងខាងក្រោមនឹងបង្ហាញពីចំនួនផ្ទៃដីកសិកម្ម និងចំនួនផ្ទៃដីដែលបានបង្កបង្កើនផលដោយបែងចែងទៅតាមប្រភេទរដូវនីមួយៗ៖

*តារាងទី២២៖ ចំនួនផ្ទៃដីកសិកម្ម និងផ្ទៃដីបានដាំដុះតាមប្រភេទរដូវ (គិតជាហិកតា)*

| បរិយាយ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ផ្ទៃដីកសិកម្ម | ផ្ទៃដីបានដាំដុះ | ផ្ទៃដីកសិកម្ម | ផ្ទៃដីបានដាំដុះ |
| រដូវប្រាំង | ៩៤.៥៤២ | ៨៨.៥៦០ | ១១២.២៨២ | ១១១.៣៦៤ |
| រដូវវស្សា | ១៦១.៧០១ | ១៤៨.៨៧៣ | ១៤៦.៨៣៦ | ១៤២.៧៨៤ |
| ទាំងពីររដូវ | ១៨២.៩០៩ | ១៧៦.៨៩០ | ៧.៩៦៦ | ៧.៩៦៦ |
| សរុប | ៤៣៩.១៥៣ | ៤១៤.៣២៣ | ២៦៧.០៨៤ | ២៦២.១១៤ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២២ គឺជាចំនួនផ្ទៃដីកសិកម្ម និងផ្ទៃដីដែលបានដាំដុះទៅតាមប្រភេទរដូវនីមួយៗ។ នៅខេត្តកំពង់ធំមានផ្ទៃដីកសិកម្មសរុប ៤៣៩.១៥៣ហិកតា ក្នុងនោះផ្ទៃដីកសិកម្មដែលអាចបង្កបង្កើនផលបានតែនៅរដូវប្រាំងមាន ៩៤.៥៤២ហិកតា ស្មើនឹង ២១,៥% (ដាំដុះបាន ៨៨.៥៦០ហិកតា) សម្រាប់តែរដូវវស្សាមាន ១៦១.៧០១ហិកតា ស្មើនឹង ៣៦,៨% (ដាំដុះបាន ១៤៨.៨៧៣ហិកតា) និងផ្ទៃដីដែលអាចបង្កបង្កើនផលបានទាំងពីររដូវមាន ១៨២.៩០៩ហិកតា ស្មើនឹង ៤១,៧% (ដាំដុះបាន ១៧៦.៨៩០ហិកតា)។ ខេត្តឧត្តរមានជ័យមានផ្ទៃដីកសិកម្មសរុប ២៦៧.០៨៤ហិកតា ក្នុងនោះផ្ទៃដីកសិកម្មដែលអាចបង្កបង្កើនផលបានតែនៅរដូវប្រាំងមាន ១១២.២៨២ហិកតា ស្មើនឹង ៤២% (ដាំដុះបាន ១១១.៣៦៤ហិកតា) សម្រាប់តែរដូវវស្សាមាន ១៤៦.៨៣៦ហិកតា ស្មើនឹង ៥៥% (ដាំដុះបាន ១៤២.៧៨៤ហិកតា) និងផ្ទៃដីដែលអាចបង្កបង្កើនផលបានទាំងពីររដូវមាន ៧.៩៦៦ហិកតា ស្មើនឹង ៣% (ដាំដុះបានទាំងអស់)។

## ២.១១.៣. ប្រព័ន្ធស្រោចស្រព

*រូបភាពទី៣៣៖ ចំនួនផ្ទៃដីដាំដំណាំមាន និងគ្មានប្រព័ន្ធស្រោចស្រព (គិតជាហិកតា)*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣៣បានបង្ហាញថា៖ ខេត្តកំពង់ធំ ប្រជាពលរដ្ឋបានដាំស្រូវលើផ្ទៃដី ២៣១.២៥១ហិកតា (៥៦%) ខណៈដែលដាំដំណាំផ្សេងៗទៀតមាន ១៨៣.០៧២ហិកតា (៤៤%)។ ក្នុងចំណោមផ្ទៃដីដែលបានដាំដំណាំទាំងអស់ មានតែ១១៤.៣៤០ហិកតា ស្មើនឹង២៨% ទេ ដែលមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់។ ខេត្តឧត្តរមានជ័យ ប្រជាពលរដ្ឋបានដាំដំណាំផ្សេងៗចំនួន ១៣៦.៥០២ហិកតា ច្រើនជាងដំណាំស្រូវ ៤%។ ក្នុងចំណោមផ្ទៃដីដែលបានដាំដំណាំទាំងអស់ក្នុងខេត្តនេះ មានតែ ៦.៧១០ហិកតា ស្មើនឹង ៣% ទេ ដែលមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់។

## ២.១១.៤. ការប្រើប្រាស់ជី និងថ្នាំពុលលើផ្ទៃដីផលិតកម្ម

### ក. ការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្ម

*រូបភាពទី៣៤៖ ភាគរយនៃការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្ម*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣៤បង្ហាញថា៖ ខេត្តកំពង់ធំ ប្រជាពលរដ្ឋបានប្រើប្រាស់ជីគីមីលើផ្ទៃដីផលិតកម្មរហូតដល់ ៨៥% ខណៈដែលការប្រើប្រាស់ជីសរីរាង្គមាន១៥%។ រីឯខេត្តឧត្តរមានជ័យវិញ ក៏មិនខុសពីខេត្តកំពង់ធំដែរ ប្រជាពលរដ្ឋច្រើនលើសលុប (៩៣%) បានប្រើប្រាស់ជីគីមីទៅលើការដាំដំណាំ ខណៈដែលការប្រើប្រាស់ជីសរីរាង្គមានត្រឹមតែ ៧% ប៉ុណ្ណោះ។

### ខ. ការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្ម

*រូបភាពទី៣៥៖ ការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្ម (គិតជាហិកតា)*




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

ទន្ទឹមនឹងការប្រើប្រាស់ជីទាំងពីរប្រភេទខាងលើ តាមរូបភាពទី៣៥ ក៏បានបង្ហាញនូវការប្រើប្រាស់ថ្នាំពុលលើដំណាំកសិកម្មផងដែរ។ យើងឃើញថា ផ្ទៃដីផលិតកម្មទាំងអស់នៅក្នុងខេត្តកំពង់ធំ ការប្រើប្រាស់ថ្នាំសម្លាប់ស្មៅទៅលើដំណាំផ្សេងៗក្រៅពីស្រូវមានចំនួនច្រើនជាងគេ គឺ ១៤៥.០៤៨ហិកតា ខណៈដែលការប្រើប្រាស់លើដំណាំស្រូវមាន ១២៨.៨៦៦ហិកតា។ បន្ទាប់ពីនេះ គឺការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃទៅលើដំណាំក្រៅពីស្រូវ ដែលមាន ១៣៤.២៣៦ហិកតា ខណៈដែលដំណាំស្រូវមានចំនួន ១២៣.៣៧២ហិកតា ចំណែកឯថ្នាំសម្លាប់ផ្សិតវិញ គឺត្រូវបានប្រើប្រាស់ទៅលើផ្ទៃដីចំនួន ៣២.១៩៦ហិកតា (ដំណាំស្រូវចំនួន ២៤.៨១២ហិកតា និងដំណាំក្រៅពីស្រូវចំនួន ៧.៣៨៤ហិកតា)។

## ២.១១.៥. ការចិញ្ចឹមបសុសត្វ និងបសុបក្សី

### ក. បសុសត្វ

*តារាងទី២៣៖ ចំនួនគ្រួសារចិញ្ចឹមបសុសត្វ*

| បសុសត្វ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បសុសត្វ | គ្រួសារ | បសុសត្វ |
| គោ | ៥២.៥១៦ | ១៧២.៤២២ | ៩.០១៨ | ៤៣.៧២០ |
| ក្របី | ១២.៩៤០ | ៨៧.៤៣៨ | ២២៤ | ១.៨៥២ |
| សេះ | ៧៦ | ១៩៦ | ០ | ០ |
| ជ្រូក | ១១.៧០៤ | ៥៥.០៣០ | ៥.២៣៨ | ២២.១១៤ |
| ពពែ/ចៀម | ១.៨៥៨ | ៦.២១៤ | ៤១៤ | ៣.១៦៦ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២៣ បង្ហាញពីចំនួនបសុសត្វដែលបានចិញ្ចឹមតាមគ្រួសារ។ តាមតារាងនេះយើងឃើញថា នៅក្នុងខេត្តកំពង់ធំ ការចិញ្ចឹមគោគឺឈរនៅលំដាប់ខ្ពស់ទី១ ដែលមានចំនួន ១៧២.៤២២ក្បាល ត្រូវបានចិញ្ចឹមក្នុង ៥២.៥១៦គ្រួសារ ស្មើនឹង២៨,៦% នៃគ្រួសារសរុប (ជាមធ្យម៣ក្បាល/គ្រួសារដែលចិញ្ចឹម) ក្របីស្ថិតនៅលំដាប់ទី២ ដែលមានចំនួន ៨៧.៤៣៨ក្បាល ត្រូវបានចិញ្ចឹមក្នុង ១២.៩៤០គ្រួសារ ស្មើនឹង៧,១% នៃគ្រួសារសរុប (ជាមធ្យម៧ក្បាល/គ្រួសារដែលចិញ្ចឹម) ខណៈដែលការចិញ្ចឹមសេះមានចំនួនតិចតួចបំផុត (១៩៦ក្បាល ត្រូវបានចិញ្ចឹមក្នុង ៧៦គ្រួសារ)។ ខេត្តឧត្តរមានជ័យក៏មិនខុសគ្នាពីខេត្តកំពង់ធំដែរ ដោយការចិញ្ចឹមគោគឺឈរនៅលំដាប់ខ្ពស់ទី១ ដែលមានចំនួន ៤៣.៧២០ក្បាល ត្រូវបានចិញ្ចឹមក្នុង ៩.០១៨គ្រួសារ ស្មើនឹង១៤,៩% នៃគ្រួសារសរុប (ជាមធ្យម៥ក្បាល/គ្រួសារដែលចិញ្ចឹម) ឯ

ជ្រូកគឺស្ថិតនៅលំដាប់ទី២ មានចំនួន ២២.១១៤ក្បាល ត្រូវបានចិញ្ចឹមក្នុង ៥.២៣៨គ្រួសារ ស្មើនឹង ៨,៦% នៃគ្រួសារសរុប (ជាមធ្យម៤ក្បាល/គ្រួសារដែលចិញ្ចឹម) ខណៈដែលសេះគ្មានគ្រួសារណាមួយចិញ្ចឹមទេ។

### ខ. បសុបក្សី

*តារាងទី២៤៖ ចំនួនគ្រួសារចិញ្ចឹមបសុបក្សី*

| បសុបក្សី | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បសុបក្សី | គ្រួសារ | បសុបក្សី |
| មាន់ | ១១៥.៩២៤ | ១.០៣៩.៤៦០ | ៤១.៧៧៤ | ៥២៩.៧៧៨ |
| ទា | ១០.៦៤០ | ៦៥៧.១៨០ | ៤.២២០ | ៥២.៣១៤ |
| ក្រួច | ៥៨ | ២.២០២ | ៤ | ៣៦០ |
| ត្រចៀកកាំ | ៤៤ | - | ២០ | - |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២៤ បង្ហាញពីចំនួនបសុបក្សីដែលបានចិញ្ចឹមតាមគ្រួសារ។ ក្នុងតារាងនេះយើងឃើញថា នៅក្នុងខេត្តកំពង់ធំ ការចិញ្ចឹមមាន់មានចំនួន ១.០៣៩.៤៦០ក្បាល ត្រូវបានចិញ្ចឹមក្នុង១១៥.៩២៤ គ្រួសារ ស្មើនឹង៦៣,២% នៃគ្រួសារសរុប (ជាមធ្យម៩ក្បាល/គ្រួសារដែលចិញ្ចឹម) ទាមាន ៦៥៧.១៨០ ក្បាល ត្រូវបានចិញ្ចឹមក្នុង១០.៦៤០គ្រួសារ ស្មើនឹង៥,៨% នៃគ្រួសារសរុប (ជាមធ្យម៦២ក្បាល/គ្រួសារដែលចិញ្ចឹម) ក្រួចមាន ២.២០២ក្បាល ត្រូវបានចិញ្ចឹមក្នុង៥៨គ្រួសារ ស្មើនឹង០,០៣% នៃគ្រួសារសរុប (ជាមធ្យម៣៨ក្បាល/គ្រួសារដែលចិញ្ចឹម) និងការចិញ្ចឹមត្រចៀកកាំមានចំនួន៤៤គ្រួសារ។ ចំណែកខេត្តឧត្តរមានជ័យ ការចិញ្ចឹមមាន់មានចំនួន ៥២៩.៧៧៨ក្បាល ត្រូវបានចិញ្ចឹមក្នុង៤១.៧៧៤គ្រួសារ ស្មើនឹង៦៨,៩% នៃគ្រួសារសរុប (ជាមធ្យម១៣ក្បាល/គ្រួសារដែលចិញ្ចឹម) ទាមាន ៥២.៣១៤ក្បាល ត្រូវបានចិញ្ចឹមក្នុង៤.២២០គ្រួសារ ស្មើនឹង៧,០% នៃគ្រួសារសរុប (ជាមធ្យម១២ក្បាល/គ្រួសារដែលចិញ្ចឹម) ក្រួចមាន ៣៦០ក្បាល ត្រូវបានចិញ្ចឹមក្នុង៤គ្រួសារ ស្មើនឹង០,០១% នៃគ្រួសារសរុប (ជាមធ្យម៩០ក្បាល/គ្រួសារដែលចិញ្ចឹម) និងមានការចិញ្ចឹមត្រចៀកកាំចំនួន២០គ្រួសារផងដែរ។

## គ. វារីវប្បកម្ម

*តារាងទី២៥៖ ចំនួនគ្រួសារចិញ្ចឹមវារីវប្បកម្ម*

| វារីវប្បកម្ម | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | គ្រួសារ | បរិមាណ (តោន) | គ្រួសារ | បរិមាណ (តោន) |
| ត្រី | ១.២៧៤ | ២.៥៩១ | ៦៦ | ៣៥ |
| បង្គារ | ៤ | ២ | 0 | 0 |
| បង្កង | 0 | 0 | ១០ | ៣ |
| ក្រពើ | ១៣៦ | ៤៤៨ | 0 | 0 |
| កង្កែប | ៣៦ | ១៧ | ៤ | ១ |
| អន្ទង់ | 0 | 0 | 0 | 0 |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២៥ គឺជាចំនួនវារីវប្បកម្មដែលចិញ្ចឹមនៅតាមគ្រួសារ។ តារាងនេះបានបង្ហាញថា ការធ្វើវារីវប្បកម្មនៅខេត្តកំពង់ធំ ភាគច្រើនគឺចិញ្ចឹមត្រី (១.២៧៤គ្រួសារ ទទួលផលបាន២.៥៩១តោន) ដែលជាមធ្យមប្រមាណ២តោន/គ្រួសារ ស្មើនឹង 0,៧% នៃគ្រួសារសរុប បន្ទាប់មកគឺក្រពើ (១៣៦គ្រួសារ ទទួលផលបាន៤៤៨តោន) ដែលជាមធ្យមប្រមាណ៣,៣តោន/គ្រួសារ ស្មើនឹង 0,១% នៃគ្រួសារសរុប ខណៈដែលវារីវប្បកម្មផ្សេងទៀតដូចជា បង្គារ កង្កែប ... មានចំនួនតិចតួចបំផុត។ រីឯខេត្តឧត្តរមានជ័យមិនសូវមានគ្រួសារធ្វើវារីវប្បកម្មទេ ផ្អែកតាមតារាងខាងលើគឺមានតែចិញ្ចឹមត្រី ៦៦គ្រួសារ (ស្មើនឹង 0,១% នៃគ្រួសារសរុប) ដែលទទួលផលបាន៣៥តោន និងចិញ្ចឹមកង្កែប ៤គ្រួសារ ដែលទទួលបានផល ១តោន ប៉ុណ្ណោះ។

## ២.១១.៦. ទិន្នផលដំណាំ និងគោលបំណងផលិត

### ក. ទិន្នផលដំណាំ

*តារាងទី២៦៖ ចំនួនទិន្នផលនៃដំណាំសំខាន់ៗ*

| ដំណាំ | កំពង់ធំ | | ឧត្តរមានជ័យ | |
|---|---|---|---|---|
| | ទិន្នផលមធ្យម (តោន/ហិកតា) | ទិន្នផល/១ឆ្នាំ (តោន) | ទិន្នផលមធ្យម (តោន/ហិកតា) | ទិន្នផល/១ឆ្នាំ (តោន) |
| ដំឡូងមី | ១២ | ៧៥៨.៧១១ | ១១ | ១.២៨៧.៩៤៦ |
| ស្រូវ | ៣ | ៥១៧.៨៨៧ | ២ | ២០៣.៣០១ |
| កៅស៊ូ | ៤ | ២៩៩.៧៥៦ | ៥ | ១.៣៥៨ |
| ស្វាយចន្ទី | ២ | ១៧៤.២៨៨ | ១៤ | ៤៨.០០៥ |
| ស្វាយ | ២ | ៨.១០០ | ១២ | ១០២.៦៤៣ |
| ពោត | ១ | ៦៩៦ | ១ | ១៦ |
| ដំឡូងជ្វា | ៤ | ៥៤២ | - | 0 |
| សណ្តែកបាយ | ២ | ១២៨ | ១ | ៣០ |
| ចេក | ១ | ៧៩ | ១៨ | ៩៦០ |
| ម្រេច | ១០ | ៦០ | - | 0 |
| សណ្តែកដី | ៣ | ៥១ | ១ | ១៧៥ |
| ទុរេន | ២ | ៤៦ | - | 0 |
| មៀន | ១ | ២៨ | ៦ | ២៦០ |
| ល្ហុង | ១ | ១៤ | ៦៦ | ៦៦ |
| សារម៉ៅ | ១ | ១២ | ១ | ១ |
| ក្រូច | ១ | ៨ | - | 0 |
| អំពៅ | ៤ | ៧ | - | 0 |
| ប៊ឺរ | ២ | ៤ | - | 0 |
| សណ្តែកសៀង | - | 0 | ១ | ១១១ |
| ល្ង | - | 0 | ១ | ៨ |

*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

តារាងទី២៦ បង្ហាញពីចំនួនទិន្នផលនៃដំណាំសំខាន់ដែលមាននៅក្នុងខេត្ត។ តាមតារាងនេះ ខេត្តកំពង់ធំ ដំណាំដំឡូងមី គឺជាដំណាំដែលទទួលបានទិន្នផលខ្ពស់ជាងគេ វាមាន ៧៥៨.៧១១តោន

(ជាមធ្យម១២តោន/ហិកតា) បន្ទាប់មកគឺដំណាំស្រូវ មាន៤៨.៣៣៤តោន (ជាមធ្យម៣តោន/ហិកតា) បន្ទាប់មកទៀត គឺដំណាំកៅស៊ូ មាន២៩៩.៧៥៦តោន (ជាមធ្យម៤តោន/ហិកតា) ស្វាយចន្ទីមាន ១៧៤.២៨៨តោន (ជាមធ្យម២តោន/ហិកតា) ស្វាយ ៨.១០០តោន (ជាមធ្យម២តោន/ហិកតា) ខណៈដែលដំណាំពោត ដំឡូងជ្វា សណ្ដែកបាយ ... មានចំនួនតិចតួចបើធៀបទៅនឹងដំណាំទាំងអស់នៅទូទាំងខេត្ត។ ខេត្តឧត្តរមានជ័យ ដំណាំដំឡូងមី គឺជាដំណាំដែលទទួលបានទិន្នផលខ្ពស់ជាងគេ វាមាន ១.២៨៧.៩៤៦តោន (ជាមធ្យម១១តោន/ហិកតា) បន្ទាប់មកគឺដំណាំស្រូវ ២០៣.៣០១តោន (ជាមធ្យម២តោន/ហិកតា) បន្ទាប់មកទៀតគឺដំណាំស្វាយ ១០២.៦៤៣តោន (ជាមធ្យម១២តោន/ហិកតា) ស្វាយចន្ទី ៤៨.០០៥តោន (ជាមធ្យម១៤តោន/ហិកតា) កៅស៊ូ ១.៣៥៨តោន (ជាមធ្យម៥តោន/ហិកតា) ខណៈដែលដំណាំចេក មៀន សណ្ដែកដី សណ្ដែកសៀង ... មានចំនួនតិចតួចបើធៀបទៅនឹងដំណាំទាំងអស់នៅទូទាំងខេត្ត។

### ខ. គោលបំណងផលិត




*ប្រភព៖ ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២២*

រូបភាពទី៣៦ បង្ហាញពីគោលបំណងចម្បងនៃការដាំដំណាំ។ យើងឃើញថា ការដាំដំណាំនៅខេត្តកំពង់ធំ មាន ៨៦% ខណៈដែលខេត្តឧត្តរមានជ័យមាន ៩៧% គឺដាំដើម្បីប្រមូលផលលក់។

# ជំពូកទី៣

# សន្និដ្ឋាន និងអនុសាសន៍

## ៣.១. សន្និដ្ឋាន

តាមលទ្ធផលនៃការវិភាគខាងលើអាចសន្និដ្ឋានបានថាៈ ក្រៅពីកត្តាប្រជាជន គឺមានកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់ការរួមចំណែកក្នុងការអភិវឌ្ឍរបស់ខេត្តទាំងពីរដូចជា ការប្រើប្រាស់ទឹកស្អាត ការប៉ះពាល់បរិស្ថាន និងអនាម័យ បញ្ហាទំនាស់ដីធ្លី អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ អសន្តិសុខសង្គម បញ្ហាគ្រឿងញៀន សេវាសុខាភិបាល និងសេវាអប់រំជាដើម។ បញ្ហាទាំងអស់នេះ គឺជាធាតុចូលយ៉ាងសំខាន់ដែលត្រូវគិតគូរវែងឆ្ងាយទៅអនាគត ដើម្បីឱ្យខេត្តទាំងពីរមានការអភិវឌ្ឍបន្ថែមទៀត ពិសេសគឺធ្វើឱ្យប្រជាជននៅទទួលបានសុខុមាលភាព និងទទួលបានសុវត្ថិភាពជីវភាពរស់នៅខ្ពស់ផងដែរ។

## ៣.២. អនុសាសន៍

ខាងក្រោមនេះជាអនុសាសន៍មួយចំនួន ដើម្បីឱ្យខេត្តទាំងពីរមានការអភិវឌ្ឍល្អប្រសើរៈ

១. គ្រប់គ្រងនូវចំនួនប្រជាជនទាំងការចំណាក និងចំណូលស្រុកឱ្យបានច្បាស់លាស់ ព្រោះថា កត្តាប្រជាជនជាកត្តាចម្បងនៃការរៀបចំផែនការអភិវឌ្ឍផ្សេងៗនៅក្នុងមូលដ្ឋានដែលមិនអាចខ្វះបាន។

២. ជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ តាមរយៈអជ្ញាធរភូមិ ឃុំ/សង្កាត់ និងអង្គការក្រៅរាជរដ្ឋាភិបាល រួមទាំងការចូលរួមពីមន្ទីរអភិវឌ្ឍន៍ជនបទផងដែរ។

៣. ការដោះស្រាយទំនាស់ដីធ្លី គួរធ្វើទៅតាមបច្ចេកទេស និតិវិធីនៃច្បាប់ និងតម្លាភាព ដោយមានការសហការពីអាជ្ញាធរដែនដី និងអាជ្ញាធរដោះស្រាយទំនាស់ដីធ្លី ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌ពិតប្រាកដ។

៤. អាជ្ញាធរក្នុងតំបន់ត្រូវអប់រំអំពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ ដែលនាំឱ្យមានការបែកបាក់គ្រួសារ បាត់បង់អាយុជីវិត ខាតបង់ប្រាក់កាស និងពេលវេលាសម្រាប់ប្រកបរបររកស៊ីប្រចាំថ្ងៃ ម៉្យាងទៀតវានាំឱ្យរំខានដល់អ្នកជិតខាង និងអាជ្ញាធរដើម្បីជួយដោះស្រាយទៀតផង។

៥. រៀបចំផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍បន្ថែម រួមទាំងដាក់ចេញនូវកម្មវិធីបណ្តុះបណ្តាលឬផ្សព្វផ្សាយនៅតាមសាលារៀន/តាមភូមិ ដើម្បីឱ្យសិស្ស និស្សិត ក៏ដូចជាប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឱ្យមានការយល់ដឹងពីគ្រោះថ្នាក់ និងយល់ដឹងពីច្បាប់ចរាចរណ៍។

៦. សមត្ថកិច្ចគួរតែមានវិធានការឱ្យខានតែបាននូវបញ្ហាអសន្តិសុខនៅក្នុងមូលដ្ឋានរបស់ខ្លួនដូចជាការលួច ឆក់ ប្លន់ ឃាតកម្ម និងគ្រឿងញៀនជាដើម។

៧. ពង្រឹង និងពង្រីកបន្ថែមទៀតនូវការផ្តល់សេវាសុខាភិបាល និងសេវាផ្សេងៗទៀតដែលជារបស់រដ្ឋឱ្យបានល្អប្រសើរដល់ប្រជាពលរដ្ឋដែលត្រូវការ។

# ឧបសម្ព័ន្ធ ១

**ក្រសួងផែនការ**

**វិទ្យាស្ថានជាតិស្ថិតិ**

**កម្រងសំណួរស្ថិតិថ្នាក់ក្រោមជាតិ**

Sub-national Statistics Questionnaire

**លេខកម្រងបញ្ជីសំណួរៈ**...................................

| ព័ត៌មានភូមិសាស្ត្រ / Geographical Information | លេខកូដ / Code |
|---|---|
| រាជធានី/ខេត្ត / Municipal / Provincial | |
| ស្រុក/ខណ្ឌ/ក្រុង / District / City | |
| ឃុំ/សង្កាត់ / Commune | |
| ភូមិ/មណ្ឌល / Village | |
| តំបន់ (ទំនាបកណ្តាល=១, បឹងទន្លេសាប=២, ឆ្នេរសមុទ្រ=៣, ភ្នំ និងខ្ពង់រាប=៤) / Zone (Central lowlands=1, Tonle Sap Lake Area=2, Coastal areas=3, Mountainous and Highlands areas=4) | |
| ផ្នែក (ទីប្រជុំជន=១, ជនបទ=២) / Sector (Urban=1 Rural = 2) | |

| ព័ត៌មានមន្ត្រីត្រួតពិនិត្យការសម្ភាស មន្ត្រីសម្ភាសន៍ និងអ្នកឆ្លើយតបការសម្ភាស<br>Supervisor, Enumerator and Respondent Information | | | | |
|---|---|---|---|---|
| ព័ត៌មាន<br>Information | ឈ្មោះ<br>Name | មុខងារ<br>Position | លេខទូរសព្ទ<br>Phone Number | ហត្ថលេខា<br>Signature |
| មន្ត្រីត្រួតពិនិត្យការសម្ភាស<br>Supervisor | | | | |
| មន្ត្រីសម្ភាសន៍<br>Enumerator | | | | |
| អ្នកឆ្លើយតបការសម្ភាស<br>Respondent | | | | |

## ផ្នែកទី១ ៖ ប្រជាសាស្ត្រ Demography

**សំណួរទី១.១ ៖ ចំនួនសហគមន៍/សមាគមនៅក្នុងភូមិ** Number of Communities/Associations in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities | ចំនួនគ្រួសារដែលចូលរួម<br>No. of Households | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|---|
| 1- | | | | |
| 2- | | | | |
| 3- | | | | |
| 4- | | | | |
| *សរុប*<br>*Total* | | | | |

**សំណួរទី១.២ ៖ ចំនួនអង្គការនៅក្នុងភូមិ** Number of Organization in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities |
|---|---|
| 1- | |
| 2- | |
| 3- | |
| 4- | |
| *សរុប*<br>*Total* | |

**សំណួរទី១.៣ ៖ ចំនួនមីក្រូហិរញ្ញវត្ថុ/ធនាគារនៅក្នុងភូមិ** Number of Microfinances/Banks in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities |
|---|---|
| 1- | |
| 2- | |
| 3- | |
| 4- | |
| *សរុប*<br>*Total* | |

**សំណួរទី១.៤ ៖ ចំនួនគ្រួសារ និងចំនួនប្រជាជន** Number of Households and Population

| ប្រភេទគ្រួសារ Household type | ចំនួនគ្រួសារ No. of household | ចំនួនមនុស្សនៅក្នុងគ្រួសារ No. of persons in the household | ប្រុស Male | ស្រី Female |
|---|---|---|---|---|
| 1- បុរស ជាមេគ្រួសារ Male headed households | | | | |
| 2- ស្ត្រី ជាមេគ្រួសារ Female headed households | | | | |
| 3- ស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំ Female headed households having less 5 years old children | | | | |
| *សរុប Total (1+2)* | | | | |

**សំណួរទី១.៥ ៖ ចំនួនជនជាតិដែលរស់នៅក្នុងភូមិ** Number of Nationalities are living in the village

| ជនជាតិ Nationality | សរុប Total | ប្រុស Male | ស្រី Female |
|---|---|---|---|
| 1- ខ្មែរ Khmer | | | |
| 2- ចិន Chinese | | | |
| 3- ថៃ Thailand | | | |
| 4- ឡាវ Laos | | | |
| 5- វៀតណាម Vietnamese | | | |
| 6- ខ្មែរឥស្លាម Khmer Islam | | | |
| 7- កូរ៉េ Korean | | | |
| 8- ជនជាតិដើមភាគតិច Group of Ethnic minority | | | |
| 9- ជនជាតិបរទេសផ្សេងៗទៀត Other Nationality | | | |
| *សរុប Total* | | | |

**សំណួរទី១.៦ ៖ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ** Marital status of household headed

| ស្ថានភាពអាពាហ៍ពិពាហ៍<br>Marital status | ចំនួនគ្រួសារ<br>No. of household |
|---|---|
| 1- បានរៀបការរស់នៅជាមួយគ្នា Married/living together | |
| 2- មេម៉ាយ ឬពោះម៉ាយ Widowed | |
| 3- រស់នៅផ្សេងគ្នា Separated | |
| 4- រស់នៅជាមួយគ្នាមិនបានរៀបការ Living together without married | |
| 5- មិនបានរៀបការ Never married | |
| *សរុប*<br>*Total* | |

** សំណួរទី១.៦៖ សរុបស្ថានភាពអាពាហ៍ពិពាហ៍ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបដែលមានក្នុងភូមិ Total of marital status is must be equal to the number of households in the village.*

**សំណួរទី១.៧ ៖ ចំនួនមនុស្សធ្វើចំណាកស្រុកចូល និងចេញ** Number of person In and out-migrations

| ការពិពណ៌នា<br>Descriptions | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|
| 1- ចំណូលស្រុក In-migration | | | |
| 2- ចំណាកស្រុក Out-migration | | | |
| *2.1- ចំណាកស្រុកក្នុងប្រទេស Local migration* | | | |
| 2.1.1- ដើម្បីស្វែងរកការងារធ្វើ To seeking employment | | | |
| 2.1.2- ដើម្បីបន្តការសិក្សា To studying | | | |
| 2.1.3- ផ្សេងៗ Other | | | |
| *2.2- ចំណាកស្រុកក្រៅប្រទេស Overseas migration* | | | |
| 2.2.1- ដើម្បីស្វែងរកការងារធ្វើ To seeking employment | | | |
| 2.2.2- ដើម្បីបន្តការសិក្សា To studying | | | |
| 2.2.3- ផ្សេងៗ Other | | | |

**សំណួរទី១.៨ ៖ ចំនួនខ្នងផ្ទះ និងមូលដ្ឋានបរិក្ខារដែលមាន** Number of Houses and Access to basic facilities

| ប្រភេទខ្នងផ្ទះ Type of house | ចំនួនខ្នងផ្ទះ និងមូលដ្ឋានបរិក្ខារដែលមាន No. of houses and access to basic facilities | | | | | |
|---|---|---|---|---|---|---|
| | សរុប Total | អគ្គិសនី Electricity | ទូរទស្សន៍ TV | កុំព្យូទ័រ Computer | ទូរសព្ទដៃ Mobile phones | អ៊ីនធឺណេត Internet |
| 1- ផ្ទះដំបូលបេតុង Concrete roof houses | | | | | | |
| 2- ផ្ទះដំបូលក្បឿង Tiles roof houses | | | | | | |
| 3- ផ្ទះដំបូលស័ង្កសី / ហ្វីប្រូ Zinc roof houses | | | | | | |
| 4- ផ្ទះប្រក់ស្លឹក Thatched huts | | | | | | |
| 5- ផ្សេងៗ Other | | | | | | |
| *សរុប Total* | | | | | | |

** សំណួរទី១.៨៖ ចំនួនខ្នងផ្ទះសរុប គឺត្រូវតែស្មើ ឬតិចជាងចំនួនគ្រួសារសរុបនៅក្នុងភូមិ The total number of houses is equal to or less than the total number of households in the village.*

**សំណួរទី១.៩ ៖ បរិក្ខារដែលទាក់ទងការងារដឹកជញ្ជូន គ្រឿងម៉ាស៊ីន និងយានយន្ត** Transportation, Machineries and Vehicles Related Equipment

| ប្រភេទបរិក្ខារ Type of equipment | ចំនួនបរិក្ខារ No. of equipment | ចំនួនគ្រួសារដែលមានបរិក្ខារ No. of households having equipment | ភាគរយគ្រួសារមានបរិក្ខារ Percentage of households having equipment |
|---|---|---|---|
| 1- ឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីន ម៉ាស៊ីនភ្ជួររាស់ Agriculture tools & machineries Ploughing machines | | | |
| 2- ម៉ាស៊ីនប្រមូលផល Harvesting machines | | | |
| 3- ឧបករណ៍កសិកម្មផ្សេងទៀត (ក្រៅពីគ្រឿងម៉ាស៊ីន) Other agricultural tools (Not mechanical) | | | |
| 4- រថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និងក្រោម១៩កៅអី) Taxi and Vans | | | |

| | | | |
|---|---|---|---|
| 5- រថយន្តដឹកទំនិញ Loading trucks | | | |
| 6- រថយន្តក្រុង (ចាប់ពី២៤កៅអី) Buses | | | |
| 7- រថយន្តលក្ខណៈគ្រួសារ Cars | | | |
| 8- ម៉ូតូ Motorbikes | | | |
| 9- រទេះអូសដោយដៃ Carts | | | |
| 10- ម៉ូតូកង់បី Tri tier motorbike | | | |
| 11- រទេះគោ និងសេះ Ox and horse carts | | | |
| 12- ទូក Boats | | | |
| 13- ទូកដឹកអ្នកដំណើរ Passenger boats | | | |
| 14- ទូកនេសាទ Fishing boats | | | |
| 15- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | | |

**សំណួរទី១.១០ ៖ ទីកន្លែង និងចំនួនទារកកើត** The place and Number of Infant born

| ទីកន្លែងកើត Place of birth | សរុប Total | ប្រុស Male | ស្រី Female |
|---|---|---|---|
| 1- មន្ទីរពេទ្យរដ្ឋ (បង្អែកខេត្ត ស្រុក ...) Government Hospital | | | |
| 2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព Health centers/Health Post | | | |
| 3- មន្ទីរពេទ្យឯកជន Private Clinic | | | |
| 4- ផ្ទះខ្លួនឯងដោយពេទ្យឆ្មប/ឆ្មបបុរាណ Private house by Nurse/Midwife | | | |
| 5- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | | |
| *សរុប Total* | | | |

**សំណួរទី១.១១ ៖ ចំនួនអ្នកស្លាប់នៅក្នុងភូមិតាមក្រុមអាយុ** Number of death in the village

| មូលហេតុចម្បងនៃការស្លាប់ Cause of Dead | សរុប Total | ប្រុស Male | | | | ស្រី Female | | | |
|---|---|---|---|---|---|---|---|---|---|
| | | តិចជាង ៥ឆ្នាំ Lest then 5years | ៥-១៧ 5-17 | ១៨-៦៤ 18-64 | ៦៥ ឆ្នាំ ឡើង Over 65 years | តិចជាង ៥ឆ្នាំ Lest then 5years | ៥–១៧ 5-17 | ១៨–៦៤ 18-64 | ៦៥ ឆ្នាំ ឡើង Over 65 years |
| 1- ជំងឺ Disease | | | | | | | | | |
| 1.1- ជំងឺឆ្លង Cable Diseases | | | | | | | | | |
| 1.2- ជំងឺមិនឆ្លង Non-Cable Diseases | | | | | | | | | |
| 2- គ្រោះថ្នាក់ចរាចរណ៍ Traffic accident | | | | | | | | | |
| 3- លង់ទឹក Drowning | | | | | | | | | |
| 4- ពស់ចឹក Snakebites | | | | | | | | | |
| 5- ឃាតកម្ម Criminal | | | | | | | | | |
| 6- អត្តឃាត Suicide | | | | | | | | | |
| 7- គ្រាប់មិនទាន់ផ្ទុះ Unexploded ordnance | | | | | | | | | |
| 8- ផ្សេងៗ Other | | | | | | | | | |
| *សរុប Total* | | | | | | | | | |

**សំណួរទី១.១២ ៖ ពិការភាពនៃបុគ្គល** Disability of Persons

| ការពិពណ៌នា Descriptions | សរុប Total | ប្រុស Male | ស្រី Female |
|---|---|---|---|
| 1- បុគ្គលដែលរងគ្រោះដោយសារគ្រាប់មិនទាន់ផ្ទុះ Persons victimized from Unexploded ordnance | | | |
| 2- ផ្ទៃដីដែលបានសំអាតគ្រាប់មិនទាន់ផ្ទុះ (ហិកតា) Area cleared of Unexploded ordnance (ha) | | | |
| 3- មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់ Old people without any protectors/family support | | | |
| 4- អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ) Disabled minors (less than 18 years old) | | | |
| 5- បុគ្គលពិការដែលមានប្រភពចំណូល (ដូចជាជាងកាត់សក់។ល។) Disabled persons with sources of earnings (barbers, etc.) | | | |
| 6- បុគ្គលពិការដែលគ្មានចំណូល (នៅក្នុងបន្ទុក អង្គការចិញ្ចឹម។ល។) Disabled persons without any income | | | |

**សំណួរទី១.១៣ ៖ ចំនួនគ្រួសារដែលលែងលះគ្នាតាមមុខរបរ (មេគ្រួសារ)** Number of Divorces by Occupational Groups (Head of households)

| ជំនាញ Professions | ចំនួនគ្រួសារដែលលែងលះគ្នា No. of divorces household |
|---|---|
| 1- អ្នកមានវិជ្ជាជីវៈ Professionals | |
| 2- មន្ត្រីរាជការ Civil servants | |
| 3- អ្នកជំនួញ Business people | |
| 4- អ្នកនយោបាយ Politicians | |
| 5- ពលករ/កម្មករ Laborers | |
| 6- កសិកម្ម Agriculture | |
| 7- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | |
| *សរុប Total* | |

**សំណួរទី១.១៤ ៖ ប្រភពទឹកប្រើប្រាស់ និងទទួលទាន (ទឹក)** Sources of Using and Drinking Water

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារប្រើប្រាស់ទឹក<br>No. of households using water | ចំនួនគ្រួសារទទួលទានទឹក<br>No. of households drinking water |
|---|---|---|
| 1- ទឹកស្អាត (ទុយោ) Clean water (piped) | | |
| 2- ទឹកបរិសុទ្ធ Pure water | | |
| 3- ទឹកអណ្តូង Well water | | |
| 4- ទឹកភ្លៀង Rain water | | |
| 5- ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ Ponds / lakes / rivers / streams water | | |
| 6- ផ្សេងៗ (សូមបញ្ជាក់....) Other water (Please specify...) | | |
| *សរុប*<br>*Total* | | |

** សំណួរទី១.១៤៖ ប្រភពទឹកប្រើប្រាស់ ឬទឹកទទួលទាន គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Sources of using or drinking water is equal to the total number of households in the village.*

**សំណួរទី១.១៥ ៖ ការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារ** Energy consumption for cooking

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារ<br>No. of households |
|---|---|
| 1- ការប្រើប្រាស់អុស/ធ្យូង Fuel wood | |
| 2- ការប្រើប្រាស់ហ្គាស Gas | |
| 3- ឡជីវឧស្ម័ន Biogas plant | |
| 4- ផ្សេងៗ Others | |
| *សរុប*<br>*Total* | |

** សំណួរទី១.១៥៖ សរុបការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Total of energy consumption for cooking is equal to the total number of households in the village.*

**សំណួរទី១.១៦ ៖ ការប្រើប្រាស់បង្គន់អនាម័យ** Using the toilets

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារ<br>No. of households |
|---|---|
| 1- គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យផ្ទាល់ខ្លួន Households with personal toilet for using | |
| 2- គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាង Households with neighbors' toilet for using | |
| 3- គ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ (បន្ទោបង់ពាសវាល)<br>Households without toilet for using (Outdoor defecation) | |
| *សរុប*<br>*Total* | |

** សំណួរទី១.១៦៖ សរុបចំនួនគ្រួសារប្រើប្រាស់បង្គន់អនាម័យ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Total number of households using toilets is equal to the total number of households in the village.*

**សំណួរទី១.១៧ ៖ ប្រជាជនដែលគ្មានផ្ទះសម្បែង** Homeless people

| ការពិពណ៌នា<br>Descriptions | ចំនួន<br>Number |
|---|---|
| 1- គ្រួសារដែលរស់នៅលើដីសាធារណៈ Households living on public land | |
| 2- គ្រួសារដែលគ្មានផ្ទះសំបែង Homeless people | |

**សំណួរទី១.១៨ ៖ គ្រោះធម្មជាតិ** Natural disasters

| គ្រោះធម្មជាតិ<br>Natural disasters | ចំនួនគ្រួសាររងផលប៉ះពាល់<br>No. of households affected | ផ្ទៃដីរងផលប៉ះពាល់ (ហិកតា)<br>Areas affected (ha) |
|---|---|---|
| 1- ទឹកជំនន់ Flooding | | |
| 2- ដីបាក់ ឬស្រុត Land slides | | |
| 3- គ្រោះរាំងស្ងួត Drought | | |
| 4- ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ Storm / Twitch | | |
| 5- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | |

**សំណួរទី១.១៩ ៖ ការគ្រប់គ្រងកាកសំណល់** Waste management

| ការពិពណ៌នា<br>Descriptions | ចំនួន<br>Number | ចំនួនផ្ទៃដី (ហិកតា)<br>Areas (ha) |
|---|---|---|
| 1- ទីតាំងចោលកាកសំណល់ទូទៅ General waste disposal site | | |
| 2- ទីតាំងចោលកាកសំណល់ឧស្សាហកម្ម Industrial waste disposal site | | |
| 3- ទីតាំងចោលកាកសំណល់សិប្បកម្ម Handicraft waste disposal site | | |
| 4- ទីតាំងចោលកាកសំណល់វេជ្ជសាស្ត្រ Medical waste disposal site | | |
| 5- គ្រួសារដែលប្រើសេវាប្រមូលសំរាម Households using garbage collection service | | |
| 6- ធុងសំរាមតាមទីសាធារណៈ Bin in public site | | |
| 7- ធុងសំរាមតាមលំនៅឋាន Bin in home site | | |

**សំណួរ១.២០ ៖ ចំនួនផ្ទៃដីព្រៃឈើ** Number of forest area

| ការពិពណ៌នា<br>Descriptions | ចំនួនផ្ទៃដី (ហិកតា)<br>Total area (ha) |
|---|---|
| 1- ព្រៃឈើគ្របដណ្តប់ Forest coverage | |
| 2- ការដាំកូនឈើ Afforestation | |
| 3- ការកាប់ឆ្ការព្រៃឈើ Deforestation | |

# ផ្នែកទី២ ៖ សន្តិសុខសង្គម និង សេដ្ឋកិច្ច Social Security and Economics

## សំណួរទី២.១ ៖ សន្តិសុខសង្គម Social Security

| ការពិពណ៌នា Descriptions | ចំនួនករណីកើតឡើង No. of occurrences | ចំនួនករណីដែលបានដោះស្រាយ No. of cases solved |
|---|---|---|
| 1- ប្លន់/ចាប់ជម្រិត Robbery / Kidnapping | | |
| 2- លួច Stealing | | |
| 3- ជម្លោះដីធ្លី Land Conflicts | | |
| 4- ប្រជាពលរដ្ឋទាស់ទែងគ្នា Civil conflicts | | |
| 5- ឃាតកម្ម/ឧក្រិដ្ឋកម្ម Murdering / Criminal Conflicts | | |

## សំណួរទី២.២ ៖ អំពើហិង្សាក្នុងគ្រួសារ Domestic Violence

| ការពិពណ៌នា Descriptions | ចំនួនគ្រួសារ No. of Household |
|---|---|
| 1- គ្រួសារដែលជួបអំពើហិង្សា Households facing domestic violence | |
| 2- គ្រួសារដែលមានសមាជិកប្រើប្រាស់គ្រឿងញៀន Households that have members using illegal Drugs | |

## សំណួរទី២.៣ ៖ ស្ត្រីរងគ្រោះ Victimization of Women

| ការពិពណ៌នា Descriptions | ចំនួនអ្នករងគ្រោះ No. of victims | អ្នករងគ្រោះអាយុតិចជាង១៨ឆ្នាំ Victims less than 18 years old | អ្នករងគ្រោះអាយុ១៨ឆ្នាំឡើង Victims 18 years old and above |
|---|---|---|---|
| 1- ចំនួនស្ត្រីដែលត្រូវបានគេចាប់រំលោភ Number of raped women | | | |
| 2- ចំនួនស្ត្រីដែលត្រូវគេបានជួញដូរ Number of trafficked women | | | |

សំណួរទី២.៤៖ សកម្មភាពអាជីវកម្មចម្បងនៃគ្រួសារ Households of major business activities

| សកម្មភាពអាជីវកម្ម Business Activities | ចំនួនគ្រួសារមានសកម្មភាពអាជីវកម្ម No. of households having business activities | ចំនួនអ្នកធ្វើការ No. of Worker | | |
|---|---|---|---|---|
| | | សរុប Total | ប្រុស Male | ស្រី Female |
| 1- ម៉ាស៊ីនកិនស្រូវ Milling | | | | |
| 2- លក់ និងជួសជុលម៉ូតូ/កង់ Selling and Motorbike / Bike repairing | | | | |
| 3- លក់ និងជួសជុលរថយន្ត Selling and Vehicle repairing | | | | |
| 4- លក់ និងជួសជុលឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្ម Selling and Agricultural tools / machinery repairing | | | | |
| 5- លក់ និងជួសជុលគ្រឿងអេឡិចត្រូនិច Selling and Electronics repairing | | | | |
| 6- លក់ និងផលិតគ្រឿងសង្ហារិមពីឈើ Selling and Woods furniture making | | | | |
| 7- លក់ និងផលិតគ្រឿងសង្ហារិមពីស៊ីម៉ងត៍ Selling and Cements furniture making | | | | |
| 8- លក់ និងផលិតគ្រឿងសង្ហារិមពីដែក/អ៊ីណុក Selling and Steel / Stainless furniture making | | | | |
| 9- បិតស្រា Distillery | | | | |
| 10- ហាងកាត់សក់/អ៊ុតសក់/កែសម្ផស្ស Barbers / Salon | | | | |
| 11- ហាងលក់គ្រឿងទេស និងភេសជ្ជៈ Groceries and Beverage stores | | | | |
| 12- ហាងលក់ថ្នាំពេទ្យ និងគ្លីនិក Pharmacies and Clinics | | | | |
| 13- សណ្ឋាគារ/ផ្ទះសំណាក់ Hotels / Guest Houses | | | | |
| 14- ភោជនីយដ្ឋាន Restaurants | | | | |
| 15- ស្ថានីយ៍ប្រេងឥន្ធនៈ Gasoline/Gas station | | | | |
| 16- តូបលក់សាំង Gasoline seller | | | | |
| 17- លក់គ្រឿងសំណង់ Construction equipment | | | | |

| | | | | |
|---|---|---|---|---|
| 18- កាត់កញ្ចក់/ជាងដែក<br>Glass cutting machine / Blacksmith | | | | |
| 19- អាជីវកម្មផ្សេងៗទៀត ( សូមបញ្ជាក់.... )<br>Other businesses ( Please specify… ) | | | | |
| *សរុប*<br>*Total* | | | | |

**សំណួរទី២.៥ ៖ ផលិតកម្ម សិប្បកម្ម/ឧស្សាហកម្ម និងការងារ** Industrial / Production and Employment

| ប្រភេទនៃសិប្បកម្ម/ឧស្សាហកម្ម<br>Type of Industries | ចំនួនសិប្បកម្ម/ឧស្សាហកម្ម<br>No. of Industries | ចំនួននិយោជិត<br>No. of Employee | | |
|---|---|---|---|---|
| | | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| 1- | | | | |
| 2- | | | | |
| 3- | | | | |
| 4- | | | | |
| 5- | | | | |
| 6- | | | | |
| 7- | | | | |
| 8- | | | | |
| 9- | | | | |

**សំណួរទី២.៦ ៖ លំហូរវិនិយោគតាមប្រភេទនៃសកម្មភាពអភិវឌ្ឍន៍** Investment flows of development activities

| សកម្មភាពអភិវឌ្ឍន៍<br>Development Activities | ចំនួនសកម្មភាព<br>No. of Activities |
|---|---|
| 1- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ Infra-structural development | |
| 2- ការអភិវឌ្ឍកសិកម្ម Agriculture Development | |
| 3- ធារាសាស្ត្រ Irrigation | |
| 4- ការដាំដុះ Farming | |

| | |
|---|---|
| 5- បសុសត្វ/បសុបក្សី Livestock / Poultry | |
| 6- នេសាទ Fishery | |
| 7- វារីវប្បកម្ម Aquaculture | |
| 8- ព្រៃឈើ Forestry | |
| 9- ការអភិវឌ្ឍឧស្សាហកម្ម Industrial Development | |
| 10- ផ្សេងៗ ( សូមបញ្ជាក់.... ) Other ( Please specify... ) | |

## ផ្នែកទី៣ ៖ វិស័យអប់រំនិង សេវាសង្គម Education and Social Services

### សំណួរទី៣.១ ៖ ចម្ងាយប៉ាន់ស្មានពីភូមិទៅកន្លែងផ្តល់សេវាកម្មជិតបំផុត Proximity of Service Provider from Village Center

| ប្រភេទសេវាកម្ម<br>Service Providers | ចម្ងាយពីភូមិទៅកន្លែងផ្តល់សេវា ( គីឡូម៉ែត្រ )<br>Distance from village center to service point ( Km ) | ចម្ងាយពីភូមិទៅកន្លែងផ្តល់សេវា កាលពី៥ឆ្នាំមុន ( គីឡូម៉ែត្រ )<br>Distance from village center to service point, 5 years ago ( Km ) |
|---|---|---|
| *1- សាលារៀន School* | | |
| 1.1- មត្តេយ្យសិក្សា Pre-primary | | |
| 1.2- បឋមសិក្សា Primary | | |
| 1.3- អនុវិទ្យាល័យ Secondary | | |
| 1.4- វិទ្យាល័យ College | | |
| 1.5- សាកលវិទ្យាល័យ Universities | | |
| *2- ប្រភេទសុខាភិបាល Health facilities* | | |
| 2.1- មន្ទីរពេទ្យរដ្ឋ (បង្អែកខេត្ត ស្រុក ...) Government Hospital | | |
| 2.2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព Health centers/Health Post | | |
| 2.3- គ្លីនីកឯកជន Clinic Private | | |
| 2.4-ឱសថស្ថាន Pharmacy | | |
| *3- ប្រភេទផ្សេងទៀត Other providers* | | |

| | | |
|---|---|---|
| 3.1- មណ្ឌលពាណិជ្ជកម្ម ឬផ្សារ<br>Market / Commercial center | | |
| 3.2- ប៉ុស្តិ៍នគរបាល Police station | | |
| 3.3- សាលាឃុំ Commune office | | |
| 3.4- ប្រៃសណីយ៍ ឬអ៊ីនធឺណេតកាហ្វេ<br>Post office / Cyber Cafe | | |

** សំណួរទី៣.១៖ ប្រសិនបើកន្លែងផ្តល់សេវាមាននៅក្នុងភូមិ នោះចម្ងាយប៉ាន់ស្មានគឺត្រូវតែ "0" If the service provider in the village, the estimated distance is "0".*

**សំណួរទី៣.២ ៖ សេវាអប់រំ** Education Levels

| ប្រភេទសាលារៀន<br>Type of Schools | ចំនួនសាលារៀន<br>No. of Schools | ចំនួនសិស្ស<br>No. of Students | | | ចំនួនគ្រូ<br>No. of Teachers | | |
|---|---|---|---|---|---|---|---|
| | | សរុប<br>Total | ប្រុស<br>Boy | ស្រី<br>Girl | សរុប<br>Total | បុរស<br>Male | ស្ត្រី<br>Female |
| *1- មត្តេយ្យសិក្សា Pre-primary* | | | | | | | |
| 1.1- រដ្ឋ Government | | | | | | | |
| 1.2- ឯកជន Private | | | | | | | |
| 1.3- សហគមន៍ Association | | | | | | | |
| *2- បឋមសិក្សា Primary* | | | | | | | |
| 2.1- រដ្ឋ Government | | | | | | | |
| 2.2- ឯកជន Private | | | | | | | |
| *3- អនុវិទ្យាល័យ Secondary* | | | | | | | |
| 3.1- រដ្ឋ Government | | | | | | | |
| 3.2- ឯកជន Private | | | | | | | |
| *4- វិទ្យាល័យ Colleges* | | | | | | | |
| 4.1- រដ្ឋ Government | | | | | | | |
| 4.2- ឯកជន Private | | | | | | | |
| *5- សាកលវិទ្យាល័ Universities* | | | | | | | |
| 5.1- រដ្ឋ Government | | | | | | | |

| 5.2- ឯកជន Private | | | | | | | |
|---|---|---|---|---|---|---|---|
| *សរុប*<br>*Total* | | | | | | | |

**សំណួរទី៣.៣៖ ការស្ថាបនាថ្នល់ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក** Road construction in the last 5 years

| ប្រភេទផ្លូវថ្នល់<br>Type of Roads | ប្រវែងផ្លូវថ្នល់បានស្ថាបនា (គីឡូម៉ែត្រ)<br>Length of Roads (Km) |
|---|---|
| 1- ថ្នល់កៅស៊ូ Metaled Road | |
| 2- ថ្នល់បេតុង Concrete Road | |
| 3- ថ្នល់គ្រួស Graveled Road | |
| 4- ថ្នល់ដី Non-graveled Road | |
| *សរុប*<br>*Total* | |

# ផ្នែកទី៤៖ សុខាភិបាល Health

**សំណួរទី៤.១៖ សេវាកម្មសុខភាព** Health services

| ប្រភេទសុខាភិបាល / សេវាកម្ម<br>Type of Health / Services | ចំនួន<br>Numbers |
|---|---|
| 1- មន្ទីរពេទ្យរដ្ឋ (បង្អែកខេត្ត ស្រុក ...) Government Hospital | |
| 2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព Health centers/Health Post | |
| 3- គ្លីនិកឯកជន Private clinic | |
| 4- ឱសថស្ថាន Pharmacy | |
| 5- វេជ្ជបណ្ឌិត Doctors | |
| 6- ពេទ្យមធ្យម Health assistants | |
| 7- គិលានុបដ្ឋាយិកា ឬឆ្មប Nurses/Midwives | |
| 8- ឆ្មបបុរាណ Traditional midwives | |

**សំណួរទី៤.២ ៖ ជំងឺចម្បងទូទៅ** Prevalence of major diseases

| ការពិពណ៌នា<br>Descriptions | ចំនួនករណី<br>No. of Cases | | |
|---|---|---|---|
| | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| *1- គ្រុនចាញ់ Malaria* | | | |
| 1.1- ចំនួនករណីកើតជំងឺគ្រុនចាញ់ No. of Malaria cases | | | |
| 1.2- ចំនួនស្លាប់ដោយជំងឺគ្រុនចាញ់ No. of Malaria deaths | | | |
| *2- របេង TB* | | | |
| 2.1- ចំនួនករណីកើតជំងឺរបេង No. of TB cases | | | |
| 2.2- ចំនួនស្លាប់ដោយជំងឺរបេង No. of TB deaths | | | |

**សំណួរទី៤.៣ ៖ ចំនួនអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ តាមក្រុមអាយុ** Number of HIV / AIDS by Age Group

| ក្រុមអាយុ<br>Age group | ចំនួនអ្នកកើតជំងឺអេដស៍<br>Number of AIDS | | | ចំនួនអ្នកស្លាប់ដោយជំងឺអេដស៍<br>Number of Death from AIDS | | |
|---|---|---|---|---|---|---|
| | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| 1- ( ០-១៧ ឆ្នាំ ) 0-17 years | | | | | | |
| 2- ( ១៨-២៥ ឆ្នាំ ) 18-25 years | | | | | | |
| 3- ( ២៦-៥៩ ឆ្នាំ ) 26-59 years | | | | | | |
| 4- ( ៦០ ឆ្នាំឡើង ) 60 over years | | | | | | |
| *សរុប*<br>*Total* | | | | | | |

**សំណួរទី៤.៤ ៖ គ្រួសារដែលមានជំងឺអេដស៍ ឬផ្ទុកមេរោគអេដស៍ និងកុមារកំព្រា** Households having HIV / AIDS Patients and Orphans

| ការពិពណ៌នា<br>Descriptions | ចំនួនមនុស្ស<br>No. of People |
|---|---|
| 1- គ្រួសារដែលមានសមាជិកមានជំងឺអេដស៍ ឬផ្ទុកមេរោគអេដស៍<br>Households having member affected by HIV / AIDS | |

| | |
|---|---|
| 2- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលឪពុកម្តាយបានស្លាប់ដោយជំងឺអេដស៍<br>Orphans ( less than 18 years old ) whose parents died with HIV / AIDS | |
| 3- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលមានអ្នកមើលថែត្រឹមត្រូវ<br>Orphans ( less than 18 years old ) who have legal protector | |
| 4- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលគ្មានអ្នកមើលថែត្រឹមត្រូវ<br>Orphans ( less than 18 years old ) who do not have legal protector | |
| *សរុប*<br>*Total* | |

## ផ្នែកទី៥ ៖ កសិកម្ម Agriculture

**សំណួរទី៥.១ ៖ ចំនួនផ្ទៃដីកសិកម្ម** Number of Agricultural land

| ផ្ទៃដី<br>Area | ចំនួនផ្ទៃដី (ហិកតា)<br>No. of Area ( ha ) |
|---|---|
| ផ្ទៃដីកសិកម្ម Agricultural land | |

**សំណួរទី៥.២ ៖ ការកាន់កាប់ដីកសិកម្ម** Landholding and Agricultural land

| ទំហំផ្ទៃដី<br>Size of landholding | ចំនួនគ្រួសារ<br>No. Households |
|---|---|
| 1- ( គ្មានដី ) Landless | |
| 2- ( តិចជាង១ហិកតា ) <1 ha | |
| 3- ( ១-១,៩៩ហិកតា ) 1-1.99 ha | |
| 4- ( ២-២,៩៩ហិកតា ) 2-2.99 ha | |
| 5- ( ៣-៣,៩៩ហិកតា ) 3-3.99 ha | |
| 6- ( ៤-៤,៩៩ហិកតា ) 4-4.99 ha | |
| 7- ( ៥ហិកតាឡើង ) More than or 5 ha | |
| *សរុប ( ត្រូវស្មើនឹងចំនួនគ្រួសារក្នុងភូមិ )*<br>*Total ( Must be equal to the households in the village )* | |

**សំណួរទី៥.៣ ៖ ផ្ទៃដីកសិកម្មដែលមាន និងផ្ទៃដីដែលបានដាំដុះ** Agricultural and Cultivated land

| ផ្ទៃដីដែលមាន (ហិកតា) Area in hectares | | | ផ្ទៃដីបានដាំដុះ (ហិកតា) Production in hectare | | |
|---|---|---|---|---|---|
| រដូវប្រាំង Dry season | រដូវវស្សា Wet season | ទាំងពីររដូវ Multi -season | រដូវប្រាំង Dry season | រដូវវស្សា Wet season | ទាំងពីររដូវ Multi-season |
| | | | | | |

**សំណួរទី៥.៤ ៖ ស្ថានភាពប្រព័ន្ធស្រោចស្រព** Irrigation status

| ប្រព័ន្ធស្រោចស្រព Irrigation status | ផ្ទៃដីបានដាំដំណាំ (ហិកតា) Cropped area (ha) | | |
|---|---|---|---|
| | សរុប Total | ដំណាំស្រូវ Paddy | ដំណាំផ្សេង Other crops |
| 1- មានប្រព័ន្ធស្រោចស្រព Irrigated | | | |
| 2- គ្មានប្រព័ន្ធស្រោចស្រព Non-Irrigated | | | |

**សំណួរទី៥.៥ ៖ ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វចង្រៃក្នុងកសិកម្ម** Fertilizers and Insecticides using in Agricultural

| ប្រភេទជី និង ថ្នាំសម្លាប់សត្វចង្រៃ Types fertilizers and Insecticides | ផ្ទៃដីបានដាំដំណាំ (ហិកតា) Cropped area (ha) | | |
|---|---|---|---|
| | សរុប Total | ដំណាំស្រូវ Paddy | ដំណាំផ្សេង Other crops |
| 1- ជីគីមី Inorganic fertilizers | | | |
| 2- ជីសរីរាង្គ Organic fertilizers | | | |
| 3- ថ្នាំសម្លាប់សត្វចង្រៃ Pesticides | | | |
| 4- ថ្នាំសម្លាប់ផ្សិត Fungicides | | | |
| 5- ថ្នាំសម្លាប់ស្មៅ Herbicides | | | |
| 6- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | | |

**សំណួរទី៥.៦ ៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី** Livestock and Poultry holdings

| ប្រភេទនៃបសុសត្វ និងបសុបក្សី<br>Type of Livestock and poultry | ចំនួនគ្រួសារ<br>No. Households | ចំនួនសត្វ<br>No. of animals | ចំនួនសត្វ/គ្រួសារ<br>No. of animals/<br>Households |
|---|---|---|---|
| 1- គោ Cattles | | | |
| 2- ក្របី Buffalo | | | |
| 3- សេះ Horses | | | |
| 4- ជ្រូក Pigs | | | |
| 5- ពពែ/ចៀម Goat / Sheep | | | |
| 6- មាន់ Chicken | | | |
| 7- ទា Ducks | | | |
| 8- គ្រួច Quail | | | |
| 9- ត្រចៀកកាំ Swallow | | | |
| 10- សត្វល្អិត Insects | | | |
| 11- ផ្សេងៗ ( សូមបញ្ជាក់.... ) Other ( Please specify... ) | | | |

**សំណួរទី៥.៧ ៖ ការធ្វើវារីវប្បកម្ម** Aquaculture

| ប្រភេទនៃវារីវប្បកម្ម<br>Type of Aquaculture | ចំនួនគ្រួសារ<br>No. of<br>Households | ចំនួនស្រះ<br>No. of ponds | ចំនួនផលិតផល (តោន/ឆ្នាំ)<br>No. of Production (ton/Year) | ផលិតផល/គ្រួសារ<br>Production /<br>Households |
|---|---|---|---|---|
| 1- ត្រី Fish | | | | |
| 2- បង្គារ Shrimp | | | | |
| 3- បង្កង Lobster | | | | |
| 4- ក្រពើ Crocodile | | | | |
| 5- កង្កែប Frog | | | | |
| 6- អន្ទង់ Eel | | | | |
| 7- ផ្សេងៗ ( សូមបញ្ជាក់.... )<br>Other ( Please specify... ) | | | | |

## សំណួរទី៥.៨ ៖ ផ្ទៃដី និងផលិតកម្មនៃដំណាំសំខាន់ៗ Area and Production of Major crops

| ដំណាំ Crops | ផ្ទៃដី (ហិកតា) Area (ha) | ទិន្នផលមធ្យម (តោន/ហិកតា) Average Yield rate (t/ha) | ចំនួនប្រមូលផល/ឆ្នាំ No. of harvests / year | បរិមាណផលិតកម្ម (តោន) Estimated production (ton) | គោលបំណងចម្បង Main purpose | |
|---|---|---|---|---|---|---|
| | | | | | សម្រាប់ហូប For home Consumption | សម្រាប់លក់ Only for sale |
| 1- ស្រូវ Paddy | | | | | | |
| 2- ពោត Corn | | | | | | |
| 3- សណ្តែកសៀង Soybean | | | | | | |
| 4- សណ្តែកបាយ Green gram | | | | | | |
| 5- សណ្តែកដី Peanuts | | | | | | |
| 6- ដំឡូងមី Cassava | | | | | | |
| 7- ដំឡូងជ្វា Sweet Potato | | | | | | |
| 8- ល្ង Sesame | | | | | | |
| 9- ម្រេច Black Pepper | | | | | | |
| 10- ស្វាយចន្ទី Cashew nuts | | | | | | |
| 11- កៅស៊ូ Rubber | | | | | | |
| 12- ចេក Banana | | | | | | |
| 13- ក្រូច Orange | | | | | | |
| 14- មៀន | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| Longan | | | | | | |
| 15- សាវម៉ៅ<br>Rambutan | | | | | | |
| 16- ស្វាយ<br>Mango | | | | | | |
| 17- ល្ហុង<br>Papaya | | | | | | |
| 18- ទុរេន<br>Durian | | | | | | |
| 19- ប៊ឺរ<br>Avocado | | | | | | |
| 20- អំពៅ<br>Sugar Cane | | | | | | |
| 21- ផ្សេងៗ<br>Other crops | | | | | | |

# ឧបសម្ព័ន្ធ ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ
## របស់ក្រសួងផែនការ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០២ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងឥស្សរជនចំនួន ២៣៨ រូប ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦៤ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញបទបញ្ជាលេខ ០៥ បប ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការអនុវត្តព្រះរាជក្រឹត្យ និងអនុក្រឹត្យផ្ទេរ និងសមាហរណកម្មការងាររបស់ស្ថាប័នរដ្ឋមួយចំនួន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

**<u>សម្រេច</u>**

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១៖ អនុក្រឹត្យនេះរៀបចំអង្គភាពនានារបស់ក្រសួងផែនការ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន វិទ្យាស្ថាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូក ២
## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២ ៖ ក្រសួងផែនការត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់ឱ្យទទួលបន្ទុកបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យផែនការស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើការអនុវត្តន៍ស្ថិតិ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ ៖ ក្រសួងផែនការមានមុខងារនិងភារកិច្ចដូចតទៅ ៖

- ធ្វើសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ទស្សនាទាន យុទ្ធសាស្ត្រ គោលនយោបាយ និងកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍប្រទេសជាតិ ដោយឈរលើមូលដ្ឋាននៃការបង្កើតឱ្យមាននិរន្តរភាព និងតុល្យភាពរវាងកិច្ចអភិវឌ្ឍ និងសមភាព យុត្តិធម៌ក្នុងសង្គម រវាងកិច្ចអភិវឌ្ឍខាងសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍខាងសង្គមកិច្ចនិងវប្បធម៌ រវាងទីប្រជុំជននិងជនបទ រវាងការធ្វើអាជីវកម្ម និងការកកើតឡើងវិញនៃធនធានធម្មជាតិ និង រវាងកិច្ចអភិវឌ្ឍនិងការការពារបរិស្ថាន ។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្ត្រនិងបែបបទក្នុងការរៀបចំផែនការស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច តាមប្រព័ន្ធវិមជ្ឈការក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- រៀបចំផែនការ និងកម្មវិធីជាតិសម្រាប់កិច្ចអភិវឌ្ឍរយៈពេលវែង មធ្យម និងខ្លី ដោយសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថាផែនការ និងកម្មវិធីជាតិទាំងនោះមានសង្គតិភាពជាមួយគ្នា រវាងបណ្តាវិស័យសេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងរាជធានី ខេត្ត ក្រុង និងតំបន់នានាក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- តាមដានត្រួតពិនិត្យការអនុវត្តផែនការ កម្មវិធីជាតិ និងបណ្តាគម្រោងពីគ្រប់ផ្នែកទាំងអស់ហើយវាយតម្លៃលទ្ធផលនៃការអនុវត្ត និងលើកឡើងពីវិធានការកែតម្រូវផែនការ កម្មវិធីជាតិទាំងនោះក្នុងករណីចាំបាច់ ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្តានុពលនៃធនធានទាំងក្នុង និងក្រៅប្រទេស ។
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់បរិមាណធនធានសរុបនិងវិភាជន៍ទុនវិនិយោគសាធារណៈប្រចាំឆ្នាំ ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិទ្យាសាស្ត្របច្ចេកទេស និងជាមួយដៃគូអភិវឌ្ឍន៍ឱ្យមានសង្គតិភាពជាមួយនឹងទិសដៅ និងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយប្រជាសាស្ត្រ ការផ្លាស់ប្តូរទីលំនៅ និងផែនការសកម្មភាពស្តីពីការបែងចែកកម្លាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការការពារជាតិ ។
- សហការជាមួយក្រសួង ស្ថាប័នកណ្តាលទាំងបួនសម្រាប់កំណត់និងវាស់វែងភាពក្រីក្រនៅកម្ពុជា។
- រៀបចំវិធីសាស្ត្រធ្វើជំរឿន អង្កេតនិងអនុវត្តការធ្វើជំរឿន អង្កេត ប្រជាពស្ត្រ សេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ។
- ធ្វើជំរឿនអង្កេតនិងការសិក្សាស្រាវជ្រាវដែលចាំបាច់ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងព័ត៌មានស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស។
- គ្រប់គ្រងប្រព័ន្ធស្ថិតិជាតិកម្ពុជាតាមការចងក្រង ណែនាំអនុវត្តវិធីប្រើចំណាត់ថ្នាក់ស្ថិតិ និងគំរូតារាងឯកភាពក្នុងការបំពេញនិងការប្រមូលយកព័ត៌មានស្ថិតិ ណែនាំអនុវត្តវិធីសាស្ត្រ និងរូបមន្ត

២

គណនាទិន្នន័យស្ថិតិឯកភាពក្នុងទូទាំងប្រទេស ។

- ផ្តល់ជំនួយខាងផ្នែកបច្ចេកទេស និងវិធីសាស្ត្រឬអនុវត្តការធ្វើជំរឿន និងអង្កេតតាមវិស័យ និងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ចងក្រងគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម និងកម្រងតួលេខស្ថិតិរបស់កម្ពុជាទៀងទាត់ជាប្រចាំ ។
- សហការដោះដូរព័ត៌មានស្ថិតិជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ ក្នុងពិភពលោក និងបណ្តាអង្គការជាតិ អង្គការអន្តរជាតិ ។
- បំពេញមុខងារនិងភារកិច្ចចាំបាច់ផ្សេងទៀតតាមការទុកចិត្តនិងការប្រគល់សិទ្ធពីនាយករដ្ឋមន្ត្រី។

មាត្រា ៤ ៖ ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ ៖

ក. នៅថ្នាក់កណ្តាល

- អគ្គនាយកដ្ឋានផែនការរួមមាន៖
  + នាយកដ្ឋានផែនការទូទៅ
  + នាយកដ្ឋានផែនការសេដ្ឋកិច្ច
  + នាយកដ្ឋានផែនការសង្គមកិច្ច
  + នាយកដ្ឋានផែនការវិនិយោគ
  + នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ
  + នាយកដ្ឋានលើកកម្ពស់អាហារូបត្ថម្ភ
  + នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
  + នាយកដ្ឋានផែនការថ្នាក់ក្រោមជាតិ
- វិទ្យាស្ថានជាតិស្ថិតិរួមមាន ៖
  + នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
  + នាយកដ្ឋានស្ថិតិសង្គមកិច្ច
  + នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត
  + នាយកដ្ឋានស្តង់ដារស្ថិតិនិងវិភាគស្ថិតិ
  + នាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានវិទ្យា
  + នាយកដ្ឋានគណនេយ្យជាតិ
  + នាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការស្ថិតិ
  + នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ
- អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍរួមមាន៖
  + នាយកដ្ឋានផ្សព្វផ្សាយ និងព័ត៌មាន
  + នាយកដ្ឋានបណ្តុះបណ្តាល និងការអភិវឌ្ឍ
  + នាយកដ្ឋានវិភាគគោលនយោបាយប្រជាជន
  + នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
- អគ្គាធិការដ្ឋាន
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានរដ្ឋបាលទូទៅ
- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

៣

ខ. អង្គភាពមូលដ្ឋាន

មន្ទីរផែនការរាជធានី ខេត្ត

អង្គការលេខរបស់ក្រសួងផែនការជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គនាយកដ្ឋានផែនការ

មាត្រា ៥ ៖ អគ្គនាយកដ្ឋានផែនការមានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួងក្នុងការងារ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្ររយៈពេលវែង មធ្យម និងខ្លីសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។
- កំណត់អាទិភាពក្នុងការវិនិយោគទាំងឯកជន និងសាធារណៈ ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្តានុពលនៃធនធានទាំងក្នុងនិងក្រៅប្រទេស តាមរយៈកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល។
- ដឹកនាំនិងគ្រប់គ្រងវិធីសាស្ត្រ និងបែបបទក្នុងការរៀបចំផែនការស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ធានាសង្គតិភាពរវាងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ដោយសម្របសម្រួលផែនការកម្មវិធី និងគម្រោងអភិវឌ្ឍន៍តាមវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដែលរៀបចំឡើងដោយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជធានី ខេត្ត ក្រុង ។
- តាមដានត្រួតពិនិត្យការអនុវត្តផែនការ និងកម្មវិធីជាតិ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជធានី ខេត្ត ក្រុង និងវិទ្យាស្ថានជាតិស្ថិតិ និងធ្វើរបាយការណ៍បូកសរុប និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងផែនការ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច។
- រៀបចំគោលនយោបាយប្រជាសាស្ត្រការផ្លាស់ប្តូរទីលំនៅ និងផែនការសកម្មភាពស្តីពីការបែងចែកកម្លាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការការពារជាតិ ។
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ លើកកម្ពស់អាហារូបត្ថម្ភ និងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងកំណត់និងវាស់វែងភាពក្រីក្រនៅកម្ពុជា។
- រៀបចំ និងអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ។
- អនុវត្តការងារថ្មីៗបន្ថែមទៀតទៅតាមតម្រូវការចាំបាច់ និងការវិវត្តជាក់ស្តែងទាំងក្នុង និងក្រៅប្រទេសសម្រាប់អភិវឌ្ឍន៍ប្រទេស ក្រោមការណែនាំនិងដឹកនាំរបស់ថ្នាក់ដឹកនាំក្រសួងផែនការ។

អគ្គនាយកដ្ឋានផែនការត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានផែនការមាននាយកដ្ឋានចំណុះចំនួន ៨ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ៦ ៖ នាយកដ្ឋានផែនការទូទៅទទួលបន្ទុក ៖

- កសាងទស្សនាទានយុទ្ធសាស្ត្រផែនការ និងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចជាតិរយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយសម្របសម្រួលជាមួយនាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានផែនការ ។

៥

- វិភាគ និងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុង និងក្រៅប្រទេស ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស។
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច រួមមានគណនេយ្យជាតិ សារពើពន្ធ ជញ្ជីងទូទាត់ រូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុ ។

មាត្រា ៧ ៖ នាយកដ្ឋានផែនការសេដ្ឋកិច្ចទទួលបន្ទុក:

- វិភាគ និងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកសេដ្ឋកិច្ចនានា នៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស ។
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការក្នុងវិស័យសេដ្ឋកិច្ច រួមមានជាអាទិ៍ កសិកម្ម រុក្ខកម្ម នេសាទ ឧស្សាហកម្ម គមនាគមន៍ដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ សំណង់ និងបរិស្ថាន ។
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់កិច្ចសហការអភិវឌ្ឍន៍សេដ្ឋកិច្ច ទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ។

មាត្រា ៨ ៖ នាយកដ្ឋានផែនការសង្គមកិច្ចទទួលបន្ទុក :

- វិភាគ និងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តក្នុងវិស័យសង្គមកិច្ច និងស្ថានភាពប្រជាសាស្ត្រនៅក្នុងប្រទេស ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស ។
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងវិស័យសង្គមកិច្ច រួមមាន ៖ ការងារប្រជាសាស្ត្រ អប់រំ បណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍សហគមន៍ ការកាត់បន្ថយភាពក្រីក្រ លំនៅដ្ឋាន សុខាភិបាល អាហារូបត្ថម្ភ សង្គមកិច្ច ការងារវប្បធម៌ សមភាពយេនឌ័រ សាសនា និងព័ត៌មាន ។

មាត្រា ៩ ៖ នាយកដ្ឋានផែនការវិនិយោគទទួលបន្ទុក :

- វិភាគ និងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកវិនិយោគនៅក្នុងប្រទេស ទាំងវិនិយោគសាធារណៈ និងឯកជន ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ដើម្បីតម្រង់ទិសវិនិយោគឲ្យសមស្របតាមទិសដៅអាទិភាពនៃការអភិវឌ្ឍប្រទេស ។
- រៀបចំយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ។
- កំណត់អាទិភាពក្នុងការវិភាជន៍ទុនតាមវិស័យ ។
- ពិនិត្យសេចក្តីព្រាងគម្រោងវិនិយោគសាធារណៈរបស់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ។
- រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលប្រចាំឆ្នាំ ។
- ចូលរួមក្នុងគណៈកម្មការដេញថ្លៃលើគ្រប់គម្រោងការងារវិនិយោគសាធារណៈ ។
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល។

មាត្រា ១០ ៖ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិទទួលបន្ទុក :

- វិភាគ និងព្យាករណ៍ពីស្ថានភាពរួមនៃការងារសហប្រតិបត្តិការសេដ្ឋកិច្ច ជាមួយបរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់ដើម្បីតម្រង់ទិសការងារសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេសជាមួយបរទេសឲ្យស្របតាមទិសដៅនៃការអភិវឌ្ឍប្រទេស ។
- ធ្វើសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលក្នុងក្របខ័ណ្ឌការងារផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចជាមួយបរទេសតាមការចាំបាច់ ។

៥

- សម្របសម្រួលការងារសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិទ្យាសាស្ត្របច្ចេកទេសជាមួយបរទេសផ្សេងទៀតតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ជាអាទិ៍ដូចជាការងារក្នុងក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) និងអាស៊ាន ជាដើម ។

មាត្រា១១ ៖ នាយកដ្ឋានលើកកម្ពស់អាហារូបត្ថម្ភទទួលបន្ទុក ៖

- រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រស្តីពីអាហារូបត្ថម្ភ ។
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍នានា អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ វិស័យឯកជននិងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗ ដែលធ្វើការងារពាក់ព័ន្ធនិងអាហារូបត្ថម្ភ ។
- តាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋកម្ពុជាដោយយកចិត្តទុកដាក់ ជាពិសេសដល់ក្រុមជនដែលងាយរងគ្រោះ ។
- សិក្សាស្រាវជ្រាវអំពីបញ្ហាកង្វះអាហារូបត្ថម្ភ និងសេចក្តីត្រូវការ និងបញ្ហាពាក់ព័ន្ធនឹងអាហារូបត្ថម្ភ និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងរាជរដ្ឋាភិបាល ។
- បង្កើនការផ្សព្វផ្សាយចំណេះដឹង ស្តីពីអាហារូបត្ថម្ភឲ្យបានទូលំទូលាយទូទាំងប្រទេស ។
- ធ្វើជាសេនាធិការឲ្យក្រសួង ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិនិងគណៈកម្មការបច្ចេកទេសអន្តរក្រសួង ។

មាត្រា១២ ៖ នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រទទួលបន្ទុក ៖

- រៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្តីពីការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា។
- រៀបចំនីតិវិធី និងលក្ខណៈវិនិច្ឆ័យ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- សម្របសម្រួលជាមួយក្រសួងស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- តាមដានត្រួតពិនិត្យការអនុវត្ត អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ។
- ណែនាំ និងបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋានអំពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។
- ប្រមូល ចងក្រងព័ត៌មានអំពីគ្រួសារក្រីក្រសម្រាប់កំណត់កម្រិតភាពក្រីក្រ និងអត្រាភាពក្រីក្រ។
- ផ្សព្វផ្សាយព័ត៌មាន អំពីលទ្ធផលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
- ធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រជាប្រចាំ សម្រាប់តម្រូវការនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមមូលនិធិសមធម៌ និងតម្រូវការផ្សេងៗទៀត ។

មាត្រា១៣ ៖ នាយកដ្ឋានផែនការថ្នាក់ក្រោមជាតិទទួលបន្ទុក៖

- រៀបចំ និងណែនាំបណ្តុះបណ្តាលពីបែបបទនីតិវិធីសម្រាប់រៀបចំគោលនយោបាយយុទ្ធសាស្ត្រគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ក្នុងក្របខ័ណ្ឌការងារផែនការ អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។
- ធានាក្នុងការធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ទៅនឹងផែនការ ។
- ផ្សព្វផ្សាយពីគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍជាតិ នីតិវិធី និងសេចក្តីណែនាំទាក់ទងនឹងការងារផែនការ ដល់អ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

- សហការ និងសម្របសម្រួលជាមួយគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា លើការងារពាក់ព័ន្ធនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មាន កម្រងស្ថានភាពទិន្នន័យ មូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ដើម្បីគាំទ្រដល់ការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។
- រៀបចំមូលដ្ឋានទិន្នន័យឃុំ សង្កាត់ (Commune Data Base) សម្រាប់បម្រើឲ្យការងាររៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។
- រៀបចំ និងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ។
- វិភាគ រាយការណ៍ និងផ្តល់យោបល់ពីលទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិជូនថ្នាក់ដឹកនាំក្រសួងផែនការ ។

## ជំពូក ៤
## វិទ្យាស្ថានជាតិស្ថិតិ

មាត្រា១៤ ៖ វិទ្យាស្ថានជាតិស្ថិតិមានមុខងារអនុវត្តន៍រាល់បេសកកម្មរបស់ក្រសួងក្នុងការធ្វើជំរឿន និងអង្កេតអំពីសេដ្ឋកិច្ច សង្គមកិច្ចនិងប្រជាសាស្ត្រ ។ ចងក្រង និងណែនាំវិធីប្រើប្រាស់ចំណាត់ថ្នាក់ស្ថិតិតារាងឯកភាព និងវិធីសាស្ត្រគណនាទិន្នន័យស្ថិតិ ប្រមែប្រមូល ចងក្រង និងផ្សព្វផ្សាយទិន្នន័យស្ថិតិស្តីពីស្ថានភាពនៃការវិវត្តន៍ក្នុងផ្នែកសេដ្ឋកិច្ច សង្គមកិច្ចនៅក្នុងប្រទេស ។

- សហការជាមួយអង្គភាពស្ថិតិជាតិ នៃប្រទេសនានាក្នុងតំបន់ និងពិភពលោកក្នុងការដោះដូរព័ត៌មានស្ថិតិ បណ្តុះបណ្តាលមន្ត្រីជំនាញការងារស្ថិតិដើម្បីការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិកម្ពុជា ។

វិទ្យាស្ថានជាតិស្ថិតិត្រូវដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួន ជួយធ្វើការតាមការចាំបាច់ ។

វិទ្យាស្ថានជាតិស្ថិតិមាននាយកដ្ឋានចំណុះចំនួន ៨ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា១៥ ៖ នាយកដ្ឋានស្ថិតិសេដ្ឋកិច្ចទទួលបន្ទុក ៖
- ប្រមូល ចងក្រងព័ត៌មានបឋមស្តីពីស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន។
- សិក្សានិងសហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំនិងធ្វើជំរឿន អង្កេតប្រមូល ចងក្រងនិងវិភាគព័ត៌មានស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម ស្ថិតិសំណង់ ស្ថិតិគមនា-គមន៍ដឹកជញ្ជូន ស្ថិតិទេសចរណ៍ និងស្ថិតិបរិស្ថាន ។

មាត្រា១៦ ៖ នាយកដ្ឋានស្ថិតិសង្គមកិច្ចទទួលបន្ទុក ៖
- ប្រមូល ចងក្រងព័ត៌មានបឋមស្តីពីស្ថិតិសង្គមកិច្ច ការងារស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិព័ត៌មាន និងស្ថិតិវប្បធម៌ ។
- សិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធរៀបចំ និងធ្វើជំរឿនអង្កេតប្រមូលចងក្រង និងវិភាគព័ត៌មានស្ថិតិសង្គមកិច្ច ការងារស្ថិតិអប់រំសិក្សា ស្ថិតិសុខាភិបាល ស្ថិតិព័ត៌មាននិងស្ថិតិវប្បធម៌ ។

មាត្រា១៧ ៖ នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេតទទួលបន្ទុក :

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ ។
- សហការធ្វើការរៀបចំអនុវត្តការធ្វើជំរឿន អង្កេតតាមប្រធានបទនានា តាមសំណូមពររបស់បណ្តាអង្គភាព និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ ។
- ធ្វើការបណ្តុះបណ្តាលបំពេញសមត្ថភាពជំនាញស្ថិតិ ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ តាមតម្រូវការការងារ ។

មាត្រា ១៨ ៖ នាយកដ្ឋានស្តង់ដារស្ថិតិនិងវិភាគស្ថិតិទទួលបន្ទុក:

- រៀបចំ និងចងក្រងចំណាត់ថ្នាក់ស្តង់ដារស្ថិតិជាតិ ដើម្បីបម្រើឲ្យការផលិតទិន្នន័យជំរឿន អង្កេត និងការវិភាគ ។
- រៀបចំ និងចងក្រងទស្សនាទាន និយមន័យស្ថិតិជាតិ ។
- រៀបចំ និងចងក្រងវិធីសាស្ត្រស្ថិតិរបស់ស្ថិតិផ្លូវការតាមវិស័យ ដើម្បីធានាដំណើរការ ផលិតទិន្នន័យស្ថិតិផ្លូវការឲ្យបានត្រឹមត្រូវ មានគុណភាព និងគួរទុកចិត្តបាន ។
- សម្របសម្រួលក្នុងការអនុវត្តន៍ចំណាត់ថ្នាក់ស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ដើម្បីឲ្យអង្គភាពស្ថិតិដែលបានចាត់តាំងអនុវត្តមានការឯកភាពគ្នា ។
- វិភាគស្ថិតិស៊ីជម្រៅ តាមប្រធានបទដែលបានពីការអង្កេត និងជំរឿន ដូចជា ភាពក្រីក្រ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការប្រើប្រាស់ពេលវេលា អាហារូបត្ថម្ភ ពលកម្មកុមារ និងប្រធានបទចាំបាច់ផ្សេងទៀត ។
- ស្រាវជ្រាវ និងក្រងចងព័ត៌មានស្ថិតិសំខាន់ៗតាមសំណូមពរ និងតាមតម្រូវការរបស់អ្នកប្រើប្រាស់ អ្នកធ្វើគោលនយោបាយ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ ។
- ផ្សព្វផ្សាយវិធីសាស្ត្រ នៃការវិភាគស៊ីជម្រៅដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៃក្រសួងស្ថាប័នរាជរដ្ឋាភិបាល ។
- ទទួលបន្ទុកធ្វើបញ្ជីឈ្មោះទិន្នន័យស្ថិតិរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់របស់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល ។
- ផ្តល់សេវាកម្មស្រាវជ្រាវ និងវិភាគស្ថិតិតាមសំណូមពរនិងសេចក្តីត្រូវការរបស់ស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ។

មាត្រា ១៩ ៖ នាយកដ្ឋានបច្ចេកវិទ្យា ទូរគមនាគមន៍ និងព័ត៌មានវិទ្យាទទួលបន្ទុក :

- តម្លើងកែលម្អ ថែទាំ ជួសជុលប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង និងទំនាក់ទំនងបញ្ជូន ព្រមទាំងទទួលព័ត៌មាននិងទិន្នន័យពីក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដោយធានាផ្តល់នូវសុវត្ថិភាពទិន្នន័យក្នុងប្រព័ន្ធស្ថិតិ និងសេវាផ្សេងទៀត ដូចជា៖ អ៊ីនធឺណែត អ៊ីម៉ែល ការរក្សា ការបែងចែកឯកសារ និងការបោះពុម្ពឯកសារ ។
- វិភាគតម្រូវការ ការងារអភិវឌ្ឍប្រព័ន្ធ និងតម្លើងកម្មវិធីដោយរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ កែតម្រូវបញ្ហាសម្អាតទិន្នន័យបម្លែងជាទិន្នន័យមូលដ្ឋាន ព្រមទាំងត្រួតពិនិត្យផ្នែកទន់សម្រាប់ការងារអង្កេត និងជំរឿន ។
- បង្កើត រៀបចំ ថែរក្សា កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន កំណត់លេខកូដ និងអភិវឌ្ឍន៍ផ្នែកទន់ដើម្បីអនុវត្តឲ្យមានការឯកភាព និងប្រសិទ្ធភាពនៃទិន្នន័យមូលដ្ឋាន ។
- បង្កើត រៀបចំគេហទំព័រនិងប្រព័ន្ធអេឡិចត្រូនិចដើម្បីផ្សព្វផ្សាយអំពីរបាយការណ៍ និងស្ថិតិ ។
- ទទួលបន្ទុករៀបចំ និងអនុវត្តគោលការណ៍បែបបទប្រើប្រាស់ និងស្តង់ដារប្រព័ន្ធកុំព្យូទ័រដើម្បីធានាឲ្យមានប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងទិន្នន័យ។

- ត្រួតពិនិត្យការវាយបញ្ចូលទិន្នន័យ ការកែតម្រូវទិន្នន័យសម្អាតកំហុសទិន្នន័យបឋម និងធ្វើការណែនាំការវាយបញ្ចូលទិន្នន័យដោយកុំព្យូទ័រ ។
- ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយទិន្នន័យមូលដ្ឋានកម្មវិធីសម្រាប់បញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យតាមការកំណត់របស់ឯកសារណែនាំ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យមូលដ្ឋាន និងព័ត៌មានស្ថិតិដល់អ្នកប្រើប្រាស់ អ្នកអភិវឌ្ឍន៍ផ្នែកទន់ អ្នកប្រើប្រាស់ស្ថិតិនៃក្រសួងស្ថាប័នរាជរដ្ឋាភិបាលនិងសាធារណជន ។
- ស្រាវជ្រាវ និងដាក់ឲ្យប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រថ្មីៗក្នុងក្រសួងដែលទាក់ទងនិងការគ្រប់គ្រងប្រព័ន្ធបណ្តាញកុំព្យូទ័រ ការអភិវឌ្ឍកម្មវិធីកុំព្យូទ័រ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការវិភាគ និងគ្រោងវាយបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ អ៊ិនធឺណែត អ៊ីម៉ែល គេហទំព័រ ។

មាត្រា ២០ ៖ នាយកដ្ឋានគណនេយ្យជាតិទទួលបន្ទុក ៈ

- ប៉ាន់ស្មាន និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងនៃវិទ្យាស្ថានជាតិស្ថិតិ ។
- ធ្វើរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចជាតិ ការវិវត្តតាមវិស័យ អតិផរណា និងសន្ទស្សន៍ថ្លៃផ្សេងទៀត ។
- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ គណនីស្ថាប័ន គណនីលំហូរ គណនីចំណាយ គណនីមូលធន គណនីហិរញ្ញវត្ថុ គណនីពាណិជ្ជកម្មអន្តរជាតិ តារាងផ្គត់ផ្គង់និងតារាងតុល្យការ តារាងលំហូរគណនីចូល និងលំហូរគណនីចេញតាមប្រព័ន្ធគណនេយ្យជាតិនៃអង្គការសហប្រជាជាតិ តាមថ្លៃថេរ និងថ្លៃបច្ចុប្បន្នប្រចាំឆ្នាំ ។
- ចងក្រង វិភាគ និងបោះផ្សាយស្ថិតិគណនេយ្យជាតិ តាមវិស័យផលិតកម្ម និងចំណាយតាមថ្លៃថេរ និងថ្លៃបច្ចុប្បន្ន ប្រចាំត្រីមាស ។
- អង្កេត ចងក្រង វិភាគ និងបោះផ្សាយសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ប្រចាំខែ ត្រីមាស សន្ទស្សន៍ថ្លៃអ្នកផលិតប្រចាំត្រីមាស សន្ទស្សន៍តម្លៃឧស្សាហកម្មប្រចាំត្រីមាស សន្ទស្សន៍តម្លៃនាំចេញនាំចូលប្រចាំត្រីមាស សន្ទស្សន៍តម្លៃកសិកម្មប្រចាំត្រីមាស និងសន្ទស្សន៍តម្លៃផ្សេងទៀត ។
- ប្រមូលនិងចងក្រងទិន្នន័យរដ្ឋបាល តាមក្រសួងស្ថាប័នរាជរដ្ឋាភិបាលដើម្បីគាំទ្រការប៉ាន់ស្មានទិន្នផលស្ថិតិតាមវិស័យ និងគណនេយ្យជាតិ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ។
- អង្កេត និងចងក្រងសូចនាករសេដ្ឋកិច្ចមួយចំនួន ដើម្បីធានាគុណភាពនៃការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ ។
- រៀបចំ និងធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រប៉ាន់ស្មានគណនី និងអនុវត្តពេញលេញតាមប្រព័ន្ធគណនេយ្យជាតិនៃអង្គការសហប្រជាជាតិ ។
- រៀបចំ និងចងក្រងសៀវភៅណែនាំស្តីពីប្រព័ន្ធគណនេយ្យជាតិ និងស្ថិតិតម្លៃ ។

មាត្រា ២១ ៖ នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិទទួលបន្ទុក ៈ

- រៀបចំគោលនយោបាយក្នុងការពង្រឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ។
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហប្រតិបត្តិការស្ថិតិ ។
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិដល់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល អង្គភាពឯកជននិងសាធារណជនឲ្យបានយល់ដឹងអំពីសារៈសំខាន់នៃស្ថិតិ ។
- រកដំណោះស្រាយក្នុងករណីមានបទល្មើសស្ថិតិ ។
- សហប្រតិបត្តិការស្ថិតិទ្វេភាគី ពហុភាគីក្នុងតំបន់ លើពិភពលោក និងសម្របសម្រួលការងារសម្រាប់អ្នកស្រាវជ្រាវស្ថិតិអន្តរជាតិ ។
- សហការជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ដើម្បីផ្តល់ទិន្នន័យស្ថិតិ និងសេវាកម្មស្ថិតិ ។

- គ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញស្ថិតិដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។
- ប្រមូលសរុបសកម្មភាពការងារ និងធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តន៍ការងារស្ថិតិ របស់វិទ្យាស្ថានជាតិស្ថិតិ ។
- គ្រប់គ្រងលិខិតស្នាម និងតម្កល់ឯកសារ ។
- រៀបចំ និងគ្រប់គ្រងការងារចុះធ្វើសម្ភាស និងប្រមូលទិន្នន័យស្ថិតិ ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភណ្ឌរបស់វិទ្យាស្ថានជាតិស្ថិតិ ។
- រៀបចំផែនការយុទ្ធសាស្ត្រសកម្មភាពការងារស្ថិតិរយៈពេលខ្លី មធ្យម និង វែង ។
- ធ្វើគម្រោងថវិកាសម្រាប់ដំណើរការការងារស្ថិតិប្រចាំថ្ងៃ រយៈពេលខ្លី មធ្យម និងវែងរបស់វិទ្យាស្ថានជាតិស្ថិតិ ។
- ធ្វើជាលេខាធិការជូនគណៈកម្មាធិការសម្របសម្រួលស្ថិតិ ។

មាត្រា ២២ ៖ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិទទួលបន្ទុក :

- ប្រមូលនិងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីប្រជាសាស្ត្រ អត្រានុកូលដ្ឋានផ្ទះសម្បែង ស្ថានភាពគ្រួសារ និងស្ថិតិប្រជាសាស្ត្រដទៃទៀតពីការិយាល័យស្ថិតិនៃមន្ទីរផែនការរាជធានី ខេត្ត។
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីសេដ្ឋកិច្ច ដូចជា កសិកម្ម រុក្ខាប្រម៉ាញ់ នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ ទេសចរណ៍ បរិស្ថាន គមនាគមន៍ និងស្ថិតិសេដ្ឋកិច្ចដទៃទៀត ពីការិយាល័យស្ថិតិនៃមន្ទីរផែនការរាជធានី ខេត្ត។
- ប្រមូលនិងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីផលិតផលក្នុងស្រុកសរុប (GDP) សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) និងសន្ទស្សន៍ដទៃទៀត ពីការិយាល័យស្ថិតិនៃមន្ទីរផែនការរាជធានី ខេត្ត។
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីសង្គមកិច្ច ដូចជា អប់រំ ការងារ សុខាភិបាល វប្បធម៌ ព័ត៌មាន សាសនា និងស្ថិតិសង្គមកិច្ចដទៃទៀត ពីការិយាល័យស្ថិតិនៃមន្ទីរផែនការរាជធានី ខេត្ត។
- កំណត់ និងធ្វើបច្ចុប្បន្នកម្មអត្តសញ្ញាណភូមិសាស្ត្រតំបន់តូចៗ។
- ប្រមូល និងចងក្រងស្ថិតិ ស្តីពីប្រជាសាស្ត្រសេដ្ឋកិច្ចនិងសង្គមកិច្ចតាមអត្តសញ្ញាណភូមិសាស្ត្រតំបន់តូចៗ ។
- វិភាគ និងផ្សព្វផ្សាយស្ថិតិថ្នាក់ក្រោមជាតិស្តីពីប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ចស្ថិតិភូមិសាស្ត្រថ្នាក់ក្រោមជាតិ ។
- នឹងការងារមួយចំនួនទៀតពាក់ព័ន្ធនឹងស្ថិតិនិងប្រព័ន្ធទិន្នន័យថ្នាក់ក្រោមជាតិ ។

## ជំពូក ៥
## អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ

មាត្រា ២៣ ៖ អគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ មានមុខងារអនុវត្តន៍រាល់បេសកកម្មរបស់ក្រសួងក្នុងការងារ :

- លើកផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ។
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដៃគូអភិវឌ្ឍនានា ជាពិសេសមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនលើរាល់សកម្មភាពដែលពាក់ព័ន្ធ នឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ ។

១០

- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដៃគូអភិវឌ្ឍនានាលើរាល់សកម្មភាពអភិវឌ្ឍន៍សហគមន៍ តាមរយៈការចងក្រង កែលម្អនិងពង្រឹងសមត្ថភាព និងផ្តល់ឥណទាន ។ល។
- សម្របសម្រួល និងសហការជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ អំពីបញ្ហាប្រជាជននិងការអភិវឌ្ឍ ដោយរៀបចំសិក្ខាសាលា និងផ្សព្វផ្សាយនូវគោលការណ៍ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា ។
- ស្រាវជ្រាវ ចងក្រងនិងផ្សព្វផ្សាយឯកសារគោលនយោបាយផែនការកម្មវិធី និងសេចក្តីប្រកាសនានា ដែលទាក់ទងនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ ។
- តាមដាន វាយតម្លៃ និងលើកអនុសាសន៍ក្នុងការកែសម្រួលគោលនយោបាយជាតិប្រជាជន ដើម្បីឲ្យការអនុវត្តន៍គោលនយោបាយយុទ្ធសាស្រ្តជាតិនានា ដែលពាក់ព័ន្ធឲ្យកាន់តែល្អប្រសើរ ស្របតាមការវិវត្តនៃសភាពការណ៍ក្នុងប្រទេស តំបន់ និងពិភពលោក ។
- បណ្តុះបណ្តាលបច្ចេកទេសដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការវិភាគត្រួតពិនិត្យតាមដាន និងវាយតម្លៃរាល់បញ្ហាទាក់ទងនឹងប្រជាជន តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលាជាតិនិងអន្តរជាតិ ។

អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍមាននាយកដ្ឋានចំណុះចំនួន ០៤ ដូចខាងក្រោម ហើយនាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ២៤ ៖ នាយកដ្ឋានផ្សព្វផ្សាយ និងព័ត៌មានទទួលបន្ទុក ៖

- ផ្សព្វផ្សាយព័ត៌មានស្តីពីឯកសារ គោលនយោបាយ ផែនការកម្មវិធី និងសេចក្តីប្រកាសដែលទាក់ទងនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍនិងទិន្នន័យ រួមទាំងអត្ថបទបោះពុម្ពផ្សាយទស្សនាវដ្តី សៀវភៅព្រឹត្តិបត្រ ផ្ទាំងរូបភាព ការពិភាក្សាតុមូល និងខ្សែវីដេអូផ្សេងៗ ។
- ពន្យល់ និងផ្តល់ព័ត៌មានអំពីគំនិតនៃគោលនយោបាយជាតិប្រជាជន ដល់អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើផែនការ អ្នកធ្វើការសម្រេចចិត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីឲ្យមានការគាំទ្រ និងអនុវត្តគោលនយោបាយជាតិប្រជាជនឲ្យមានប្រសិទ្ធភាព ។
- ចូលរួមនិងរៀបចំធ្វើបទបង្ហាញ ការត្រួតពិនិត្យគោលនយោបាយនិងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍនៅក្នុងសន្និសីទជាតិ ដើម្បីទទួលបានការគាំទ្រពីស្ថាប័នពាក់ព័ន្ធនានា ។
- សម្របសម្រួល និងសហការជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ អំពីបញ្ហាប្រជាជន និងការអភិវឌ្ឍដើម្បីជាជំនួយក្នុងការសម្រេចគោលដៅកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- ចូលរួមក្នុងសន្និសីទ និងកិច្ចប្រជុំជាតិ និងអន្តរជាតិ និងសហការរៀបចំឯកសារសំខាន់ៗស្តីពីបញ្ហាប្រជាជន និងការអភិវឌ្ឍ ។
- រៀបចំពិធីសារ សេចក្តីប្រកាស និងដំណោះស្រាយនានាពាក់ព័ន្ធនឹងបញ្ហាប្រជាជនដូចជាសុខភាពបន្តពូជ មនុស្សចាស់ និងយេនឌ័រជាដើម ។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

មាត្រា ២៥ ៖ នាយកដ្ឋានបណ្តុះបណ្តាល និងការអភិវឌ្ឍទទួលបន្ទុក ៈ

- ចូលរួមនិងរៀបចំវគ្គបណ្តុះបណ្តាលជូនដល់អ្នកធ្វើគោលនយោបាយ អ្នកធ្វើការសម្រេចចិត្ត និងអ្នកធ្វើផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ជ្រាបនិងបង្កើនចំណេះដឹងនិងស្វែងយល់អំពីទំនាក់ទំនងនិងរវាងបញ្ហាប្រជាជននិងការអភិវឌ្ឍ ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលដើម្បីបង្កើតយន្តការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈជាវិជ្ជមាន និងកម្មវិធីថ្មីៗ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍក្នុងតំបន់ ក៏ដូចជាក្រៅតំបន់ ។
- បណ្តុះបណ្តាលបច្ចេកទេស និងចំណេះដឹងក្នុងការវិភាគ ត្រួតពិនិត្យតាមដាន និងមានលទ្ធភាពវាយតម្លៃនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ តាមរយៈការចូលរួមសិក្ខាសាលាថ្នាក់ជាតិនិងអន្តរជាតិ ។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

មាត្រា ២៦ ៖ នាយកដ្ឋានវិភាគគោលនយោបាយប្រជាជនទទួលបន្ទុក ៈ

- ស្រាវជ្រាវពីបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍជូនរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ។
- ពិនិត្យ និងស្រាវជ្រាវពីគម្លាតខុសគ្នារវាងទិន្នន័យនិងទិដ្ឋភាពជាក់ស្តែងនិងពង្រឹងសមត្ថភាពក្នុងការស្រាវជ្រាវ អំពីបញ្ហានានានៅក្នុងគោលនយោបាយជាតិប្រជាជន និងគោលនយោបាយពាក់ព័ន្ធដែលកើតមានឡើងដូចជាការបម្លាស់ទី មនុស្សចាស់ នគរូបនីយកម្មជាដើម ។
- រៀបចំសូចនាករសម្រាប់ការអនុវត្តគោលនយោបាយជាតិប្រជាជន ដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ។
- អភិវឌ្ឍមជ្ឈមណ្ឌលប្រមូលផ្តុំព័ត៌មាននិងទិន្នន័យទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

មាត្រា ២៧ ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ទទួលបន្ទុក ៈ

- កំណត់សូចនាករស្រាវជ្រាវ និងអង្កេតអំពីសហគមន៍ក្រីក្រនៅរាជធានី ខេត្ត ក្រុង សម្របសម្រួល និងធ្វើការសហការជាមួយរដ្ឋបាលមូលដ្ឋានក្នុងការកំណត់ឲ្យបាននូវសហគមន៍ក្រីក្រ ដែលត្រូវកែលម្អ និងអភិវឌ្ឍន៍ ។
- ស្វែងរកមូលនិធិជាតិ និងអន្តរជាតិ ដើម្បីជាទុនសម្រាប់ការធ្វើឥណទានដល់ប្រជាជនរស់នៅសហគមន៍ក្រីក្រជំរុញការសន្សំប្រាក់ និងផ្តល់ឥណទានមានការប្រាក់ទាបដល់សហគមន៍តាមតម្រូវការជាក់ស្តែង ។
- រៀបចំ ចងក្រង និងកែលម្អសហគមន៍ក្រីក្រឲ្យសម្រេចបានតាមគោលការណ៍ និងគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ១០០ សហគមន៍ក្នុងមួយឆ្នាំ ។
- រៀបចំ ចងក្រង និងពង្រឹងសមត្ថភាពសហគមន៍ ពង្រឹងភាពជាដៃគូក្នុងសហគមន៍នៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និងអន្តរជាតិ ។
- រៀបចំ និងរុញឲ្យមានការផ្លាស់ប្តូរ និងដកស្រង់យកបទពិសោធន៍ល្អៗពីសហគមន៍មួយទៅសហគមន៍មួយទៀត តាមរយៈទស្សនកិច្ចសិក្សា និងកិច្ចប្រជុំ ។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

## ជំពូក ៦
## អគ្គាធិការដ្ឋាន

មាត្រា ២៨ ៖ អគ្គាធិការដ្ឋានរបស់ក្រសួងផែនការទទួលបន្ទុក ៖

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចនិងពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ ។
- ប្រតិបត្តិភារកិច្ចតាមការណែនាំរបស់រដ្ឋមន្ត្រី ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយឬច្រើនរូបជួយធ្វើការតាមការចាំបាច់ ។

## ជំពូក ៧
## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ២៩ ៖ ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៨
## នាយកដ្ឋានរដ្ឋបាលទូទៅ នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ
## នាយកដ្ឋានបុគ្គលិក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

មាត្រា ៣០ ៖ នាយកដ្ឋានរដ្ឋបាលទូទៅទទួលបន្ទុក ៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង ។
- តម្កល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ ។

នាយកដ្ឋានរដ្ឋបាលទូទៅដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ៣១ ៖ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុក ៖

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភណ្ឌ ។
- គ្រប់គ្រងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងកម្មវិធីចំណាយនិងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពរាជធានី ខេត្ត ។
- កាន់បញ្ជីជាប្រចាំនូវសលាកបត្រ័ និងគណនេយ្យរូបធាតុ ។
- ព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- លើកគម្រោងថវិកាក្រសួង និងតាមដានលើកពីការប្រតិបត្តិ ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា ។

- តាមដានលើកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ ។
- ប្រមូលចំណូលឲ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ៣២ ៖ នាយកដ្ឋានបុគ្គលិកទទួលបន្ទុក ៈ

ក/ក្នុងវិស័យបុគ្គលិក

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីតំណែង ឯកទេស និងធនធានមនុស្សរបស់ក្រសួង ។
- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតាពងព័ត៌មានប្រតិបត្តិ ។
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង ។

ខ/ក្នុងវិស័យបណ្តុះបណ្តាល

មជ្ឈមណ្ឌលបណ្តុះបណ្តាលក្របខ័ណ្ឌផែនការ-ស្ថិតិ ទទួលបន្ទុក ៈ

- រៀបចំការប្រឡងជ្រើសរើស និងធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ក្នុងវិស័យផែនការ និងស្ថិតិ ។
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង ។

នាយកដ្ឋានបុគ្គលិកដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

មាត្រា ៣៣ ៖ នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុក ៈ

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងតាមបណ្តាស្ថាប័នក្រសួងនិងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជួយធ្វើការតាមការចាំបាច់ ។

## ជំពូក ៩
## អង្គភាពមូលដ្ឋាន

មាត្រា ៣៤ ៖ នៅរាជធានី ខេត្ត មានមន្ទីរផែនការរាជធានី ខេត្ត ទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពការងារផែនការរបស់ក្រសួងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ជំពូក ១០
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ៣៥ ៖ អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាម

លក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

**ជំពូក ១១**
**អវសានប្បញ្ញត្តិ**

មាត្រា៣៦ ៖ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

មាត្រា ៣៧ ៖ អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម ៖

- អនុក្រឹត្យលេខ ៥៥ អនក្រ .បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងផែនការ
- អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ

មាត្រា ៣៨ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
សូមហត្ថលេខា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

**ចម្លងជូន** :
- ខុទ្ទកាល័យក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ